ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ

# THE SITUATION OF TEACHER ALLOCATION IN PRIMARY AND SECONDARY SCHOOL IN PRAS SIHANUKVILLE PROVINCE

ដោយ/By
សូ ស៊ីណា/ SO SINA

ដើម្បីបំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH ANDSPORT

វិទ្យាស្ថានជាតិអប់រំ

Nation Institute of Education ( NIE )

# និក្ខេបបទ

# ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ

# THE SITUATION OF TEACHER ALLOCATION IN PRIMARY AND SECONDARY SCHOOL IN PRAS SIHANUKVILLE PROVINCE

ដោយ/By

សូ ស៊ីណា/ SO SINA

ដើម្បីបំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩-២០២០

សាស្ត្រាចារ្យដឹកនាំ៖ លោក  សៀង  វាសនា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទដែលមានចំណងជើងថា "**ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ**" សម្រាប់បំពេញលក្ខណសញ្ញាបត្រវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃរបស់ ខ្ញុំបាទទាំងស្រុងប្រាកដមែន ។ ស្នាដៃនេះពុំទាន់ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថាននេះឬសាកលវិទ្យល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយ។ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតិពី អ្នកនិពន្ធឬចុះបញ្ជីឯកសារយោងឡើយ។និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាស្រាវជ្រាវចងក្រងដោយរូបខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ.......................ខែ.....................ឆ្នាំជូត ទោស័កព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី............ខែ.............ឆ្នាំ២០២០

**ហត្ថលេខា**

**សូ ស៊ីណា**

# លិខិតបញ្ជាក់

**លោក សៀង វាសនា** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

**លោក សូ ស៊ីណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣ ឯកទេសវិជ្ជាជីវៈ នាយកសាលាមធ្យមសិក្សាទុតិយភូមិពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពក្នុងការប្រើប្រាស់ គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ**" ពិតប្រាកដមែន។

ថ្ងៃ.........................ខែ..................ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ២០២០

......................................

**លោក សៀង វាសនា**

គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**
លេខ:....................វជអ

# លិខិតបញ្ជាក់ និងទទួលស្គាល់

## នាយកវិទ្យាស្ថានជាតិអប់រំ

សូមបញ្ជាក់ និងទទួលស្គាល់ថា ៖

**លោក សូ ស៊ីណា** ជានិស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែលមានប្រធានបទ **"ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ ក្នុងខេត្តព្រះសីហនុ"** ស្របតាមលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាល ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត សៀង សុវណ្ណា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

លេខៈ............វជអ

## លិខិតបញ្ជាក់ និងទទួលស្គាល់
## នាយកវិទ្យាស្ថានជាតិអប់រំ

សូមបញ្ជាក់ និងទទួលស្គាល់ថាៈ

**លោក សូ ស៊ីណា** ជានិស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែលមានប្រធានបទ "**ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀន នៅកម្រិតបឋមសិក្សានិងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ**"ស្របតាមលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន។

ថ្ងៃ........................ខែ..................ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ២០២០

**បណ្ឌិត សៀង សុវណ្ណា**

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ៣៣៤..... ទជអ. ៩ក

## លិខិតឧទ្ទេសនាម

យោង៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨៖០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្តេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី រដ្ឋា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្ទី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្លួន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន វ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ www.nie.edu.kh

II. **លេខាកត់ត្រា** (កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ)

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** (រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍)

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ** អ.នៃ

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

- -នាយក នាយករង នាយិការងវជអ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"
- -ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជអ "ដើម្បីសហការ"
- -សាមីជន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជអ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សូ ស៊ីណា** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំ។

## សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

លោកឪពុក **ឡៅចមា** និងអ្នកម្តាយ **ចាន់ អាន** ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ផ្តល់នូវដំបូន្មានល្អៗ និងបានបញ្ជូនកូនឲ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់ឧត្តមសិក្សាដោយមិនគិតពីការលំបាក នឿយហត់ ព្រមទាំងតស៊ូគ្រប់បែបយ៉ាង ដើម្បីឲ្យកូនទទួលបាន នូវអ្វីៗ គ្រប់បែបយ៉ាងដូចសព្វថ្ងៃនេះ ជាពិសេសគឺ កាយសប្បទា បញ្ញាសប្បទា ចរិយាសប្បទា និងនវានុវត្តន៍ សម្រាប់កសាង សង្គមគ្រួសារល្អមួយនៅពេលអនាគត។

លោកស្រី **លីន ម៉ារី**ជាភរិយានិងកូនៗរបស់ខ្ញុំទាំងពីរ **ស៊ីណា សុវណ្ណរេត** និង **ស៊ីណា សុ វឌ្ឍនា** ដែលអ្នកទាំងអស់គ្នាតែងតែបានជួយជ្រោមជ្រែង ទាំងផ្នែកថវិកា ស្មារតី កម្លាំងចិត្ត ភាពកក់ក្តៅ ទំនុកចិត្តឲ្យខ្ញុំបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសវិជ្ជាជីវៈ នាយកសាលាមធ្យម សិក្សាទុតិយ ភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ នេះ។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ដែលបានរៀបចំផែនការណ៍បង្កើតគោលនយោបាយអប់រំឲ្យមាន វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនេះឡើង ដែលផ្តល់ឱកាសឱ្យខ្ញុំបាទ និងមន្ត្រីអប់រំបានអភិវឌ្ឍសមត្ថភាពបន្ថែមទៀត ដើម្បីបង្កើនចំណេះដឹងនិងគុណវុឌ្ឍិ ប្រកបដោយគំនិតច្នៃប្រឌិត និងការបង្កើតថ្មី។

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ លោកនាយករងលោកស្រីនាយិការរងគណៈគ្រប់គ្រងផ្នែកគ្រប់គ្រង និងផែនការលោក លោកស្រី ជាសាស្ត្រាចារ្យនិងបុគ្គលិកទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ និងលោក លោកស្រី ជាសាស្ត្រាចារ្យដែល មកពីគ្រប់អគ្គនាយកដ្ឋាននាយកដ្ឋានការិយាល័យចំណុះក្រសួងអប់រំទាំងអស់ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃមកបង្រៀនយើងខ្ញុំយ៉ាងយកចិត្តទុកដាក់ អស់ពីកម្លាំងកាយចិត្តរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ។

សាស្ត្រាចារ្យដឹកនាំ **លោក សៀខ ទាសនា** ដែលបានឆ្លៀតពេលដ៏មានតម្លៃ ក្នុងការដឹក នាំបង្ហាញផ្លូវជាគំនិត យោបល់ល្អៗទាំងកម្លាំងកាយចិត្តប្រាជ្ញាស្មារតីទាំងបច្ចេកទេស វិធីសាស្ត្រស្រាវជ្រាវរកឯកសាផ្សេងៗ រហូតទទួលបានជោគជ័យ។

លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ លោក លោកស្រីជាបុគ្គលិក ក្រោមឱវាទមន្ទីរអប់រំយុវជន និងកីឡាខេត្តទាំងអស់ដែលបានផ្តល់ឱកាសនិងសម្របសម្រួលផ្តល់ទិន្នន័យ យ៉ាងល្អិតល្អន់គ្រប់ជ្រុងជ្រោយ ដើម្បីវិភាគនិងសរសេរនិក្ខេបបទមួយនេះបានបញ្ចប់ដោយជោគជ័យ។

លោកនាយក/នាយិកាសាលាបឋមសិក្សានិងអនុវិទ្យាល័យនៅ ខេត្តព្រះសីហនុដែលលោកបានអនុញ្ញាតិ និងជួយសម្របសម្រួល បង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងឱ្យខ្ញុំបាទក្នុងការចុះបំពេញកម្មសិក្សាព្រមទាំងផ្តល់នូវឯកសារផ្សេងៗដើម្បីបំពេញបន្ថែមទាក់ទងនិងប្រធានបទនេះរហូតដល់ ទទួលបានទៅតាមគោលបំណងដែលខ្ញុំបាទរំពឹងទុកអស់រយៈពេលជាយូរកន្លងមកហើយ និងសង្ឃឹមថាលទ្ធផលនេះនិងសម្រេចបានជោគជ័យពិតប្រាកដដ៏ល្អប្រសើរ។

មិត្តរួមថ្នាក់ រួមជំនាន់ ទាំងអស់ដែលតែងតែផ្តល់កម្លាំងចិត្ត ភាពស្និតស្នាល រាក់ទាក់ជាមួយគ្នា សាមគ្គីភាពល្អ ចេះចែករំលែកបទពិសោធន៍ ចំណេះដឹង និងគំនិតយោបល់ល្អៗ ដែលធ្វើឲ្យខ្ញុំបាទមានមោទនភាពយ៉ាងខ្លាំង ដែលបានជួប និងរៀនជាមួយមិត្តល្អៗដូចនេះ។

ជាចុងក្រោយ ខ្ញុំបាទសូមគោរពជូនពរ ចំពោះ ឯកឧត្តមនាយក លោកនាយករង លោកស្រីនាយិការង បុគ្គលិក សាស្ត្រាចារ្យ ទាំងអស់នៃវិទ្យាស្ថានជាតិអប់រំនិងថ្នាក់ដឹកនាំអស់នៃក្រសួងអប់រំ យុវជន និងកីឡា ក្រុមគ្រួសាររបស់ខ្ញុំ ព្រមទាំងមិត្តរួមជំនាន់ទាំងអស់ ទទួលនូវសេចក្តីសុខសុវត្ថិភាព កម្លាំងមាំមួនប្រាជ្ញាវាងវៃ ជាពិសេសសម្រេចបានជោគជ័យគ្រប់ភារកិច្ច ។

# មាតិកា

**ចំណងជើង**

**សេចក្តីអះអាងរបស់បេក្ខជន** ........ III

**លិខិតបញ្ជាក់** ........ IV

**លិខិតបញ្ជាក់ និងទទួលស្គាល់** ........ V

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ VI

**សេចក្តីថ្លែងអំណរគុណ** ........ VII

**មាតិកា** ........ VIII

**បញ្ជីតារាង** ........ IX

**បញ្ជីរូបភាព** ........ X

**មូលន័យសង្ខេប** ........ X1

**ជំពូកទី ១សេចក្តីផ្តើម**

១.១ សេចក្តីផ្តើម ........ 01

១.២ លំនាំបញ្ហានៃការស្រាវជ្រាវ ........ 07

១.៣ គោលបំណង នៃការស្រាវជ្រាវ ........ 08

១.៤ សំណួរស្រាវជ្រាវ ........ 08

១.៥ គោលបំណងនៃការស្រាវជ្រាវ ........ 09

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ 09

១.៧. ដែលកំណត់ និងវិសាលភាពនៃការរស្រាវជ្រាវ ........ 09

១.៧.១ វិសាលភាពនៃការស្រាវជ្រាវ ........ 09

១.៧.២ ដែនកំណត់នៃការស្រាវជ្រាវ ........ 10

១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 10

**ជំពូកទី ២រំលឹកទ្រឹស្តី** ........ 12

២.១ សេចក្តីផ្តើម ........ 12

២.២ គោលនយោបាយស្តីពីគ្រូបង្រៀន ........ 13

២.៣ តួនាទី និងភារកិច្ចនាយកសាលានៅកម្ពុជា ........ 15

២.៤ ភារកិច្ចអ្នកគ្រប់គ្រងអង្គភាព ........ 17

២.៥ ការគ្រប់គ្រង និងការបែងចែងធនធានមនុស្សក្នុងវិស័យអប់រំ ........ 17

២.៥.១ ការបែងចែងគ្រូតាមសាលាបឋមសិក្សា និងវិទ្យាល័យ ........ 18

២.៥.២ គ្រឹះស្ថានសិក្សាចំណេះទូទៅ ........ 19

២.៥.៣ ការអនុវត្តម៉ោងបន្ថែម ........ 20

២.៥.៤ ការប្រើប្រាស់បុគ្គលិកនៅទីចាត់ការសាលា ........ 21
២.៦ បញ្ហាប្រឈមចំពោះការចាត់ចែងធនធានមនុស្ស ........ 22
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ........ 24
៣.១ ដែលកំណត់ និងវិសាលភាព ........ 24
៣.២ សំណាក ........ 24
៣.៣ ឧបករណ៍ ........ 25
៣.៤ វិធីសាស្ត្រប្រមូលទិន្ន័យ ........ 25
៣.៥ ការវិភាគទិន្នន័យ ........ 26
**ជំពូកទី ៤៖ លទ្ធផលនៃការស្រាវជ្រាវ** ........ 27
៤.១ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀកម្រិតមូលដ្ឋានក្នុងស្រុកទី១ ........ 33
៤.២ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានក្រុងស្រុកទី២ ........ 36
៤.៣ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិស្រុកទី៣ ........ 39
៤.៤ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិស្រុកទី៤ ........ 43
៤.៥ តម្រូវការគ្រូ និងបំណែងចែកភារកិច្ចគ្រូ ........ 46
៤.៦ បញ្ហាប្រឈមក្នុងការគ្រប់គ្រងអនុវិទ្យាល័យ ........ 47
៤.៧ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្នែកសាលាបឋមសិក្សា ........ 48
៤.៨ ស្រុកទី១៖ ស្ថិតិសិស្ស-ថ្នាក់-គ្រូ និងម៉ោង ........ 49
៤.៩ ស្រុកទី២ ៖ ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង ........ 51
៤.១០ ស្រុកទី៣៖ ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង ........ 53
៤.១១ ស្រុកទី៤៖ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង ........ 55
៤.១២ ដំណោះស្រាយរបស់នាយកសាលា ចំពោះសាលា ដែលលើស ឬ ខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) ........ 57
៤.១៣ ដំណោះស្រាយរបស់នាយកសាលា ចំពោះសាលា ដែលលើស ឬ ខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតបឋម) ........ 58
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 60
៥.១ សេចក្តីសន្និដ្ឋាន ........ 60
៥.២ សំណូមពរ ........ 61
៥.៣ ការងារស្រាវជ្រាវបន្ត ........ 62
**ឯកសារយោង**( REFERENCES ) ........ 65
**ឧបសម្ព័ន្ធ**
បញ្ជីឈ្មោះសាលាអនុវិទ្យាល័យទាំង១៨ វិទ្យាល័យ៨ដែលមានអនុវិទ្យាល័យនៅជាមួយ ........ 65
សាលាបឋមសិក្សាទាំង៧២(ខេត្តព្រះសីហនុ) ........ 67

# បញ្ជីតារាង

តារាងទី 1៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង អនុវិទ្យាល័យទាំង២៦ ក្នុងខេត្ត ព្រះ សីហនុ..........32
តារាងទី 2៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង អនុវិទ្យាល័យទាំង៣ ក្នុងស្រុកទី១......................34
តារាងទី 3៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅតាមអនុវិទ្យាល័យក្នុងស្រុកទី២....................37
តារាងទី 4៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅតាមអនុវិទ្យាល័យក្នុងស្រុកទី៣ ...................40
តារាងទី 5៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅតាមអនុវិទ្យាល័យក្នុងស្រុកទី៤....................43
តារាងទី 6៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូ សរុបតាមនិយាម និងតាមជាក់ស្តែង ទូទាំងខេត្តព្រះសីហនុ..................................49
តារាងទី 7៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១ ..................................................50
តារាងទី ៨៖ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាមនិងតាមជាក់ស្តែងក្នុងស្រុកទី២ ....................................................51
តារាងទី ៩៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង ក្នុងស្រុកទី៣..................................................53
តារាងទី 10៖ ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង ស្រុកទី៤ ខេត្តព្រះសីហនុ ............................................................55

# បញ្ជីរូបភាព


ក្រាហ្វទី 1៖ ទិន្នន័យថ្នាក់សរុប ២៦អនុវិទ្យាល័យ(ខេត្តព្រះសីហនុ) ....................................................................................... 37

ក្រាហ្វទី 2៖ ទិន្នន័យថ្នាក់សរុប ៧២សាលាបឋមសិក្សា(ខេត្តព្រះសីហនុ) .................................................................................. 28

ក្រាហ្វទី 3៖ ស្ថិតិគ្រូកម្រិតមូលដ្ឋានទាំង ២៦អនុវិទ្យាល័យ(ខេត្តព្រះសីហនុ) ............................................................................ 29

ក្រាហ្វទី 4៖ស្ថិតិគ្រូកម្រិតបឋមទាំង ៧២សាលាបឋមសិក្សា(ខេត្តព្រះសីហនុ) .............................................................................. 30

ក្រាហ្វទី 5៖ គ្រូកម្រិតមូលដ្ឋានគិតតាមនិយាម ថ្នាក់ជាក់ស្តែង អនុវិទ្យាល័យ ២៦ (ខេត្តព្រះសីហនុ) ........................................ 31

ក្រាហ្វទី 6៖ គ្រូកម្រិតបឋមសិក្សាគិតតាមនិយាម ថ្នាក់ជាក់ស្តែង សាលាបឋមសិក្ស ៧២ (ខេត្តព្រះសីហនុ) ................................. 32

ក្រាហ្វទី 7៖ ថ្នាក់ ម៉ោង គ្រូកម្រិតមូលដ្ឋានតាមនិយាម និងមានជាក់ស្តែង ........................................................................... 33

ក្រាហ្វទី 8៖ គុណវិឌ្ឍិគ្រូបង្រៀន(កម្រិតមូលដ្ឋាន)នៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតម្រូវការជាក់ស្តែងក្នុងស្រុកទី១ ............... 34

ក្រាហ្វទី 9៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ(គ្រូកម្រិតមូលដ្ឋាន)តាមនិយាមនៃមុខវិជ្ជានីមួយៗ

និងគ្រូបង្រៀនដែលមានជាក់ស្តែងនៃមុខវិជ្ជានីមួយៗ តាមអនុវិទ្យាល័យក្នុងស្រុកទី១ ........................................................ 36

ក្រាហ្វទី 10៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី២ ........... 38

ក្រាហ្វទី 11៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) តាមនិយាមនៃមុខវិជ្ជានីមួយៗនិងគ្រូបង្រៀនដែល មានជាក់ ស្តែង នៃ

មុខវិជ្ជានីមួយៗ តាមអនុវិទ្យាល័យក្នុងស្រុកទី២ ....................................................................................................... 39

ក្រាហ្វទី 12៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៣ ...........

ក្រាហ្វទី 13៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ(គ្រូកម្រិតមូលដ្ឋាន)តាមនិយាមនៃមុខវិជ្ជានីមួយ

និងគ្រូបង្រៀនដែលមានជាក់ស្តែងនៃមុខវិជ្ជានីមួយៗ តាមអនុវិទ្យា ........................................................................... 42

ក្រាហ្វទី 14៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៤ ....... 44

ក្រាហ្វទី 15៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ(គ្រូកម្រិតមូលដ្ឋាន)តាមនិយាមនៃមុខវិជ្ជានីមួយ និងគ្រូបង្រៀនដែល មានជាក់ ស្តែង

នៃមុខវិជ្ជានីមួយៗ តាមអនុវិទ្យាល័យក្នុងស្រុកទី៤ ................................................................................................... 45

ក្រាហ្វទី 16៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ ............................................................. 49

ក្រាហ្វទី 17៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ ............................................................. 50

ក្រាហ្វទី 18៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ ............................................................. 52

ក្រាហ្វទី 19៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ ............................................................. 55

ក្រាហ្វទី 20៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះក្នុងស្រុទី៤ ខេត្តព្រះសីហនុ ........................... 56

# មូលន័យសង្ខេប

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺ ដើម្បីស្វែងយល់ពីការពន្យល់ បកស្រាយរបស់គណៈគ្រប់អង្គភាពនីមួយៗលើការដឹកនាំ ការគ្រប់គ្រង និងបំណែងចែកភារកិច្ចបុគ្គលិកសិក្សាម្នាក់ៗតាមតួនាទី ស្របតាមនិយាមគុរុកោសល្យ និងបញ្ហាប្រឈមដែលគណៈគ្រប់គ្រងម្នាក់ៗបានជួបប្រទះតាមអង្គភាពនីមួយៗ។

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅតាមអនុវិទ្យាល័យ១៨ ដែលមានវិទ្យាល័យនៅជាមួយ៨ និងសាលាបឋមសិក្សា៧២ នៅក្នុងខេត្តព្រះសីហនុ អ្នកចូលរួមក្នុងការស្រាវជ្រាវនេះមាន នាយក ឬនាយករង។ការសិក្សាស្រាវជ្រាវដែលរៀបចំបែបគុណវិស័យ និងបរិមាណវិស័យត្រូវប្រើឧបករណ៍ពីរតាមរយៈការសម្ភាសន៍ និងបញ្ជីសំណួរសម្រាប់ការប្រមូលទិន្នន័យនៅក្នុងនិក្ខេបបទនេះ ។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានបញ្ចូលក្នុងកម្មវិធី (Excel) ដោយបង្កើតជាគំនូសតាង (Bar Graph) ជាក្រាហ្វិច និងភាគរយដើម្បីប្រៀបធៀបទាញសេចក្តីសន្និដ្ឋាន និងវាយតម្លៃលើលទ្ធផលដែលសម្រេចបាន។

តាមរយៈការសិក្សាបានបង្ហាញថា អនុវិទ្យាល័យ និងសាលាបឋមសិក្សាមួយចំនួនបានជួបប្រទះបញ្ហាប្រឈមជាច្រើនដែលកើតមានឡើងនៅក្នុងអង្គភាពរបស់ខ្លួនតាមរយៈការប្រើប្រាស់ និងបែងចែកបុគ្គលិកទៅតាមតួនាទី និងម៉ោងបង្រៀនរបស់បុគ្គលិកម្នាក់ៗមិនទាន់ត្រឹមត្រូវនៅឡើយទេដូចជា យកគ្រូបង្រៀនខុសឯកទេស ៧០% បន្ថយម៉ោងមុខវិជ្ជាដែលខ្វះគ្រូ ២០% យកគ្រូទុតិយភូមិជួយបង្រៀន ១០% ។

ដូច្នេះតាមរយៈការស្រាវជ្រាវនេះយើងបានរកឃើញថាមានកត្តាមួយចំនួនដែលទាក់ទងទៅនឹងការបែងចែកបុគ្គលិកបង្រៀននៅអនុវិទ្យាល័យ និងបឋមសិក្សាមិនទាន់ត្រឹមត្រូវនៅឡើយទេដោយគ្រូបង្រៀននៅសាលាមួយចំនួនលើស (ផ្ទេរចូល) សាលានៅទីប្រជុំជន ឬតាមទីរួមខេត្ត សាលាខ្លះខ្វះគ្រូឯកទេស (ផ្ទេរចេញ) ជាពិសេសសាលានៅជនបទ ឬតំបន់ដាច់ស្រយាល។

សរុបមកយើងឃើញថាបំណែងចែកភារកិច្ចគ្រូបង្រៀននៅអនុវិទ្យាល័យ និងសាលាបឋមសិក្សាក្នុងខេត្ត

ព្រះសីហនុមិនទាន់មានលក្ខណៈត្រឹមត្រូវតាមនិយាមទាំងស្រុង នៅឡើយដោយកង្វះគ្រូបង្រៀនឯកទេសខ្លះៗ នៅតាមអនុវិទ្យាល័យមួយចំនួនដែកធ្វើឱ្យគុណភាពអប់រំនៅមានកម្រិត ។ ដូច្នេះក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាមន្ទីរអប់រំ និងភាគីពាក់ព័ន្ធនានាគួរពង្រាយគ្រូបង្រៀនពីសាលាលើសឱ្យទៅបម្រើការងារនៅសាលាខ្វះគ្រូ ជ្រើសរើសគ្រូថ្មីបន្ថែមទៀត ហើយបញ្ជូនទៅតាមតម្រូវការរបស់សាលាដែលបានស្នើសុំ ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមលើប្រាក់បៀវត្សរ៍ ឬផ្តល់លិខិតសរសើ ចំពោះលោកគ្រូ អ្នកគ្រូដែលស្ម័គ្រចិត្ត ទៅបម្រើ ការនៅ សាលាជនបទ ឬតំបន់ដាច់ស្រយាល ទប់ស្កាត់ការផ្ទេរគ្រូបង្រៀនចេញពីសាលាខ្វះគ្រូ ទៅសាលាខ្វះគ្រូ ដើម្បីពង្រឹងគុណភាពអប់រំនៅខេត្តព្រះសីហនុឱ្យមានភាពល្អប្រសើរ។

# ជំពូកទី១៖ សេចក្ដីផ្ដើម

## ១.១ សេចក្ដីផ្ដើម

គុណភាពនៃការអប់រំអាចទទួលយកបានគឺអាស្រ័យទៅនឹងគុណវុឌ្ឍិរបស់គ្រូបង្រៀនកិច្ចសហការល្អរវាងគណៈគ្រប់គ្រង គ្រូ និងសិស្ស។ តម្រូវការគ្រូដែលមានគុណវុឌ្ឍិទៅតាមកម្រិតសិក្សាទាំងអស់ ក៏ចាំបាច់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវសម្រាប់សាលានីមួយៗផងដែរ ។ ការបែងចែងធនធានអប់រំទៅតាមកម្រិតនៃការចង់បានទៅតាមតម្រូវការ និងការស្នើសុំគ្រូបន្ថែមពីសំណាក់នាយកសា ឬនាយករងជាកត្តាមួយដែលគណៈគ្រប់គ្រងត្រូវធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំង និងបែងចែកទៅតាមត្រូវការចាំបាច់សម្រាប់សិស្ស និងគ្រូដើម្បីសម្រួលដល់ការបង្រៀន និងរៀន ។ ការបែងចែក និងគ្រប់គ្រងគ្រូបង្រៀនមានប្រសិទ្ធភាព វាជាកូនសោគន្លឹះដើម្បីសម្រេចបាននូវសង្គមមួយដែលមានការអភិវឌ្ឍិដោយផ្អែកលើពុទ្ធិ ពីព្រោះគ្រូបង្រៀនគឺជាមូលដ្ឋានគ្រឹះ

នៅក្នុងដំណើរការបង្ហាត់បង្រៀនហើយគុណភាពនៃការបង្រៀនគឺជាកត្តាដែលកំណត់ឱ្យគុណភាពនៃការអប់រំ។ ដើម្បីឱ្យដំណើរការនៃគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅ កម្រិតបឋមសិក្សា និងអនុវិទ្យាល័យមានប្រសិទ្ធភាពខ្ពស់មន្ត្រី គ្រប់គ្រងជាពិសេសនាយកសាលា និងផ្នែកបុគ្គលិកត្រូវរៀបចំផែនការរយៈពេលវែងមធ្យមពីតម្រូវការគ្រូ។ការធ្វើហេតុវិនិច្ឆ័យពីតម្រូវការគ្រូ ការកំណត់ចំនួនកូតា ការប្រើប្រាស់និងសុក្រឹត ភាពនៃការបែងចែកគ្រូបង្រៀន ដែលជាសូចនាករគន្លឹះក្នុងការចង្អុលបង្ហាញពីកម្រិតនៃការប្រើប្រាស់ធនធានអប់រំ និងការខាតបង់កម្លាំងពលកម្មក៏ជាកត្តាចាំបាច់បំផុតផងដែរ។

ទោះបីជាការយកចិត្តទុកដាក់ពីសំណាក់ក្រសួង អប់រំ យុវជន និងកីឡា ដោយបានធ្វើកំណែទម្រង់ជាច្រើនលើវិស័យអប់រំ យ៉ាងណាក៏ដោយ ក៏នៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យមួយចំនួន នៅតាមបណ្ដារាជធានី ខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជានៅតែមានបញ្ហាប្រឈមជាច្រើនកើតមានឡើង ដូចជាបញ្ហាការគ្រប់គ្រងរបស់នាយក នាយិកា មិនទាន់មានតម្លាភាពក្នុង ការបែងចែកភារកិច្ច បុគ្គលិក ឱ្យត្រឹមត្រូវតាមនិយាមគរុកោសល្យនៅឡើយទេ ។ លោកគ្រូអ្នកគ្រូមួយចំនួនមិនពេញចិត្តនឹង ការដឹកនាំរបស់ប្រធានអង្គភាពនិងបំណែងចែកភារកិច្ចរបស់ខ្លួនផងហើយម្យ៉ាង ទៀតនៅតាមសាលាបឋមសិក្សានិងអនុវិទ្យាល័យមួយ

ចំនួនខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ ផ្ទុយទៅវិញសាលាមួយចំនួន មានការលើសគ្រូបង្រៀនទៅវិញ **(ក្រសួងអប់រំ យុវជន និងកីឡា,បំណិនវិជ្ជាជីវៈសម្រាប់បំប៉ននាយកសាលាបឋមសិក្សានិងមធ្យមសិក្សា,២០១៦)**។

យោងតាមគោលការណ៍កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ មន្ទីរអប់រំយុវជន និងកីឡារាជធានី/ខេត្ត ត្រូវធ្វើសុពលភាពចំនួយសិស្ស គ្រូ ពិនិត្យ និងតាមដានសាលាខ្វះ និងលើសគ្រូបង្រៀនជារៀងរាល់ឆ្នាំ ដោយប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ គ្រូបង្រៀន និងនាយកសាលា គួរផ្លាស់ប្តូរទីកន្លែងធ្វើការក្នុងរាជធានី/ខេត្ត រៀងរាល់ ៥ ឆ្នាំម្តង។ ការពង្រាយគ្រូបង្រៀនចេញថ្មីត្រូវបញ្ជូនទៅដល់កន្លែងដែលបានជ្រើសរើសប៉ុស្តិ៍ជាមុនហើយបម្រើការងារនៅទីនោះយ៉ាងតិច ៥ឆ្នាំតំបន់វាលរាប និង ៣ឆ្នាំតំបន់ជួបការលំបាក និងដាច់ស្រយាល។ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ ត្រូវបានផ្តល់សិទ្ធសម្រេចជូនប្រធានអង្គភាព/នាយកសាលារៀន ក្នុងការទទួល ឬមិនទទួលបុគ្គលិកអប់រំផ្លាស់ចូល និងសិទ្ធសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យផ្លាស់ ឬផ្ទេរក្របខណ្ឌចេញ ប្រធានអង្គភាព/នាយកសាលាត្រូវធានា ឱ្យបានច្បាស់ក្នុងការប្រគល់ភារកិច្ច ឬសេវាបង្រៀនជូនបុគ្គលិកអប់រំ ដែលផ្លាស់ចូល ឬបែងចែកថ្មី។ អង្គភាព និងសាលារៀននីមួយៗ ត្រូវធ្វើការវិភាគ និងព្យាករពីតម្រូវការធនធានមនុស្ស តាមប្រភេទក្របខណ្ឌ និងមុខជំនាញឯកទេសឱ្យបានច្បាស់លាស់ មុននឹងលើកសំណើសុំគ្រូបង្រៀន/បុគ្គលិអប់រំបន្ថែម(ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៨)។

យោងតាមលិខិតលេខ ៥៣ អយក.សណន សេចក្តីណែនាំ ស្តីពី ការគ្រប់គ្រងគ្រូបង្រៀន គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចេញរបស់បុគ្គលិក/គ្រូបង្រៀន ដើម្បីធានាថា ការសុំផ្លាស់ចេញមិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាបច្ចុប្បន្ន និងពេលអនាគត។

អនុវត្តតាមសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពី ការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើស ត្រូវទៅបម្រើនៅទីនោះ ត្រូវបញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច បើគ្រូបង្រៀនចេញថ្មីដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសមាន នឹងត្រូវស្នើផ្អាកបៀវត្ស ឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។ បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ និងលើកទឹក

ចិត្តនិងផ្តល់ការឧបត្ថម្ភផ្សេងៗ ដល់គ្រូបង្រៀនដែលទៅបង្រៀននៅសាលាខ្វះគ្រូ។ចំពោះសិស្សថ្នាក់ទី ១ ទី២ និងទី៣ លើសពី ៥០នាក់ ទើបអនុញ្ញាតឱ្យបំបែកជាពីរថ្នាក់ និងចំនួនសិស្សថ្នាក់ទី៤ ទី៥ ទី៦លើសពី ៥៥នាក់ ទើបអនុញ្ញាតឱ្យបំបែកជាពីរថ្នាក់ មិនអនុញ្ញាតឱ្យរៀបចំបង្រៀនពីរថ្នាក់ពីរពេល ចំពោះគ្រឹះស្ថានបឋមសិក្សាណាដែលមានចំនួនសិស្សតិចមិនស្របតាមនិយាមកំណត់ ហើយស្ថិតក្នុងស្ថានភាពដែលតម្រូវឱ្យបង្រៀនថ្នាក់គួប ( **អនុក្រឹតលេខ៣០៩ អនក្រ.បក ចុះថ្ងៃទី៣០ ធ្នូ ២០១៤ ស្តីពីការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ**)។ ចំពោះមត្តេយ្យសិក្សា និងបឋមសិក្សាគ្រូត្រូវបង្រៀនម៉ោង ទ្រឹស្តី២០ម៉ោងក្នុងមួយសប្តាហ៍ គ្រូអនុវិទ្យាល័យត្រូវបង្រៀន ១៨ម៉ោងក្នុងមួយសប្តាហ៍ គ្រូវិទ្យាល័យត្រូវបង្រៀន ១៦ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត ៤៨ម៉ោងក្នុងមួយខែ បើមន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត ៣២ម៉ោងក្នុងមួយខែ(**អនុក្រឹតលេខ១០ អនក្រ.បកស្តីពី ការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែមនិងប្រាក់ម៉ោងបន្ថែម សម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ**)។ចំពោះគ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវកាត់បន្ថយការប្រើគ្រូបង្រៀនថ្នាក់គួប លុបបំបាត់ការបង្រៀនថ្នាក់គួបបីកម្រិតថ្នាក់ និងអធិការកិច្ចលទ្ធផលនៃការបង្រៀនថ្នាក់គួប កាត់បន្ថយការប្រើគ្រូបង្រៀនពីរវេនការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាគួរផ្តល់អាទិភាពដល់គ្រូចូលនិវត្តន៍ដែលមានសមត្ថភាព និងស្ម័គ្រចិត្តបន្តបង្រៀន(**សេចក្តីណែនាំលេខ ៤៩៨ មស.សណន ចុះថ្ងៃទី១៩ កុម្ភៈ២០១៥ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួបនិងគ្រូបង្រៀនជាប់កិច្ចសន្យានៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ**)។គ្រូបង្រៀនម្នាក់បង្រៀនសិស្សមួយថ្នាក់ ហើយសិស្សមួយថ្នាក់យ៉ាងច្រើន ៥០នាក់សម្រាប់បឋមសិក្សា សម្រាប់មធ្យមសិក្សាបឋមភូមិវិញសិស្សមួយថ្នាក់យ៉ាងច្រើន ៥០នាក់ ហើយគ្រូបង្រៀន១៨ម៉ោងក្នុងមួយសប្តាហ៍ បើទទួលបន្ទុកថ្នាក់បង្រៀន ១៥ម៉ោងក្នុងមួយសប្តាហ៍ ក្នុងករណីបង្រៀនមិនគ្រប់ម៉ោងកំណត់មុខវិជ្ជាណាមួយមន្ត្រីអប់រំនោះត្រូវបង្រៀនមុខវិជ្ជាផ្សេងៗ ឬត្រូវបង្រៀននៅភូមិសិក្សាខ្ពស់ជាង ឬទាបជាងឱ្យគ្រប់ម៉ោងកំណត់(**សេចក្តីណែនាំលេខ ២៥៦ អយក.សណន ចុះថ្ងៃទី ២៩ មករា ២០០២**

**ស្តីពីការកំណត់និយាមនិងប្រើប្រាស់មន្ត្រីរាជការសម្រាប់មត្តេយ្យសិក្សា បឋមសិក្សាមធ្យមសិក្សាចំណេះទូទៅនិងសាលាគរុកោសល្យ**)។ គ្រូបង្រៀនម្នាក់បង្រៀនក្នុងថ្នាក់១៨ម៉ោងក្នុងមួយសប្តាហ៍សម្រាប់មត្តេយ្យសិក្សា បង្រៀនក្នុងថ្នាក់ ២៥ម៉ោងក្នុងមួយសប្តាហ៍សម្រាប់បឋមសិក្សា បង្រៀនក្នុងថ្នាក់ ១៨ ម៉ោងក្នុងមួយសប្តាហ៍សម្រាប់មធ្យមសិក្សាបឋមភូមិ បង្រៀនក្នុងថ្នាក់ ១៦ម៉ោងក្នុងមួយសប្តាហ៍សម្រាប់មធ្យមសិក្សាទុតិយភូមិផលធៀប សិស្ស-ថ្នាក់ ២៥នាក់ សម្រាប់មត្តេយ្យសិក្សា ផលធៀប សិស្ស-ថ្នាក់ ៤០-៥០នាក់ សម្រាប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាបឋមភូមិ (**សេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើបុគ្គលិកអប់រំ**)។

ការកើនឡើងចំនួនកុមារដល់អាយុចូលរៀន រហូតមកដល់ពេលថ្មីៗនេះ ដើម្បីកាត់បន្ថយការគ្រួតថ្នាក់ច្រើននៅថ្នាក់ទី១ ក្រសួងអប់រំ យុវជន និងកីឡា មានគោលការណ៍ឱ្យកុមារចូលរៀនត្រឹមតែអាយុ ៣ឆ្នាំ ឬ៧២ខែនៅថ្នាក់មត្តេយ្យដំបូង ហើយពីមួយឆ្នាំទៅមួយឆ្នាំកុមារចុះឈ្មោះចូលរៀនមានការកើនឡើង ជាលំដាប់ដូច្នេះ ហើយទើបធ្វើឱ្យសាលារៀន មានតម្រូវការយ៉ាងច្រើននូវបន្ទប់សិក្សា ក៏ដូចជាតម្រូវការគ្រូបង្រៀនដែលមានគុណវុឌ្ឍិ។

ការបង្កើតសាលាថ្មីៗទាំងផ្នែកបឋមសិក្សា និងអនុវិទ្យាល័យ ដោយមិនបានគិតទៅលើចំនួនសិស្សថ្នាក់តាមនិយាម និងតម្រូវការគ្រូបង្រៀនឱ្យបានច្បាស់លាស់ ។ ការជ្រើសរើសគ្រូដែលមានគុណវុឌ្ឍិដោយសាលានីមួយៗ ចំនួនមិនបានធ្វើពីចំណោលតម្រូវការគ្រូបង្រៀនឱ្យបានច្បាស់លាស់ ដោយមិនបានសិក្សាលំអិតទៅលើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ និងកត្តាសេដ្ឋកិច្ច នៅតំបន់សាលាមួយចំនួននោះ។ ការជ្រើសរើសនិងបណ្តុះបណ្តាលគ្រូ ជារៀងរាល់ឆ្នាំក្រសួងមុខងារសាធារណៈបានកំណត់ចំនួនគ្រូថ្មីឱ្យក្រសួងអប់រំ ជ្រើសរើសដោយជំនួសតែគ្រូចូលនិវត្តន៍ គ្រូដែលស្លាប់ គ្រូបោះបង់ គ្រូផ្ទេរចេញពីក្របខណ្ឌ ហេតុនេះហើយធ្វើឱ្យតម្រូវការគ្រូថ្មីដែលមានគុណវុឌ្ឍិនៅតែខ្វះជារៀងរាល់ឆ្នាំ។ ការពង្រាយគ្រូបង្រៀនមិនមានតម្លាភាព ទៅលើកត្តាជាច្រើនដូចជាក្របខណ្ឌច្បាប់មិនច្បាស់លាស់ ហើយមិនទាន់បានយកមកអនុវត្តឱ្យបានត្រឹមត្រូវ ខ្វះឧបករណ៍គ្រប់គ្រង

ដោយមិនដឹងច្បាស់ពីចំនួនគ្រូ សិស្ស នៅតាមសាលានីមួយៗដោយពឹងតែទៅលើរបាយការណ៍។ នាយកសាលាមិនបានទទួលវគ្គបណ្តុះបណ្តាលផ្នែកគ្រប់គ្រង ហើយការផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តផ្សេងៗមិនបានទូលំទូលាយ។ លោកគ្រូ អ្នកគ្រូចូលចិត្តតែទីប្រជុំជន ហើយអ្នកគ្រូប្រកែកមិនទទួលយកប៉ុស្តិ៍នៅជនបទ ឬតំបន់ដាច់ស្រយាល និងមានការធ្វើអន្តរាគមន៍ពីអ្នកមានអំណាចចំពោះលោកគ្រូ អ្នកគ្រូមួយចំនួនដែលធ្វើឱ្យការបែងចែកគ្រូបង្រៀនមិនស្របទៅតាមនិយាមដែលបានកំណត់ហើយលោកគ្រូ អ្នកគ្រូ មួយចំនួនផ្ទេរតាមសហព័ទ្ធទៅរកកន្លែងល្អ ។ លក្ខខ័ណ្ឌការងារ ការគ្រប់គ្រង ការឱ្យតម្លៃពីសង្គមនៅមានកម្រិត នាយកសាលាមិនបានបង្កើត បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងបុគ្គលិកក្នុងអង្គភាព ប្រធានក្រុមបច្ចេកទេសមិនបានផ្សព្វផ្សាយបន្តនូវចំណេះដឹងថ្មីៗដែលទើបទទួលបានពីវគ្គបណ្តុះបណ្តាលនានាទៅកាន់សមាជិកក្រុមរបស់ខ្លួន។ខ្វះការលើកទឹកចិត្តពីនាយកសាលា និងភាគីពាក់ព័ន្ធចំពោះគ្រូបង្រៀនដែលទើបនិងចេញថ្មីមកពីឆ្ងាយ ដោយមិនបានផ្តល់កន្លែងស្នាក់នៅសមរម្យ ការការពារសុវត្ថិភាព និងឧបត្ថម្ភសម្ភារ ផ្សេងៗពិសេសខ្វះវិធីសាស្ត្រទាក់ទាញរក្សាគ្រូបង្រៀនទុក។

បញ្ហាបរិមាណ និងគុណភាពក៏ជាមូលដ្ឋានសំខាន់មួយដែលត្រូវយកចិត្តទុកដាក់នៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យផងដែរ។ ប្រសិនបើយើងពិនិត្យទៅលើសូចនាករផលធៀបសិស្សគ្រូ ឬសិស្សថ្នាក់ ហាក់បីដូចជាមិនមានបញ្ហានោះទេក្នុងក្របខណ្ឌទូទាំងប្រទេស ព្រោះតាមស្ថិតិនៅគ្រប់កម្រិតភូមិសិក្សាមានសិស្សនិស្សិតប្រមាណ ៣ លានប្រាំសែននាក់រីឯបុគ្គលិកបង្រៀនមានជាងដប់មុឺននាក់ (សន្និបាតអប់រំឆ្នាំ២០១៦-២០១៧)។ ម្យ៉ាងវិញទៀតបើពិនិត្យលើ សូចនាករអត្រាប្រើប្រាស់គ្រូបង្រៀន (R2) នៅមានគម្លាតធំនៅឡើយ ។ បញ្ហាផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀនដែលស្មើឡើងពីមូលដ្ឋាន ក៏មិនទាន់ច្បាស់លាស់តាមលក្ខណៈជាក់ស្តែងដោយសារតែការបំប៉ោង ឬបន្ថយទិន្នន័យក្នុងការស្នើសុំ និងផ្តល់ឱ្យដែលពេលខ្លះខុសមុខវិជ្ជាឯកទេសដែលត្រូវការ ។ ដូចគ្នានេះដែរវិធីគណនាតម្រូវការគ្រូនៅបឋមសិក្សានិងអនុវិទ្យាល័យមិនទាន់ឯកភាពគ្នា ឬមិនទាន់មានរូបមន្តច្បាស់លាស់នៅឡើយ។ ម្យ៉ាងវិញទៀតការស្នើសុំ និងការផ្តល់គ្រូបង្រៀនមិនទាន់ស្របតាម

តម្រូវការជាហេតុនាំទៅដល់ការខ្វះគ្រូឬលើសគ្រូតាមមុខវិជ្ជាឯកទេស។មុខវិជ្ជាខ្វះនៅតែខ្វះ(ប៉ុស្តិ៍ទំនេរ) ហើយមុខវិជ្ជាលើសនៅតែបន្តលើសដដែល។ កង្វះខាតប្រព័ន្ធព័ត៌មានវិទ្យា ផែនទីសាលា អត្រាវិចវិល អត្រាគ្រូវិលចូលក្នុងប្រព័ន្ធវិញ អត្រាគ្រូបង្រៀនចូលនិវត្តន៍ អត្រាកំណើនសិស្សក្នុងតំបន់ និងបទប្បញ្ញត្តិមិនសមស្របធ្វើឱ្យមានបញ្ហាលើស ឬខ្វះគ្រូបង្រៀនទៅតាមតំបន់។ ការរៀបចំផែនការរយៈពេលមធ្យមវែងនិងការរៀបចំផែនការតាមបែបបរិមាណអាចប៉ះពាល់ដល់តម្រូវការលើ កម្មវិធីគោលនយោបាយអប់រំ និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ ការព្យាករណ៍តម្រូវការគ្រូតាមកម្មវិធីធ្វើចំណោលក៏ជាគន្លឹះ និងដំណោះស្រាយសមហេតុផលមួយក្នុងការដឹងពី តម្រូវការគ្រូរយៈពេលវែង។ក្រមសីលធម៌ក្នុងការអនុវត្តការងារ សមត្ថភាពមន្ត្រីគ្រប់គ្រងពុំបានទទួល ការបណ្តុះបណ្តាលស្តីពីជំនាញគ្រប់គ្រងធនធានមនុស្សបញ្ហាអវត្តមានគ្រូ កង្វះធនធានតួនាទី និងការទទួលខុសត្រូវត្រួតគ្នាទំនាក់ទំនងមិនច្បាស់លាស់លើការវាយតម្លៃនិងការសម្រេចចិត្តមិនដូចគ្នា នាំឱ្យការគ្រប់គ្រងគ្រូបង្រៀនមិនទាន់មានប្រសិទ្ធភាព ។ ចំណែកឯគ្រូបង្រៀនជ្រើសយកតែប៉ុស្តិ៍នៅទីក្រុង ឬ ទីប្រជុំជនការផ្លាស់ប្តូរតាមសហព័ទ្ធជាពិសេសនៅពេលដែលលក្ខខណ្ឌរស់នៅរបស់គ្រូបង្រៀន និងការលើកទឹកចិត្តគ្រូបង្រៀននៅមានកម្រិត ដោយប្រាក់ខែនៅទាបហើយគ្រូស្រីជាទូទៅមិនជ្រើសរើសយកប៉ុស្តិ៍នៅជនបទក៏ជាបញ្ហាប្រឈមផងដែរ ។ ទន្ទឹមពេលជាមួយគ្នានេះក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតកម្មវិធីវិក្រិតការជាបន្តបន្ទាប់ដើម្បីពង្រឹងសមត្ថភាព មន្ត្រីគ្រប់គ្រងអប់រំនៅតាមបណ្តាបឋមសិក្សានិងអនុវិទ្យាល័យនានាក្នុងទូទាំងប្រទេស ។ ប៉ុន្តែបើទោះបីជាមានការធ្វើវិក្រិតការយ៉ាងដូច្នេះក្តី សមត្ថភាពអ្នកគ្រប់គ្រងទាំងនោះនៅមានកម្រិតនិងពុំទាន់ឆ្លើយតបទៅនឹងការកែទម្រង់របស់ក្រសួងនៅឡើយជាហេតុបណ្តាលឱ្យស្ថានភាពនៃការប្រើប្រាស់និងបែងចែកគ្រូបង្រៀនអាចជួបប្រទះនូវបញ្ហាប្រឈម ហើយក៏ជាកត្តាមួយដែលធ្វើឱ្យគុណភាពនៃការអប់រំធ្លាក់ចុះផងដែរ។

កាលពីថ្ងៃទី ៩ ខែសីហា ឆ្នាំ២០១៩ ក្រសួងអប់រំបានចេញសេចក្តីណែនាំលេខ ២០ អយក.សណន ស្តីពី និយាមប្រើប្រាស់បុគ្គលិកអប់រំ ដើម្បីធ្វើឱ្យប្រសើឡើងលើការគ្រប់គ្រង និងការបែងចែកភារកិច្ចជូនបុគ្គ

លិកអប់រំ ដែលកំពុងបម្រើការងារនៅតាមអង្គភាពរដ្ឋបាល និងនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងដើម្បីផ្តល់សេវាអប់រំ ប្រកបដោយគុណភាព ស្របទៅនិងបរិបទនៃការអប់រំបច្ចុប្បន្ន ក្រសួងអប់រំយុវជននិងកីឡា បានពិនិត្យ កែសម្រួលឡើងវិញសេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ និងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំសិក្សា ២០១៨-២០១៩តទៅ។

យ៉ាងណាមិញចំពោះខេត្តព្រះសីហនុនៅមិនទាន់បានអនុវត្តតាមនិយាមថ្មីនេះ ឱ្យមានការឯកភាពគ្នានៅឡើយដោយនៅសាលារៀនមួយចំនួននៅតែអនុវត្តតាមនិយាមចាស់គឺនិយាមលេខ ២៥៦ អយក.សណន ចុះថ្ងៃទី ២៩ មករាឆ្នាំ២០០២ ស្តីពី ការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សាមធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ ។

ចំណែកឯនីតិវិធីនៃការបែងចែកគ្រូវិញ នៅមិនទាន់មានតម្លាភាព ដោយផ្តល់ឱកាសឱ្យគ្រូជាច្រើនប្រមូលផ្តុំនៅសាលាទីរួមខេត្ត និងទីប្រជុំជន អនុញ្ញាតឱ្យគ្រូផ្ទេរចេញពីសាលាខ្វះគ្រូទៅសាលាលើសគ្រូទៅវិញ ផ្តល់គ្រូឯកទេសទៅតាមសាលាមិនស្របទៅតាមការស្នើសុំ សាលាខ្លះគ្រូលើសហើយនៅតែផ្តល់ឱ្យ។

រហូតមកដល់ពេលនេះ នៅមិនទាន់មានការសិក្សាណាមួយបង្ហាញពីស្ថានភាពនៃការប្រើប្រាស់គ្រូនៅបឋមសិក្សា និងអនុវិទ្យាល័យនៅឡើយ។

ដូច្នេះហើយទើបអ្នកសិក្សា លើកយកប្រធានបទ «**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋម និងអនុវិទ្យាល័យ**» ក្នុងខេត្តព្រះសីហនុមកធ្វើការសិក្សាស្រាវជ្រាវ ។

## ១.២ លំនាំបញ្ហានៃការស្រាវជ្រាវ

ទោះបីជាមានសេចក្តីណែនាំ ក៏ដូចជាសរាចរផ្សេងៗបានផ្តល់ជូនសម្រាប់ធ្វើការអនុវត្តទៅតាមកម្រិតមន្ទីរ ឬកម្រិតសាលាយ៉ាងណាក៏ដោយ ក៏ការបែងចែងគ្រូនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនានា នៅក្នុងខេត្តព្រះសីហនុ នៅមានភាពមិនប្រក្រតីមួយចំនួនដែលក្នុងនោះមានកត្តាមួយចំនួនដែលកំពុងជួប្រទះ ដូចជាគ្រូបង្រៀនខុសឯកទេស គ្រូបង្រៀនមិនគ្រប់ម៉ោងតាមនិយាមកំណត់ គ្រូបង្រៀនលើសនៅសាលាទី

ប្រជុំជន ខ្វះគ្រូបង្រៀននៅសាលារៀនជនបទ និងសាលារៀនតំបន់ដាច់ស្រយាល ចំណែកឯការបែងចែកសិស្សថ្នាក់វិញ មិនស្របទៅតាមនិយាមដែលបានកំណត់ដោយ ក្រសួងអប់រំ យុវជន និងកីឡាកត្តាទាំងអស់នេះហើយដែលតម្រូវឱ្យភាគីពាក់ព័ន្ធគួរតែមានវិធានការមួយចំនួនសម្រាប់ធ្វើការកែលម្អនិងពង្រឹងបន្ថែមដើម្បីគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ។

## ១.៣ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីចូលរួមចំណែកកែលម្អគុណភាពអប់រំនៅកម្ពុជាឱ្យមានការរីកចម្រើនឡើង យើងខ្ញុំជាគរុសិស្សរៀននៅវិទ្យាស្ថានជាតិអប់រំបានយកប្រធានបទ៖ « **ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យនានាក្នុងខេត្តព្រះសីហនុ** » ដើម្បីស្វែងរកឱ្យឃើញការបែងចែកភារកិច្ច និងម៉ោងបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗ ត្រឹមត្រូវតាមឯកទេសស្របតាមនិយាមគរុកោសល្យរបស់ក្រសួងអប់រំ យុវជននិងកីឡាចង់បានហើយឬនៅម្យ៉ាងទៀតការសិក្សាស្រាវជ្រាវចង់ស្វែងរកឱ្យឃើញបន្ថែមទៀតនូវអ្វីដែលជាបញ្ហាប្រឈមជាក់ស្តែង ដែលកំពុងកើតមានឡើងនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនានាក្នុងខេត្តព្រះសីហនុ។

## ១.៤ សំណួរស្រាវជ្រាវ

ដោយសារមានភាពមិនប្រក្រតីក្នុងការបែងចែកធនធានអប់រំមិនមានតម្លាភា និងមិនទាន់ត្រឹមត្រូវតាមស្តង់ដារដែលបានកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ទើបការស្រាវជ្រាវនេះមានសំណួរចំនួនពីរសម្រាប់ធ្វើការស្រាវជ្រាលើបញ្ហានេះដូចខាងក្រោម៖

១. តើស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សានិងអនុវិទ្យាល័យក្នុង ខេត្តព្រះសីហនុមានការបែងចែកយ៉ាងដូចម្តេច ?

២. តើគណៈគ្រប់គ្រងសាលារៀនមានទស្សនៈយល់ឃើញយ៉ាងដូចម្តេច លើការដោះស្រាយបញ្ហានានាទាក់ទងនិងការប្រើប្រាស់គ្រូបង្រៀនក្នុងខេត្តព្រះសីហនុ ?

## ១.៥ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងនៃ(១)រកឱ្យឃើញពី**ស្ថានភាពបច្ចុប្បន្នក្នុងការប្រើប្រាស់ គ្រូបង្រៀន នៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ**(២)ស្វែងយល់ពីទស្សនយល់ឃើញ របស់គណៈគ្រប់គ្រងសាលារៀន លើការដោះស្រាយបញ្ហានានាទាក់ទងទៅនឹងការប្រើប្រាស់គ្រូបង្រៀនក្នុង ខេត្តព្រះសីហនុ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី «**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន នៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ**»នឹងបង្ហាញពីសារៈសំខាន់ដែលធ្វើឱ្យយើងកំណត់បានពីប្រសិទ្ធភាពក្នុងការជ្រើសរើស និងបែងចែកគ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ។ ម្យ៉ាងវិញទៀតវាបង្ហាញពីប្រសិទ្ធភាព នៃការលើកទឹកចិត្តគ្រូបង្រៀបឋមសិក្សា និងគ្រូមូលដ្ឋានដើម្បីឱ្យការបង្រៀនទទួលបានគុណភាព។ លទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនេះនឹងក្លាយជាព័ត៌មានដ៏មានអត្ថប្រយោជន៍ សម្រាប់ជាជំនួយក្នុងការចែករំលែកនូវបទពិសោធន៍ល្អៗ ដែលបានរកឃើញនៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យទៅដល់គ្រឹះស្ថានសិក្សាដ៏ទៃទៀត។

ការសិក្សានេះក៏ជាទុនមួយសម្រាប់អ្នកស្រាវជ្រាវ និងអ្នកសិក្សាជំនាន់ក្រោយអាចសិក្សាបន្តឲ្យបានកាន់តែមានលក្ខណៈលម្អិត ស៊ីជម្រៅ ដើម្បីជាប្រយោជន៍ក្នុងការចូលរួមផ្តល់បទពិសោធន៍ និងព័ត៌មានល្អៗ សម្រាប់គណៈគ្រប់សាលារៀន។

## ១.៧ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៧.១ វិសាលភាពនៃការស្រាវជ្រាវ

ដើម្បីឲ្យការសិក្សាស្រាវជ្រាវដំណើរការទៅបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយទៅលើ **ប្រធានបទ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន នៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ** អ្នកស្រាវជ្រាវបានយកសាលាបឋមសិក្សានិងអនុវិទ្យាល័យទាំងអស់ក្នុងខេត្តព្រះសីហនុតែប៉ុណ្ណោះដើម្បីមកធ្វើការស្រាវជ្រាវ។

### ១.៧.២ ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងនៅក្នុង សាលាបឋមសិក្សាចំនួន៧២ អនុវិទ្យាល័យចំនួន១៨ វិទ្យាល័យដែលមានអនុវិទ្យាល័យនៅជាមួយចំនួន៨ ដែលកំពុងដំណើរការអនុវត្តភារកិច្ចនៅក្នុងខេត្តព្រះសីហនុ។ ការស្រាវជ្រាវនេះផ្តោតលើគោលការណ៍បួនសំខាន់ៗគឺៈ (១)ចំនួនសិស្ស ចំនួនថ្នាក់ សាលាបឋសិក្សានិងអនុវិទ្យាល័យ (២)ចំនួនបន្ទប់ដែលសាលាមានជាក់ស្តែង (៣)ចំនួនគ្រូបឋមសិក្សា និងអនុវិទ្យាល័យដែលមានគុណវុឌ្ឍិ(៤)ចំនួនគ្រូដែលកំពុងបង្រៀនជាក់ស្តែងផ្នែកបឋមសិក្សា និងអនុវិទ្យាល័យ។

## ១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវនេះទទួលបានលទ្ធផលល្អអ្នកស្រាវជ្រាវ បានរៀបចំរចនាសម្ព័ន្ធនៃការស្រាវជ្រាវដែលបែងចែកជា ៥ជំពូកធំៗដូចខាងក្រោមៈ

**ជំពូកទី១សេចក្តីផ្តើមៈ** នៅក្នុងជំពូកនេះបង្ហាញពី ប្រវត្តិនៃការស្រាវជ្រាវបញ្ហានៃការស្រាវជ្រាវចំណោទបញ្ហានៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សារៈប្រយោជន៍នៃការស្រាវជ្រាវដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២រំលឹកទ្រឹស្តីៈ** នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្តីផ្សេងៗ ពីអ្នកនិពន្ធមុនដែលពាក់ព័ន្ធទៅនិងប្រធានបទដើម្បីធ្វើជាអំណះអំណាង និងជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីក្នុងនិក្ខេបបទនេះ ។

**ជំពូកទី៣វិធីសាស្ត្រស្រាវជ្រាវៈ** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវដែនកំណត់ និងវិសាលភាព ការជ្រើសរើសសំណាកឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ ទាំងវិធីសាស្ត្រវិភាទិន្នន័យ និងបង្ហាញពីទំនាក់ទំនងរវាងចំណុចនីមួយៗដែលបានចោទក្នុងចំណោទបញ្ហាទៅនិងប្រធានបទ។

**ជំពូកទី៤លទ្ធផលស្រាវជ្រាវៈ** លទ្ធផលសិក្សានៅក្នុងជំពូកនេះ រួមមានអ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យជាក់ស្តែងដែលប្រមូលបានមកវិភាគនឹងបកស្រាយយ៉ាងលម្អិតដើម្បីរកឱ្យឃើញភាពអវិជ្ជមាន (បញ្ហា

ប្រឈម )ដែលចោទសួរទាំងអស់ក្នុងចំណោទបញ្ហាស្តីពីស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សានិងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ ។

**ជំពូកទី៥សេចក្តីសន្និដ្ឋាន និង សំណូមពរ៖** ជាផ្នែកមួយសំខាន់ណាស់ដែលអ្នកស្រាវជ្រាវ ត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងសំណូមពរមួយចំនួនក្នុងគោលបំណងចូលរួមចំណែកធ្វើអោយការអនុវត្តបំណែងចែកភារកិច្ចបុគ្គលិកនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុអោយកាន់តែប្រសើរឡើងថែមទៀត និងដើម្បីបង្កើនសាមគ្គីភាព និងទំនាក់ទំនងល្អថែមទៀតរវាងគណៈគ្រប់គ្រង និងសមាជិកក្នុងអង្គភាពរបស់ខ្លួន ។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

ការបែងចែកធនធានអប់រំនៅក្នុងប្រទេសកម្ពុជាមានការផ្លាស់ប្តូរទៅតាមបរិបទនៃប្រទេស និងតាមដំណាក់កាលនីមួយៗ។ ពីឆ្នាំ ២០១៨ រហូតមកដល់ឆ្នាំ២០២០ ការបែងចែកធនធានអប់រំគឺ គ្រូម្នាក់បង្រៀនសិស្ស១ថ្នាក់ ហើយសិស្សមួយថ្នាក់មានចន្លោះពី ៤០ ទៅ ៥០ នាក់ សិស្សរៀន ២៥ ម៉ោងក្នុងមួយសប្តាហ៍ចំពោះបឋមសិក្សា ផ្នែកអនុវិទ្យាល័យវិញគ្រូបង្រៀនសុទ្ធសាធ ១៨ ម៉ោងក្នុងមួយសប្តាហ៍ បើទទួលបន្ទុកថ្នាក់ផងបង្រៀនតែ១៤ ម៉ោងក្នុងមួយសប្តាហ៍ បើគ្រូទទួលបន្ទុកថ្នាក់ហើយជាប្រធានក្រុមបច្ចេកទេសទៀតគាត់បង្រៀនតែ១២ម៉ោងក្នុងមួយសប្តាហ៍ ចំណែកឯសិស្សវិញក្នុងមួយថ្នាក់មានចន្លោះពី ៤០ ទៅ៥០ នាក់ (និយាមលេខ ២០ចុះថ្ងៃទី០៩ ខែសីហា ២០១៨)។ ចាប់តាំងពីឆ្នាំ២០០២ រហូតមកដល់ឆ្នាំ២០១៧ ការបែងចែកធនធានអប់រំគឺ គ្រូម្នាក់បង្រៀនសិស្ស១ថ្នាក់ ដែលមានសិស្សចំនួន ៥០នាក់ផ្នែក បឋមសិក្សាផ្នែកអនុវិទ្យាល័យសិស្សមួយថ្នាក់មានចំនួន ៥០នាក់ គ្រូម្នាក់បង្រៀន១៨ម៉ោងក្នុងមួយសប្តាហ៍បើទទួលបន្ទុកថ្នាក់បង្រៀនតែ១៥ម៉ោងក្នុងមួយសប្តាហ៍ករណីបង្រៀនមិនគ្រប់ម៉ោងកំណត់ខាងលើក្នុងមុខវិជ្ជាណាមួយ មន្ត្រីអប់រំនោះត្រូវបង្រៀនមុខវិជ្ជាផ្សេងឬត្រូវបង្រៀននៅភូមិសិក្សាខ្ពស់ជាងឬទាបជាងឱ្យគ្រប់ម៉ោងកំណត់និងការបង្រៀនម៉ោងបន្ថែមបានលុះត្រាតែមន្ត្រីអប់រំនោះបានបង្រៀនគ្រប់ម៉ោងកំណត់របស់ក្របខណ្ឌខ្លួនសិន (និយាមលេខ ២៥៦ ចុះថ្ងៃទី២៩ មករា ២០០២)។ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០១ គ្រូបង្រៀនដែលទទួលបានការ បណ្តុះបណ្តាលគរុកោសល្យហើយត្រូវបានបញ្ជូនកាន់សាលាដែលខ្វះគ្រូខ្លាំងដោយគ្រូបង្រៀនម្នាក់អាចបង្រៀន ពីរមុខ ទៅបីមុខវិជ្ជា ដែលធ្វើឱ្យលទ្ធផលនៃការសិក្សារបស់សិស្សនៅមានកម្រិតចំពោះសាលាបឋមសិក្សាវិញបង្កើតឱ្យមានថ្នាក់គួប ថ្នាក់ពីរវេនដោយសារតែខ្វះគ្រូបង្រៀន។ ពីឆ្នាំ ១៩៨៦ មកដល់ឆ្នាំ ១៩៩៥ ប្រព័ន្ធអប់រំ ៥-៣-៣ចំនួនឆ្នាំសិក្សា១១ឆ្នាំចាប់ផ្តើមមានការបង្កើតមជ្ឈមណ្ឌល គរុកោសល្យភូមិភាគដើម្បីបណ្តុះបណ្តាលគ្រូបឋសិក្សាទៅជាគ្រូមធ្យមសិក្សាបឋមភូមិតាមរូមន្ត៧+១សម្រាប់ខេត្តតំបន់វាលរាបនិង៣+១សម្រាប់ខេត្តជួបការលំបាក

និងតំបន់ដាច់ស្រយាល ដោយគ្រូម្នាក់បង្រៀន ១៨ម៉ោងក្នុង១សប្តាហ៍ ហើយវិធីសាស្ត្របង្រៀនតាមបែបគ្រូមជ្ឈមណ្ឌល។ បើគ្រូបង្រៀនលើសនិយាមកំណត់ ត្រូវគិតប្រាក់ម៉ោងបន្ថែមជូនគាត់។

ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៥ ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា ៤-៣-៣ ចំនួនឆ្នាំសិក្សា១០ឆ្នាំ មានតែគ្រូកម្រិតបឋមសិក្សាក្នុងដំណាក់កាលនេះក្រសួងជ្រើសរើសយកអ្នកស្ម័គ្រចិត្ត ដើម្បីឱ្យក្លាយជាគ្រូបង្រៀនដោយបណ្តុះបណ្តាលពួកគាត់មួយសប្តាហ៍ទៅបួនខែប៉ុណ្ណោះដោយបញ្ជូនគាត់ទៅបង្រៀនសិស្សក្នុងមួយថ្នាក់ៗ រាប់សិបនាក់ដោយមិនបានកំណត់តាមនិយាមច្បាស់លាស់ឡើយ។

## ២.២ គោលនយោបាយស្តីពីគ្រូបង្រៀន

ការអនុម័តគោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៣ គឺជាការចាប់ផ្តើមធ្វើកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាល និងការជ្រើសរើសគ្រូបង្រៀនមានរួមបញ្ចូលកម្មវិធី សកម្មភាពកាលបរិច្ឆេទនិងលទ្ធផលរំពឹងទុកព្រមទាំងការចំណាយថវិកាសម្រាប់អនុវត្តពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០២០ដើម្បីរៀបចំចក្ខុវិស័យសម្រាប់គោលនយោបាយវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជាមានដូចជា៖(**បង្រៀនដោយ ឯកឧត្តម បណ្ឌិត សៀង សុវណ្ណា, វិទ្យាស្ថានជាតិអប់រំ ២០២០**)

គោលនយោបាយទី១ គឺទាក់ទាញអ្នកមានសមត្ថភាពឱ្យចូលធ្វើជាគ្រូបង្រៀនដោយៈផ្តល់ផលប្រយោជន៍សង្គម និងហិរញ្ញវត្ថុ ដោយតម្លើងប្រាក់បៀវត្សរ៍ និងប្រយោជន៍ផ្សេងទៀតបើកទូលាយការជ្រើសរើសគ្រូ (អនុញ្ញាតឱ្យអ្នកមានបរិញ្ញាបត្រពីគ្រឹះស្ថានរដ្ឋ និងឯកជនទទួលបានអាជ្ញាប័ណ្ណអប់រំ) ផ្តល់ការបំប៉នគ្រូបង្រៀន ១២+២ដើម្បីក្លាយជាបរិញ្ញាបត្ររឹតបន្តឹងការជ្រើសរើសចូលបណ្តុះបណ្តាល(ប្រកួតប្រជែងចំណាត់ថ្នាក់ជាតិលែងធ្វើចំណាត់ថ្នាក់តាមខេត្ត)បេក្ខជនទទួលបាននិទ្ទេស A B C ប្រឡងថ្នាក់ទី១២ ជាប់ជាស្វ័យប្រវត្តិកែលម្អការប្រឡងចូល(១)ការប្រឡងគោរពគោលការណ៍ច្បាប់ តម្លាភាព យុត្តិធម៌(២)ប្រឡងសរសេរ(៣)សម្ភាសផ្ទាល់មាត់ (៤)កែប្រែគោលការណ៍កំណត់អាយុ (៥)តាមដានការបណ្តុះបណ្តាល។

គោលនយោបាយទី២គឺបណ្តុះបណ្តាលគ្រូបង្រៀនដោយៈកែទម្រង់កម្មវិធីបណ្តុះបណ្តាលគ្រូគ្រប់កម្រិតតាមរូបមន្ត ១២+៤ រៀបចំកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់+១ ក្លាយជា គ្រូវិទ្យាល័យ អនុវត្តកម្មវិធី

បណ្ដុះបណ្ដាលគ្រូបង្រៀន ផ្អែកតាមស្តង់ដា តាមរូបមន្ត ១២+៤ តាមភូមិភាគបង្កើនប្រសិទ្ធភាពកម្មសិក្សាមុនតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនប្រែក្លាយសាលាគរុកោសល្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀនបង្កើនគុណវុឌ្ឍិ និងបទពិសោធន៍បុគ្គលិកអប់រំមានសមត្ថភាពយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់។

គោលនយោបាយទី៣ ការគ្រប់គ្រងគ្រូបង្រៀន៖ធ្វើទំនើបកម្មផែនការតម្រូវការ និងផ្គត់ផ្គង់គ្រូបង្រៀនដោយបញ្ចូលទិន្នន័យពីប្រព័ន្ធ(EMIS,HRMIS..)ពង្រឹងការប្រើប្រាស់គ្រូបង្រៀនផ្អែកតាមនិយាម និងគោលការណ៍ប្រើប្រាស់បុគ្គលិកដើម្បីកែលម្អការអនុវត្តការពង្រាយគ្រូបង្រៀនលើកកម្ពស់ដំណើរការនិងនីតិវិធី នៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនមានស្នាដៃល្អសម្រាប់ជានានិរន្តរភាពគ្រឹះស្ថានសិក្សា ធ្វើប្រតិភូកម្មការជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមការកំណត់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់ គ្រប់គ្រងសាលា និងអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្ដីសម្រេចចិត្ត( ការជ្រើសរើស ការផ្ដល់រង្វាន់ ការពិន័យការផ្ទេរការវាយតម្លៃ វេទិកាសាធារណៈ ការប្រជុំ ការវាយតម្លៃសេវាមូលដ្ឋាន និងការបង្រៀនបំណិនជីវិតជាដើម )។

គោលនយោបាយទី៤ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន៖បណ្ដុះវប្បធម៌រៀនពេញមួយជីវិត ដោយចែករំលែកបទពិសោធន៍ជាមួយបណ្ដាញក្រុមអ្នកអប់រំ និងបង្កើនគុណវុឌ្ឍិគ្រូបង្រៀនឱ្យទទួលបានសញ្ញាបត្រតាមកម្មវិធីពន្លឿនអភិវឌ្ឍ និងអនុវត្តការងារក្រឹតការគ្រូបង្រៀន( ពង្រឹងចំណេះដឹងភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រ សម្រាប់គ្រូបង្រៀនថ្នាក់ទី៩ និង១២)បង្កើតប្រព័ន្ធវិក្រឹតការរៀបរយ ដោយអនុវត្តការងារវិក្រឹតការ(១)នៅនឹងកន្លែង(២)មិនរៀបរយតាមការចាំបាច់នៃវិស័យអប់រំ(៣)រៀបរយដែលមានប្រព័ន្ធកម្មវិធីត្រឹមត្រូវការបង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសឱ្យដល់កម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារអនុវត្តអាហារូបករណ៍ និងកម្មវិធីវិក្រឹតការពន្លឿនសម្រាប់គ្រូបង្រៀនទទួលបានបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១០០០ កន្លែងក្នុងមួយឆ្នាំបង្កើនប្រព័ន្ធក្រេឌីតដើម្បីរៀបចំឱ្យមានការឯកភាពគ្នាមួយលើរាល់ប្រភេទនៃវគ្គវិក្រឹតការសម្រាប់ទទួលបាននូវការលើកកម្ពស់គុណវុឌ្ឍិ និងផលប្រយោជន៍បន្ថែមបង្កើតកម្មវិធីសម្រាប់គ្រូឧទ្ទេសសាលាគរុកោសល្យក្នុងការចុះជួយបំប៉នសមត្ថភាពគ្រូ។

គោលនយោបាយទី៥ ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន៖ លើកកម្ពស់លក្ខណៈធ្វើការងារ និង

ការរស់នៅរបស់គ្រូបង្រៀន តាមរយៈការផ្តល់បៀវត្ស លាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ ទូទៅពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងលោកគ្រូបម្រើការងារនៅតំបន់ដាច់ស្រយាល និងជួបការលំបាក ទទួលស្គាល់ និងជូនរង្វាន់ដល់គ្រូមានស្នាដៃ(រក្សាគ្រូក្នុងប្រព័ន្ធ)រៀបចំគន្លងអាជីពគ្រូបង្រៀនរៀបចំបណ្តាញគាំទ្រជាប្រចាំ ( ក្លឹបសិក្សា សមាគមវិជ្ជាជីវៈ តាមមុខវិជ្ជាឯកទេស ) បង្កើតក្រុមបច្ចេកទេសក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ចុះជួយតាមមុខវិជ្ជា។

គោលនយោបាយទី៦ ពង្រឹងភាពជាអ្នកដឹកនាំសាលារៀនៈរៀបចំស្តង់ដានាយក និងសៀវភៅណែនាំការគ្រប់គ្រងសាលារៀនបណ្តុះបណ្តាលនាយកសាលាតាមស្តង់ដានាយកសាលាដោយផ្តល់ អាទិភាពដល់នារី បង្កើតក្រុមប្រឹក្សា សហគមន៍ នាយកសាលា និងបង្កើតយន្តការពង្រឹងការគាំទ្រនាយកការពារ និងលើកកម្ពស់សិទ្ធិគ្រូបង្រៀនកែលម្អលក្ខណៈជ្រើសរើស ការបណ្តុះបណ្តាល ការបំពេញការងារនិងផលប្រយោជន៍គ្រូឧទ្ទេស និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា។

គោលនយោបាយទី៧ ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃៈកែលម្អទិន្នន័យក្នុង ប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀនរៀបចំយន្តការពិនិត្យតាមដាន និងវាយតម្លៃការងារគ្រូបង្រៀនដោយផ្តោតលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និយាមប្រើប្រាស់ លក្ខណៈសម្បត្តិ និងគន្លងអាជីពគ្រូបង្រៀន ពង្រឹងការពិនិត្យ តាមដាននៅនឹងកន្លែង តាមរយៈអធិការកិច្ច ការផ្តល់សិទ្ធិពេញលេញដល់នាយកសាលាកំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើការសម្រេចចិត្តលើការគ្រប់គ្រង និងអភិវឌ្ឍអង្គភាព។

## ២.៣ តួនាទី និងភារកិច្ចនាយកសាលានៅកម្ពុជា

នាយកសាលាមានតួនាទីជាអាជ្ញាធរអប់រំ មន្ត្រីរដ្ឋបាល ទីប្រឹក្សាគរុកោសល្យ អធិការកិច្ចអចិន្ត្រៃយ៍ និងភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍ ( *MoEYS,ការគ្រប់គ្រង រដ្ឋបាល,២០០៩* ) ៖

នាយកសាលាមានតួនាទីជាអាជ្ញាធរអប់រំគឺនាយកសាលាជាប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំ យុវជន និងកីឡាប្រចាំភូមិសាស្ត្រសិក្សារបស់សាលានីមួយៗ ។ គាត់ជាអ្នកធានាទំនាក់ទំនងការងាររវាងសាលារៀន

ននិងថ្នាក់លើ ។ គាត់ជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទបញ្ញាសិក្សានិងអត្ថបទផ្លូវការទាំងឡាយនាយកសាលាដឹកនាំ គ្រប់សកម្មភាពទាំងឡាយក្នុងសាលារៀននិងធានាឱ្យបាននូវប្រសិទ្ធភាពតាមគោលដៅអប់រំដែលបានគ្រោងទុក នាយកសាលារៀនទទួលខុសត្រូវទាំងស្រុងចំពោះមុខសាលារៀន និងថ្នាក់លើនូវរាល់អ្វីដែលកើតមានក្នុងសមត្ថកិច្ចរបស់ខ្លួន។

នាយកសាលាជាមន្ត្រីរដ្ឋបាលគឺ នាយកសាលារៀនជាអ្នកណែនាំអនុវត្តរដ្ឋបាលសិក្សាទាំងអស់ ក្នុងសាលារៀន ធានាធ្វើឱ្យសម្រេចគោលដៅអប់រំ ដោយរិះរកគ្រប់មធ្យោបាយ និងវិធានការចាំបាច់ ដើម្បីឱ្យសកម្មភាពប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

នាយកជាទីប្រឹក្សាគរុកោសល្យក្នុងឋានៈជាគ្រូបង្រៀន និងជាគ្រូមានបទពិសោធន៍នាយកសាលារៀនមានសិទ្ធិអំណាចណែនាំគរុកោសល្យដល់គ្រូបង្រៀនក្រោមឱវាទនូវល្បិច និងគន្លឹះល្អៗ នៃការបង្រៀន ។ នាយកសាលារៀនអាចបំពេញភារកិច្ចនេះបានលុះត្រាណា ជានិច្ចកាលស្វ័យសិក្សា និងអភិវឌ្ឍសម្បទាចិត្តគរុកោសល្យគ្មានឈប់ឈរ ។ គ្រូបង្រៀនតែងផ្តល់កិត្តិយស និងគោរពនាយកសាលាណាដែលមានសម្បទាអាចធានាការរៀបចំគរុកោសល្យបានល្អ។

នាយកសាលាជាអធិការអចិន្ត្រៃយ៍គឺនាយកសាលារៀនមានសិទ្ធិត្រួតពិនិត្យ និងជួយកែលម្អសកម្មភាពអប់រំគ្រប់ផ្នែក ជាពិសេសសកម្មភាពបង្រៀន និងរៀន។

នាយកសាលារៀនជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍ដ៏សំខាន់ និងចាំបាច់នៃការអភិវឌ្ឍរបស់សហគមន៍ជាពិសេសអភិវឌ្ឍចិត្តគំនិត និងស្មារតី ។ នាយកសាលារៀនមានសិទ្ធិចូលរួមគ្រប់សកម្មភាពរបស់សហគមន៍ពីតួនាទី និងភារកិច្ចរបស់ « ការអប់រំសម្រាប់ទាំងអស់គ្នា និងទាំងអស់គ្នាសម្រាប់ការអប់រំ» ក្រៅពីនេះនាយកសាលាមានភារកិច្ចទទួលខុសត្រូវលើភារកិច្ចការងារមួយចំនួនដូចជា៖ ការងាររដ្ឋបាលរបស់សាលារៀនគ្រប់ប្រភេទសំដៅធ្វើឱ្យដំណើរការងារប្រចាំថ្ងៃការងារទំនាក់ទំនងមានទំនាក់ទំនងល្អទាំងផ្ទៃក្នុង និងផ្ទៃខាងក្រៅ។

## ២.៤ ភារកិច្ចអ្នកគ្រប់គ្រងអង្គភាព

អ្នកគ្រប់គ្រងបឋមសិក្សា និងអនុវិទ្យាល័យ គឺជាអ្នកទទួលខុសត្រូវអភិបាលកិច្ច ក្នុងការប្រើប្រាស់ធនធានរបស់អង្គភាពឱ្យសម្រេចគោលដៅ អ្នកគ្រប់គ្រងត្រូវមានចិត្តទូលាយ ទន់ភ្លន់តែហ្មត់ចត់ចំពោះការងារត្រូវចេះគិតគូរ ពិចារណា ស្តាប់មតិយោបល់ និងយុត្តិធម៌ចំពោះបុគ្គលិក ស្រឡាញ់សមាជិក និងអង្គភាព និយាយឱ្យពិរោះ ឱ្យបុគ្គលិកយល់ ត្រូវហ៊ានទទួលខុសត្រូវចំពោះភារកិច្ចរបស់ខ្លួន ធ្វើរឿងធំទៅជារឿងតូចហើយរឿងលំបាកទៅជាងាយស្រួលវិញ។ អាចនិយាយបានថាអ្នកគ្រប់គ្រងល្អត្រូវចេះលៃលក កែលម្អ ឬផ្លាស់ប្តូរដោយរិះរកនូវវិធីសាស្ត្រថ្មីៗនិងមានប្រសិទ្ធភាពសម្រាប់អង្គភាពទាំងមូល។

ជារួមជោគជ័យអាស្រ័យទៅលើការទទួលខុសត្រូវខ្ពស់ចំពោះស្ថាប័នេះ ឬអង្គភាព ការផ្លាស់ប្តូរ របៀបធ្វើការ កសាងឥរិយាបទរបស់អ្នកគ្រប់គ្រង និងជាពិសេសការអនុវត្តភារកិច្ចបានគ្រប់ជ្រុងជ្រោយដែលជាសំណូមពរចាំបាច់មិនអាចខ្វះបាន។ ហេតុនេះស្ថាប័ន ឬអង្គភាពដែលត្រូវមានការយល់ដឹងខ្ពស់ អំពីវិជានការការងាររបស់ខ្លួន។ ត្រូវផ្លាស់ប្តូរកែលម្អដោយរីកចម្រើនទៅអនាគតដោយក្លាហានទើបការទាក់ទាញមនុស្សគ្រប់រូបឱ្យធ្វើការដូចខ្លួន នោះចុងក្រោយសិស្សានុសិស្សដែល ជាកូនចៅប្រជាជននិងពិតជាបានទទួលលទ្ធផលល្អក្នុងការសិក្សារបស់ខ្លួន ។ អនាគតរបស់ពួកគេទាំងអស់គ្នា និងក្លាយជាពលរដ្ឋល្អ ដែលពោរពេញដោយចំណេះដឹងជ្រៅជ្រះធានានូវការទទួលរ៉ាប់រងវាសនាអនាគតរបស់ប្រទេសជាតិឱ្យសម្បូរ រីកចម្រើន រុងរឿង(**ឯកសារបំប៉ននាយកសាលារៀន៖ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ២០១៥**)

## ២.៥ ការគ្រប់គ្រង និងការបែងចែកធនធានមនុស្សក្នុងវិស័យអប់រំ

ការគ្រប់គ្រងធនធានមនុស្សទាក់ទង និងការភ្ជាប់ធនធានមនុស្ស ទៅនឹងវត្ថុបំណងនៃអង្គភាពដូចជាក្រសួងអប់រំជាឧទាហរណ៍។ ការគ្រប់គ្រងធនធានមនុស្ស នៅក្នុងវិស័យអប់រំទាក់ទងនិងមុខងារនៃការទាក់ទាញការអភិវឌ្ឍ និងការរក្សាបុគ្គលិកដែលមានគុណវុឌ្ឍិដើម្បីបំពេញបេសកម្មចាំបាច់ ដើម្បីសម្រេចគោលដៅអង្គភាព (ដោយប្រឈមនិងឧបសគ្គនានា)។ ទាក់ទិនទៅនិងការពង្រីកការសិក្សា ជាពិសេសការអប់រំនៅបឋមសិក្សា និង

អនុវិទ្យាល័យ ធនធានមនុស្សនៅក្នុងវិស័យអប់រំត្រូវតែផ្តល់ការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ និងប្រកបដោយសមធម៌ ដូចជាគ្រូបង្រៀនជាដើម ។ដើម្បីបង្កើនគុណភាព និងសមធម៌នៅក្នុងវិស័យអប់រំគោលបំណងសំខាន់នៃការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំគឺ ត្រូវធានាបាននូវការជ្រើសរើសគ្រូបង្រៀនដោយ សមស្របមាននីតិវិធីក្នុងការបណ្តុះបណ្តាលក៏ដូចជាការបែងចែកគ្រូបង្រៀនប្រកបដោយសមធម៌ព្រមទាំងមានការលើកទឹកចិត្ត កំណត់ឱ្យបានគ្រប់គ្រាន់ចំពោះបុគ្គលិកបង្រៀន និងមិនបង្រៀន ។ នៅទីបំផុតចំពោះឧបសគ្គថវិកាការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំត្រូវតែត្រួតពិនិត្យ និងការបន្ថែមចំណាយសម្រាប់បុគ្គលិក។

ក្នុងការអនុវត្តជាក់ស្តែងជារៀងរាល់ថ្ងៃមុខងារនៃការគ្រប់គ្រង និងបែងចែកគ្រូបង្រៀននៅថ្នាក់កណ្តាលជាទូទៅត្រូវបានយល់យ៉ាងច្បាស់រួមមាន៖ ការធ្វើផែនការបុគ្គលិកការជ្រើសរើសបុគ្គលិកការបែងចែកការពិនិត្យតាមដានក្របខណ្ឌច្បាប់រួមទាំងយន្តការអនុវត្តច្បាប់ការវាយតម្លៃ និងដំឡើឋានៈ។

ជាការសង្ខេបដោយ Halliday ការគ្រប់គ្រង និងបែងចែកគ្រូបង្រៀនគឺ ជាដំណើរការមួយដោយរួបញ្ចូលទាំងមុខងាររបស់បុគ្គលិកទាក់ទងទៅនឹងការតែងតាំងគ្រូបង្រៀន ។ ការបែងចែកគ្រូបង្រៀន ការធ្វើលិខិតបញ្ជាក់ការវាយតម្លៃ និងអភិវឌ្ឍបុគ្គលិកលក្ខណៈ ការដំឡើងឋានៈ ការដាក់ពិន័យ និងបញ្ហាដ៏ទៃទៀតដែលប៉ះពាល់ដល់សេវានៃការបង្រៀនរបស់គ្រូ។ជាធម្មតាបញ្ហានេះ នឹងរួមបញ្ចូលទាំងការទទួលខុសត្រូវសម្រាប់ការរៀបចំព័ត៌មានពាក់ព័ន្ធនឹងប្រាក់ខែនិងប្រាក់ឧបត្ថម្ភ( ការគ្រប់គ្រង និងបែងចែកធនធានអប់រំ,ក្រសួងអប់រំ ) ។

### ២.៥.១ ការបែងចែកគ្រូតាមសាលបឋមសិក្សា និងអនុវិទ្យាល័យ

ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់សាធារណៈរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានត្រួតពិនិត្យឡើងវិញនូវការគ្រប់គ្រងមន្ត្រីរាជការប្រកបដោយសនិទានកម្មក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការឱ្យសមស្របតាមនិយាមកំណត់មួយ និងការពង្រាយឱ្យដល់ទីកន្លែង ដែលមានតម្រូវការ ។ ដើម្បីសម្រេចបានការងារនេះយោងអនុក្រឹត្យលេខ ១៩ អនក ចុះថ្ងៃទី ២៥-១០-៨៦ ស្តីពីការកំណត់បទដ្ឋានប្រើប្រាស់ក្របខណ្ឌសម្រាប់អង្គភាពអប់រំនានាទូទាំងប្រទេសអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី៦ កញ្ញា

១៩៩៦ ស្ដីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០០៨ អនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ស្ដីពី ការកម្រិតរបបម៉ោងកំណត់ម៉ោងបន្ថែម និងប្រាំម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ សេចក្ដីណែនាំលេខ ២៨ អយក.សណន ស្ដីពីការផ្លាស់ប្ដូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ សេចក្ដីណែនាំលេខ ៤៤៤១ អយក.សណន ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១ ស្ដីពីការពង្រឹងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេលនិងថ្នាក់គួប សេចក្ដីណែនាំលេខ ៥៣អយក.សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពី ការគ្រប់គ្រងគ្រូបង្រៀន សេចក្ដីណែនាំលេខ ៣៣ អយក.សណន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤ ស្ដីពី និយាមប្រើប្រាស់បុគ្គលិកអប់រំ លេខ ២៤២ អយក សណន ចុះថ្ងៃទី ៣១-១-០១ ស្ដីពី ម៉ោងកំណត់របស់មន្ត្រីអប់រំ សម្រាប់បង្រៀនតាមកម្រិតថ្នាក់លេខ ២៥៦ អយក សណន ចុះថ្ងៃទី២៩-០១-០២ ស្ដីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យលេខ២០ អយក.សណន ចុះថ្ងៃទី ០៩-០៨-១៨ ស្ដីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំដូចខាងក្រោមៈ

**២.៥.២ គ្រឹះស្ថានសិក្សាចំណេះទូទៅ**

ដើម្បីដំណើរការសិក្សា បង្រៀន និងរៀន ការងាររដ្ឋបាល រួមទាំងការងារយុវជន នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅនីមួយៗ ការប្រើប្រាស់មន្ត្រីរាជការត្រូវបានកំណត់ដូចខាងក្រោមៈ

ការបែងចែកភារកិច្ចសម្រាប់បុគ្គលិកបង្រៀន( **និយាមលេខៈ២០ អយក.ប្រក ចុះថ្ងៃទី ០៩ សីហា ២០១៨** ) ការកំណត់ម៉ោងបង្រៀនសម្រាប់គ្រូទទួលបន្ទុកថ្នាក់គ្រូបឋមសិក្សា បង្រៀន ២៣ម៉ោង/សប្ដាហ៍ (គ្រូធម្មតាបង្រៀន ២៥ម៉ោង/សប្ដាហ៍)គ្រូមធ្យមសិក្សាបឋមភូមិ បង្រៀន ១៤ម៉ោង/សប្ដាហ៍ (គ្រូធម្មតាបង្រៀន១៨ម/ស) គ្រូមធ្យមសិក្សាទុតិយភូមិ បង្រៀន ១២ម៉ោង/សប្ដាហ៍(គ្រូធម្មតាបង្រៀន ១៦ម/ស)

គ្រូទទួលបន្ទុកថ្នាក់មានតួនាទី ជំនួយឱ្យការគ្រប់គ្រង និងការងារយុវជន និងមានភារកិច្ច បង្រៀនសិស្សតាមមុខវិជ្ជា តាមម៉ោងកំណត់ (១៤ម៉ោង ឬ១២ម៉ោងតាមក្របខណ្ឌគ្រូ) តាមដានការសិក្សារបស់សិស្សស្រង់និងបូកពិន្ទុពីបញ្ជីពិន្ទុ ចម្លងពិន្ទុចូលតារាង សៀវភៅតាមដាន សៀវភៅសិក្ខាគារិក ព្រឹត្តិបត្រពិន្ទុនិងមានសិទ្ធិចុះហត្ថលេខាលើសៀវភៅទាំងអស់នោះ និងអនុញ្ញាតច្បាប់ឱ្យសិស្សឈប់សម្រាក ។ គ្រូទទួលបន្ទុកថ្នាក់ថែមទាំងមានភារកិច្ច គ្រប់គ្រងសិស្ស វិន័យ អនាម័យ សីលធម៌ ការសិក្សា គ្រប់គ្រងឯកសារផ្សេងៗ ដឹកនាំសិស្សចូលរួមសកម្មភាពសង្គមផ្សេងៗ ទាំងក្នុង និងក្រៅសាលា ។

**២.៥.៣ ការអនុវត្តម៉ោងបន្ថែម**

គ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមបានលុះត្រាតែលោកគ្រូ អ្នកគ្រូបានបង្រៀនគ្រប់ម៉ោងកំណត់របស់ក្របខ័ណ្ឌសិនគឺ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិដែលទទួលបន្ទុកថ្នាក់បង្រៀន ១៥ម៉/សប្តាហ៍ ( គ្រូធម្មតាបង្រៀន ១៨ម៉/សប្តាហ៍ ) គ្រូមធ្យមសិក្សាទុតិយភូមិទទួលបន្ទុកថ្នាក់បង្រៀន ១៣ម៉/សប្តាហ៍ ( គ្រូធម្មតាបង្រៀន ១៦ម៉/សប្តាហ៍ ) ។ ក្នុងករណីបង្រៀនមិនគ្រប់ម៉ោងកំណត់ខាងលើក្នុងមុខវិជ្ជាណាមួយ លោកគ្រូអ្នកគ្រូ ត្រូវបង្រៀនមុខវិជ្ជាផ្សេងៗ ឬត្រូវបង្រៀននៅតាមភូមិសិក្សាខ្ពស់ជាង ឬទាបជាងឱ្យគ្រប់ម៉ោងកំណត់។

គ្រូមធ្យមសិក្សាបឋមភូមិដែលបង្រៀនឆ្លងភូមិសិក្សាខ្ពស់ជាងក្របខ័ណ្ឌរបស់ខ្លួន ម៉ោងកំណត់ត្រូវគិត ១៦ម៉ោង ។ គ្រូមធ្យមសិក្សាទុតិយភូមិដែលបង្រៀនឆ្លងភូមិសិក្សា ទាបជាងក្របខ័ណ្ឌរបស់ខ្លួនម៉ោងកំណត់ត្រូវរក្សា ១៦ម៉ោង។ ម៉ោងកំណត់របស់មន្ត្រីអប់រំដែលបង្រៀន១មុខវិជ្ជាចាប់ពី ៣កម្រិតថ្នាក់ឡើងទៅ ឬ៣មុខវិជ្ជាឡើងទៅ ត្រូវរាប់បញ្ចូលទាំងម៉ោងរៀបចំកិច្ចតែងការបង្រៀនមួយកម្រិតថ្នាក់ ចំនួន២ម៉ោង ឬ ១មុខវិជ្ជាចំនួន ២ម៉ោ( **សេចក្តីណែនាំបន្ថែមលេខ ២៤២ អយក.សណន ចុះថ្ងៃទី ៣១ កមរា ឆ្នាំ ២០០១** )។ ការគិតនេះមិនរាប់បញ្ចូល ១កម្រិតថ្នាក់ ឬមួយមុខវិជ្ជាដំបូងដែលជាកាតព្វកិច្ចក្នុងម៉ោងកំណត់របស់គ្រូម្នាក់ៗទេ (គ្រូមធ្យមសិក្សាទុតិយភូមិបង្រៀន ៣កម្រិតថ្នាក់ ឬ៣មុខវិជ្ជាមានម៉ោងកំណត់ចំនួន១២ម៉ោង ។

ក្នុងគ្រឹះស្ថានមធ្យមសិក្សាការបង្រៀនម៉ោងបន្ថែមមុខវិជ្ជាណាមួយត្រូវផ្តល់អាទិភាពទី១ទៅលើបុគ្គលបង្រៀន អាទិភាពទី២ ទៅនាយករង អាទិភាពទី៣ ទៅបុគ្គលិកផ្សេងៗទៀតនៅការិយាល័យ។ នាយកមានភារកិច្ចសម្របសម្រួលការបែងចែកម៉ោងបន្ថែមឱ្យអាទិភាពទាំងនោះដោយពិភាក្សា ពិគ្រោះយោបល់ជាមួយប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗ។

មន្ត្រីរាជការជាគ្រូបង្រៀនប្រចាំគ្រឹះស្ថានសិក្សាសាធារណៈណាមួយ អាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត ៤៨ម៉ោងក្នុងមួយខែ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈដែលសាមីជនកំពុងបំពេញការងារ ឬគ្រឹះស្ថានសិក្សាសាធារណៈផ្សេងទៀត។ មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមបានយ៉ាងច្រើនបំផុត ៣២ម៉ោងក្នុងមួយខែ( អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ មករា ឆ្នាំ ២០១៧ )។

**២.៥.៤ ការប្រើប្រាស់បុគ្គលិកនៅទីចាត់ការសាលា**

សាលាបឋមសិក្សាជាសាលាតូចដែលមាន ៦ថ្នាក់ត្រូវមាននាយកមួយនាក់ បណ្ណារក្សមួយនាក់ ។ ពី ៧ ដល់ ១០ ថ្នាក់មានត្រូវមាននាយកមួយនាក់ នាយករងម្នាក់ លេខាធិការម្នាក់ បណ្ណារក្សម្នាក់។ ១១ ដល់ ២០ថ្នាក់ ត្រូវមាន នាយកមួយនាក់ នាយករងម្នាក់ លេខាធិការម្នាក់ បណ្ណារក្សម្នាក់ គ្រូរោងជាងម្នាក់។សាលាមធ្យមដែលមានថ្នាក់ពី ២១ ដល់ ៣០ ថ្នាក់ ត្រូវមាន នាយកមួយនាក់ នាយករងម្នាក់ លេខាធិការម្នាក់ បណ្ណារក្សពីរនាក់ គ្រូរោងជាងម្នាក់។ ពី ៣១ ដល់ ៤០ ថ្នាក់ត្រូវមាន នាយកមួយនាក់ នាយករងពីរនាក់លេខាធិការម្នាក់ បណ្ណារក្សពីរនាក់ គ្រូរោងជាងម្នាក់។ សាលាធំ ដែលមានថ្នាក់ពី ៤១ ដល់ ៦០ ថ្នាក់ ត្រូវមាន នាយកមួយនាក់ នាយករងពីរនាក់ លេខាធិការម្នាក់ បណ្ណារក្សបីនាក់ គ្រូរោងជាងម្នាក់ បុគ្គលិក ឬឆ្មាំមួយនាក់។ ពី ៦១ ដល់ ៨០ ថ្នាក់ឡើង ត្រូវមាន នាយកមួយនាក់ នាយករងបីនាក់ លេខាធិការពីរនាក់ បណ្ណារក្សបីនាក់ គ្រូរោងជាងម្នាក់ បុគ្គលិក ឬឆ្មាំមួយនាក់។

ចំពោះសាលាមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ សាលាតូចដែលមាន ៦ថ្នាក់ត្រូវមាននាយកមួយនាក់ និងលេខាធិការមួយនាក់ ។ ៧ ដល់ ១៤ ថ្នាក់ត្រូវមាន នាយកមួយនាក់ នាយករងមួយ

នាក់ លេខាធិការមួយនាក់ បណ្ណារក្សមួយនាក់ គណនេយ្យមួយនាក់ អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍ពីរនាក់។ ១៥ ដល់ ២០ ថ្នាក់ត្រូវមាន នាយកមួយនាក់ នាយករងពីរនាក់ លេខាធិការមួយនាក់ បណ្ណារក្សពីរនាក់ គណនេយ្យមួយនាក់ អ្នកទទួលបន្ទុកយុវជនមួយនាក់ អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍ពីរនាក់។ សាលាមធ្យមចាប់ពី ២១ ដល់ ២៩ ថ្នាក់ត្រូវមាន នាយកមួយនាក់ នាយករងពីរនាក់ លេខាធិការមួយនាក់ បណ្ណារក្សពីរនាក់ បេឡាមួយនាក់ គណនេយ្យមួយនាក់ អ្នកទទួលបន្ទុកយុវជនមួយនាក់ អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍បីនាក់។ ៣០ ដល់ ៤០ ថ្នាក់ត្រូវមាន នាយកមួយនាក់ នាយករងពីរនាក់ លេខាធិការពីរនាក់ បណ្ណារក្សពីរនាក់ បេឡាមួយនាក់ គណនេយ្យមួយនាក់ អ្នកទទួលបន្ទុកយុវជនមួយនាក់ អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍បីនាក់។សាលាធំចាប់ពី ៤១ ដល់ ៦០ ថ្នាក់ត្រូវមាន នាយកមួយនាក់នាយករងបីនាក់លេខាធិការពីរនាក់ បណ្ណារក្សបីនាក់ បេឡាមួយនាក់ គណនេយ្យមួយនាក់ អ្នកទទួលបន្ទុកយុវជនពីរនាក់ អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍បីនាក់។ ៦១ ដល់ ៨០ ថ្នាក់ឡើង ត្រូវមាន នាយកមួយនាក់ នាយករងបីនាក់ លេខាធិការពីរនាក់ បណ្ណារក្សបីនាក់ បេឡាមួយនាក់ គណនេយ្យមួយនាក់អ្នកទទួលបន្ទុកយុវជនពីរនាក់ អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍បួននាក់ បុគ្គលិកឬឆ្មាំពីរនាក់ **(សេចក្តីណែនាំ ស្តីពី និយាមប្រើបុគ្គលិកអប់រំ លេខ ២០អយក.សណន ចុះថ្ងៃទី ០៩ សីហា ឆ្នាំ ២០១៨)**។

## ២.៦ បញ្ហាប្រឈមចំពោះការចាត់ចែងធនធានមនុស្ស

ការរៀបចំគ្រូបង្រៀនផ្នែក មធ្យមសិក្សាបឋមភូមិមានបញ្ហាប្រឈមខ្ពស់ជាងកម្រិតបឋមសិក្សាក្នុងអាទិភាពយ៉ាងច្រើនដូចជាការពង្រាយគ្រូទៅតាមមុខវិជ្ជាដោយសមធម៌និងមានភាពប្រទាក់ក្រឡា គួរតែលើកយកមកពិចារណាឱ្យបានត្រឹមត្រូវ ។ បញ្ហាប្រឈមដែលកាន់តែស្មុគស្មាញគឺទាក់ទងដល់ការជ្រើសរើសគ្រូបង្រៀននិងការរក្សាទុកពួកគាត់ឱ្យស្ថិតនៅក្នុងវិជ្ជាជីវៈរបស់គាត់ ។ លើសពីបញ្ហានៃការផ្គត់ផ្គង់គ្រូបង្រៀនទៅទៀតនោះគឺ បញ្ហាប្រឈមដែលទាក់ទងដល់ការរៀបចំធនធានមនុស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិបញ្ហាទាំងនោះមាន៖

កង្វះបុគ្គលិក ឬលើសបុគ្គលិក៖ ការផ្គត់ផ្គង់គ្រូបង្រៀន ស្ថានភាពខ្វះបុគ្គលិក ឬលើសបុគ្គលិកនៅសាលាមធ្យមសិក្សាបឋមភូមិតាមមុខវិជ្ជាឯកទេស និងទៅតាមតំបន់ជនបទ ឬតំបន់ទីប្រជុំជនគឺជារឿងសាមញ្ញ។ ស្ថានភាពនេះបង្ហាញថាការធ្វើផែនការគ្មានភាពច្បាស់លាស់ មិនមានតុល្យភាពក្នុងការជ្រើសរើសនិងបញ្ហាដែលមាននៅក្នុងដំណើរការនៃការពង្រាយគ្រូ។

ការវិចវិល៖ កើតមាននៅកម្រិតមធ្យមសិក្សាបឋមភូមិខ្ពស់ជាងនៅកម្រិតបឋមសិក្សា ។ តែជារឿយៗការសឹកវិចវិលនេះនៅមិនទាន់មានការត្រួតពិនិត្យឱ្យបានម៉ត់ចត់ និងលើកយកបញ្ហាដែលនៅខ្វះចន្លោះមកពិចារណាឱ្យបានច្បាស់លាស់ ជាពិសេសពេលធ្វើផែនការជ្រើសរើសគ្រូបង្រៀន។

ការបែងចែក៖ ការបែងចែកនៅតែមានភាពលំអៀងក្នុងការពង្រាយ គ្រូបង្រៀនបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិក្នុងតំបន់នានា (ខេត្ត ទីប្រជុំជន តំបន់ជនបទ) និងក្នុងចំណោមសាលារៀន យេនឌ័រមុខវិជ្ជាឯកទេស និងគ្រូដែលមានគុណភាព។ការបែងចែកនេះបង្កើតឱ្យមានការទិតៀន រិះគន់ពាក់ព័ន្ធទៅលើការរៀបចំនិយាមនិងទម្រង់ការណ៍នៃការចាត់ចែងគ្រូបង្រៀននិងការដាក់កម្រិតឬបង្ខំឱ្យគេត្រូវតែប្រតិបត្តិតាម។

បញ្ហាប្រើប្រាស់មិនសមស្រប៖ គ្រូបង្រៀនតិចម៉ោងនាំឱ្យមិនមានតុល្យភាពទៅ និងអត្រានៃការប្រើប្រាស់គ្រូបង្រៀន និងនាំឱ្យមានការចំណាយខ្ពស់នៅក្នុងប្រព័ន្ធអប់រំ។បញ្ហានេះកើតមានដោយសារការប្រើប្រាស់មិនសមស្របនិងមិនត្រឹមត្រូវតាមនិយាមកំណត់ ឬក៏មិនជម្រុញឱ្យប្រើប្រាស់តាមនិយាមដែលបានកំណត់

កង្វះ ឬលើសគ្រូ៖ ការខ្វះខាតគ្រូបង្រៀននៅតាមសាលាធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរតាមតំបន់ជនបទ ។ដូច្នេះវាមិនមានភាពចម្លែកអ្វីនោះទេ ក្នុងការស្វែងរកដំណោះស្រាយបន្ថែមទៀត។បញ្ហានេះមកពីគ្រូបង្រៀននៅបឋមសិក្សានិងអនុវិទ្យាល័យមានភាពស្ទាក់ស្ទើរក្នុងការទៅបង្ហាត់បង្រៀននៅជនបទ ដោយសារលក្ខខ័ណ្ឌការងារនៅទីនោះមានភាពលំបាកច្រើនជាពិសេសអ្នកទាំងឡាយដែលរស់នៅទីក្រុងស្រាប់ ។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ដែនកំណត់ និងវិសាលភាព

ដើម្បីឲ្យការសិក្សាស្រាវជ្រាវដំណើរការទៅបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយទៅលើ **ប្រធានបទស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ** អ្នក ស្រាវជ្រាវ បានយកសាលាបឋមសិក្សានិងអនុវិទ្យាល័យ ទាំងអស់ក្នុងខេត្តព្រះសីហនុតែប៉ុណ្ណោះដើម្បីមកធ្វើការស្រាវជ្រាវ។

អ្នកស្រាវជ្រាវបានជ្រើសរើសយកសំណាកតែអ្នកពាក់ព័ន្ធនាយក ឬនាយករងសាលាបឋមសិក្សាចំនួន៧២សាលាអនុវិទ្យាល័យចំនួន ១៨ សាលាវិទ្យាល័យដែលមានអនុវិទ្យាល័យនៅជាមួយចំនួន ៨ ក្នុងខេត្តព្រះសីហនុ សម្រាប់ធ្វើការវិភាគ។

## ៣.២សំណាក

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើគ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ (ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៩) ដោយគិតពីកម្រិតគ្រូបង្រៀនបឋមសិក្សានិងគ្រូកម្រិតមូលដ្ឋាន។គោលដៅគឺ នាយក ឬនាយករង មួយនាក់ក្នុងមួយសាលា។

ការស្រាវជ្រាវនេះ ប្រើទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរបិទ។ រីឯទិន្នន័យតាមបែបគុណវិស័យត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរបើក។ ទិន្នន័យទាំងពីរប្រភេទខាងលើនេះត្រូវបានប្រមូលពី សាលាបឋមសិក្សាចំនួន ៧២ និងអនុវិទ្យាល័យចំនួន ២៦ក្នុងខេត្តព្រះសីហនុ។

ចំពោះការវិភាគទិន្នន័យបែបបរិមាណវិស័យគឺ វិភាគតាមក្រាហ្វ និងតារាង ដោយប្រើកម្មវិធីExcel ។ រីឯការវិភាគទិន្នន័យតាមបែបគុណវិស័យ គឺវិភាគតាមរយៈការចាត់ថ្នាក់ជាក្រុម និងដាក់ចំណងជើងដោយផ្អែកទៅលើទស្សនៈ និងអត្ថន័យនៃប្រយោគដែលមានលក្ខណៈប្រហាក់ប្រហែលគ្នារួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ ។

## ៣.៣ ឧបករណ៍

ឧបករណ៍ស្រាវជ្រាវដែលត្រូវ យកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យមានជាកម្រងសំណួរដែលមានលក្ខណៈកម្រិតចម្លើយ(ទម្រង់បិទ) និងកម្រងសំណួរ(ទម្រង់បើក)។ ដើម្បីឱ្យប្រមូលទិន្នន័យនេះបានត្រូវមានកម្រងសំណួរសម្រាប់នាយកសាលា។ កម្រងសំណួរត្រូវបានបង្កើតឡើងមាន ១ ប្រភេទប៉ុណ្ណោះដើម្បីធ្វើការប្រមូលទិន្នន័យនេះគឺ កម្រងសំណួរសម្រាប់សួរសម្ភាសនាយកសាលា មានគោលបំណងស្វែងយល់ពីដំណើរការនៃការងារគ្រប់គ្រងរបស់នាយកសាលាលើការគ្រប់គ្រង និងប្រើប្រាស់បុគ្គលិករបស់ខ្លួន ។ កម្រងសំណួរសម្រាប់នាយកសាលាមាន ២ ផ្នែកគឺ ផ្នែកទី១ ស្តីអំពីការកំណត់ពីតម្រូវការដូចជាចំនួនសិស្ស ចំនួនថ្នាក់មុខវិជ្ជាបង្រៀនជាក់ស្តែង ចំនួនគ្រូបង្រៀនកម្រិតបឋមសិក្សា និងកម្រិតមូលដ្ឋាន ដែលកំពុងបង្រៀនជាក់ស្តែង ដំណោះស្រាយបញ្ហាលើសគ្រូ ខ្វះគ្រូ ផ្តល់អនុសាសន៍លើបញ្ហានេះ ការទទួលគ្រូបង្រៀនពីប្រភពផ្សេងៗ ដោយមិនបានស្នើសុំ និងផ្នែកទី២ ស្តីអំពីទស្សនៈរបស់នាយកសាលាលើការជ្រើសរើសគ្រូបង្រៀន ដូចជាការទទួលបានចំនួនគ្រូបង្រៀនត្រឹមត្រូវទេតាមការស្នើសុំក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ និងបញ្ហាប្រឈមដែលជួបប្រទះក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យ។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះរយៈពេលនៃការសាកសួរក្នុងការសម្ភាសជាមធ្យមមានរយៈពេលពី ២០នាទី ទៅ២៥នាទីតាមទីកន្លែងដែលបានព្រមព្រៀងគ្នារវាងអ្នកសម្ភាស និងនាយកសាលាទាំង ៩៨ ក្នុងខេត្តព្រះសីហនុ។

## ៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

បន្ទាប់ពីទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំស្តីពីការចុះប្រមូលទិន្នន័យតាមសាលានីមួយៗក្នុងខេត្តព្រះសីហនុ ផ្នែកបឋមសិក្សា និងអនុវិទ្យាល័យ អ្នកស្រាវជ្រាវបានទៅទាក់ទងនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ ដើម្បីសុំឱ្យមន្ទីរអប់រំចេញលិខិតឧទ្ទេសនាមស្តីពីការអនុញ្ញាត ឱ្យចុះប្រមូលទិន្នន័យតាមសាលា និងជូនដំណឹងដល់ភាគីពាក់ព័ន្ធដូចជានាយកសាលាគ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំក្រុង/ស្រុក ចូលរួមសហការ។ បន្ទាប់មកអ្នកស្រាវជ្រាវបានទាក់ទងទៅនាយកសាលានីមួយៗដើម្បីណាត់ពេលវេលា ទីកន្លែង ធ្វើការសម្ភាស ។ មុននិងបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវបានពន្យល់ដល់នាយកសាលា

សាលានីមួយៗអំពីទិន្នន័យដែលត្រូវបំពេញ បន្ទាប់មកសម្ភាសជាមួយនាយកសាលាដោយប្រើកម្រងសំណួរដែលបានរៀបចំទុកជាមុនស្របតាមគោលបំណង នៃការស្រាវជ្រាវដែលនៅក្នុងនោះមានបញ្ចូលព័ត៌មានដែលត្រូវសួរដូចជាព័ត៌មានផ្នែកទី១ស្ដីអំពីការកំណត់ពីតម្រូវការ និងផ្នែកទី២ ស្ដីអំពីទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ ។

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគនេះអ្នកស្រាវជ្រាវវិភាគលើចំណុចគោលផ្អែកលើខ្លឹមសារសំខាន់ៗចំនួន០៤ផ្នែកគឺៈ (១)ចំនួនសិស្ស ចំនួនថ្នាក់ សាលាបឋមសិក្សា និងអនុវិទ្យាល័យ(២) ចំនួនបន្ទប់ដែលសាលាមានជាក់ស្ដែង(៣)ចំនួនគ្រូបឋមសិក្សា និងអនុវិទ្យាល័យដែលមានគុណវុឌ្ឍិ (៤)ចំនួនគ្រូដែលកំពុងបង្រៀនជាក់ស្ដែងផ្នែកបឋមសិក្សា និងអនុវិទ្យាល័យ។

ការវិភាគនេះគឺធ្វើឡើងដោយប្រើវិធីសាស្ត្រវិភាគទិន្នន័យបរិមាណវិស័យ និងគុណវិស័យ។ តាមបែបបរិមាណវិស័យគឺយកទិន្នន័យ ដែលបានមកពីការសម្ភាសនាយកសាលាតាមរយៈកម្រងសំណួរបិទមកបញ្ចូលក្នុងតារាងដោយប្រើកម្មវិធី Exel ដើម្បីសង់ជាក្រាហ្វិក ដោយយកទិន្នន័យតាមសាលានីមួយៗសរុបចូលគ្នាវិភាគលើថ្នាក់ស្រុកនីមួយៗ និងសរុបស្រុកបានថ្នាក់ខេត្ត បែបគុណវិស័យវិភាគទៅលើការយល់ឃើញក្នុងការប្រើប្រាស់គ្រូ របស់នាយកសាលានីមួយៗដើម្បីរកឱ្យឃើញពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមទាក់ទងទៅនឹងការពង្រាយគ្រូ និងការប្រើប្រាស់គ្រូដោយប្រើកម្មវិធី អាយប៊ីអឹម អេស ភី អេស អេស( Excel .IBM SPSS…)។

# ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ

ក្រោយពីទទួលបានទិន្នន័យរួចមក ជាលទ្ធផលបានបង្ហាញថា នៅក្នុងខេត្តព្រះសីហនុ មានសាលាអនុវិទ្យាល័យសរុបចំនួន ២៦ ដែលក្នុងនោះអនុវិទ្យាល័យដែលមានទីតាំងជាមួយវិទ្យាល័យមានចំនួន ៨។ ក្នុងនោះផងដែរ មានចំនួនថ្នាក់រៀនជាក់ស្តែងសរុបចំនួន ១៩៦ ថ្នាក់ដែលប្រើប្រាស់តាមនិយាម មានចំនួន ១៨៣និងចំនួនថ្នាក់លើសពីនិយាមមានចំនួន១៣ថ្នាក់។




*ក្រាហ្វទី 1៖ ទិន្នន័យថ្នាក់សរុប ២៦អនុវិទ្យាល័យ(ខេត្តព្រះសីហនុ)*

តាមក្រាហ្វទី១បង្ហាញថា៖ ស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពីអនុវិទ្យាល័យទាំង ២៦ ក្នុងខេត្តព្រះសីហនុ(វិទ្យាល័យដែលមានអនុវិទ្យាល័យនៅជាមួយ ៨ និងអនុវិទ្យាល័យ ១៨)។ អនុវិទ្យាល័យមានសិស្សសរុបចំនួន ៨២៣០ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់មានចំនួន ៤៥ នាក់ដែលបានកំណត់ដោយច្បាប់ នោះចំនួនថ្នាក់នៅក្នុងអនុវិទ្យាល័យទាំង ២៦ នៅក្នុងខេត្តព្រះសីហនុមាន ១៨៣ ថ្នាក់ (៨២៣០ ចែកនឹង ៤៥)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវរៀន៣២ម៉ោងក្នុងមួយសប្តាហ៍នាំឱ្យចំនួនម៉ោងសរុបគឺ៥៨៥៦ម៉ោង(១៨៣ គុណនឹង ៣២) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន៣២៥ នាក់ (៥៨៥៦ចែកនឹង ១៨) សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ ១៨ ម៉ោងក្នុង មួយសប្តាហ៍)។

ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីអនុវិទ្យាល័យទាំង ២៦ ក្នុងខេត្តព្រះសីហនុ ចំនួនថ្នាក់សរុបមាន ១៩៦ ថ្នាក់ ច្រើនជាងចំនួនថ្នាក់គិតតាមនិយាម ១៣ ថ្នាក់(១៩៦ថ្នាក់ដកនឹង១៨៣ថ្នាក់)នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់អនុវិទ្យាល័យទាំង ២៦ក្នុងខេត្តព្រះសីហនុ មិនទាន់គោរពបាននូវនិយាមសិស្ស ថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។

សន្និដ្ឋាន អនុវិទ្យាល័យទាំងអស់ក្នុងខេត្តព្រះសីហនុលើសចំនួន១៣ ថ្នាក់បើគិតទៅតាមនិយាម នេះបញ្ជាក់ថា សាលាអនុវិទ្យាល័យមួយចំនួនមិនបានបែងចែក សិស្ស ថ្នាក់ ទៅតាមនិយាមដែលកំណត់ក្រសួងអប់រំយុវជន និងកីឡា។

ក្រោយពីទទួលបានទិន្នន័យរួចមក ជាលទ្ធផលបានបង្ហាញថា នៅក្នុងខេត្តព្រះសីហនុ មានសាលាបឋមសិក្សាសរុបចំនួន ៧២។ ក្នុងនោះផងដែរ មានចំនួនថ្នាក់រៀនជាក់ស្តែងសរុបចំនួន ៨២២ថ្នាក់ បើប្រើប្រាស់តាមនិយាមមានចំនួន៦០៣ថ្នាក់ និងចំនួនថ្នាក់លើសពីនិយាមមានចំនួន ២១៩ថ្នាក់។




*ក្រាហ្វទី 2៖ ទិន្នន័យថ្នាក់សរុប ៧២សាលាបឋមសិក្សា(ខេត្តព្រះសីហនុ)*

តាមក្រាហ្វទី២បង្ហាញថា៖ ស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពី សាលាបឋមសិក្សាទាំង ៧២ ក្នុងខេត្តព្រះសីហនុ។សាលាបឋមសិក្សាមានសិស្សសរុបចំនួន ២៧១២៥ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់មានចំនួន ៤៥ នាក់ដែលកំណត់ដោយច្បាប់ នោះចំនួនថ្នាក់នៅក្នុងសាលាបឋមសិក្សាទាំង៧២ នៅក្នុងខេត្តព្រះសីហនុមាន ៦០៣ថ្នាក់(២៧១២៥ ចែកនឹង ៤៥)តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវរៀន ២៥

ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ ១៥០៧៥ម៉ោង(៦០៣ គុណនឹង ២៥)ដែលត្រូវប្រើប្រាស់គ្រូបង្រៀនបឋមសិក្សាចំនួន ៦០៣ នាក់ គ្រូបង្រៀនម្នាក់កាន់មួយថ្នាក់(និយាមគ្រូបង្រៀននៅបឋមសិក្សា ២៥ ម៉ោងក្នុងមួយសប្តាហ៍)។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីសាលាបឋមសិក្សាទាំង ៧២ ក្នុងខេត្តព្រះសីហនុ ចំនួនថ្នាក់សរុបមាន ៨២២ ថ្នាក់ ច្រើនជាងចំនួនថ្នាក់គិតតាមនិយាម ២១៩ថ្នាក់(៨២២ថ្នាក់ដកនឹង៦០៣ថ្នាក់)នេះបញ្ជាក់ឱ្យឃើញថាការប្រើប្រាស់និយាមសិស្សថ្នាក់របស់សាលាបឋមសិក្សាទាំង ៧២ ក្នុងខេត្តព្រះសីហនុមិនទាន់គោរពបាននូវនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

សន្និដ្ឋាន នាយកសាលាបឋមសិក្សាស្ទើរតែទាំងអស់ក្នុងខេត្តព្រះសីនុ មិនបានបែងចែក សិស្ស ថ្នាក់ទៅតាមនិយាមដែលកំណត់ដោយក្រសួងអប់រំឡើយជាហេតុធ្វើឱ្យថ្នាក់រៀនលើសរហូតដល់ ២១៩ថ្នាក់បើគិតទៅតាមនិយាម ។ ដូច្នេះបញ្ជាក់ឱ្យឃើញថាការអនុវត្តតាមនិយាម សិស្ស ថ្នាក់ ដែលក្រសួងបានដាក់ចេញចំពោះខេត្តព្រះសីហនុការអនុវត្តតាមនៅមានកម្រិត។

ចំពោះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) ហើយកំពុងបម្រើការនៅតាមអនុវិទ្យាល័យនានាក្នុងខេត្តព្រះសីហនុវិញមានចំនួន ៤៨៥នាក់លើសតម្រូវការតាមនិយាម ១៦០នាក់(៤៨៥ ដក ៣២៥) មានន័យថាលើសគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ១៦០ នាក់បើអនុវត្តទៅតាមនិយាមដែលកំណត់ដោយច្បាប់។




*ក្រាហ្វទី 3៖ ស្ថិតិគ្រូកម្រិតមូលដ្ឋានទាំង ២៦អនុវិទ្យាល័យ(ខេត្តព្រះសីហនុ)*

សរុបមក ខេត្តព្រះសីហនុគ្រូកម្រិតមូលដ្ឋានលើសចំនួន ១៦០នាក់ បើគិតទៅតាមនិយាម តែសាលារៀនមួយចំនួននៅតែខ្វះគ្រូ នេះបញ្ជាក់ថាការបែងចែកគ្រូពុំទាន់មានតម្លាភាព ហើយមិនទាន់បានអនុវត្តពេញលេញទៅតាមលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបែងចែកបុគ្គលិកអប់រំ

ចំពោះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ (កម្រិតបឋម) ហើយកំពុងបម្រើការនៅតាមសាលាបឋមសិក្សានានាក្នុងខេត្តព្រះសីហនុវិញ មានចំនួន ៨៣៦ នាក់ លើសតម្រូវការតាមនិយាម ២៣៣ នាក់ (៨៣៦ដក ៦០៣) មានន័យថាលើសគ្រូបង្រៀនកម្រិតបឋមចំនួន ២៣៣ នាក់ បើអនុវត្តទៅតាមនិយាមដែលកំណត់ដោយច្បាប់។




*ក្រាហ្វទី 4៖ស្ថិតិគ្រូកម្រិតបឋមទាំង ៧២សាលាបឋមសិក្សា(ខេត្តព្រះសីហនុ)*

សន្និដ្ឋាន ខេត្តព្រះសីហនុសរុបសាលាបឋមសិក្សាទាំង ៧២ គ្រូបង្រៀនមានគុណវុឌ្ឍិ(កម្រិតបឋមសិក្សា)មានចំនួន ៨៣៦ បើគិតទៅតាមនិយាមវិញតម្រូវការគ្រូបង្រៀនតែ ៦០៣នាក់ ដូច្នេះលើសគ្រូបង្រៀនចំនួន ២៣៣នាក់ តែសាលារៀនមួយចំនួននៅតែខ្វះគ្រូ នេះបញ្ជាក់ថាការបែងចែកគ្រូពុំទាន់មានតម្លាភាព ហើយមិនទាន់បានអនុវត្តឱ្យបានពេញលេញទៅតាមលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីការបែងចែកបុគ្គលិកអប់រំ។

ទិន្នន័យថ្នាក់ជាក់ស្តែងសរុបទាំង ២៦ អនុវិទ្យាល័យក្នុងខេត្តព្រះសីហនុមាន ១៩៦ថ្នាក់ និងគ្រូបង្រៀនមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)ជាក់ស្តែងមានចំនួន ៤៨៥ បើគិតតាមនិយាមមានចំនួន៣២៥នាក់

(១៨៣ គុណនឹង ៣២ ចែកនឹង ១៨) គ្រូលើសមានចំនួន១៦០(៤៨៥ដកនឹង៣២៥)ដូចច្នេះមានន័យថា ២៦អនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ ប្រើប្រាស់គ្រូច្រើនជាងតម្រូវការជាក់ស្តែងចំនួន ១៦០ នាក់។




*ក្រាហ្វទី 5៖ គ្រូកម្រិតមូលដ្ឋានគិតតាមនិយាម ថ្នាក់ជាក់ស្តែង អនុវិទ្យាល័យ ២៦ (ខេត្តព្រះសីហនុ)*

សន្និដ្ឋាន អនុវិទ្យាល័យ១៨ និងវិទ្យាល័យមានអនុវិទ្យាល័យនៅជាមួយ ៨នៅក្នុងខេត្តព្រះសីហនុ បើគិតទៅតាមនិយាមតម្រូវការគ្រូបង្រៀនកម្រិតបឋមសិក្សាតែ ៣២៥នាក់ តែជាក់ស្តែងគ្រូបង្រៀនកម្រិតមូលដ្ឋានមាន ៤៨៥នាក់ ដូច្នេះលើសគ្រូបង្រៀនចំនួន ១៦០នាក់តែសាលារៀនមួយចំនួននៅតែខ្វះគ្រូនេះបញ្ជាក់ថាការបែងចែកគ្រូពុំទាន់មានតម្លាភាពហើយមិនទាន់បានអនុវត្តឱ្យ បានពេញលេញទៅតាមលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពីការបែងចែកបុគ្គលិកអប់រំ។

ទិន្នន័យថ្នាក់ជាក់ស្តែងសរុបទាំង ៧២ សាលាបឋមសិក្សាក្នុងខេត្តព្រះសីហនុមាន ៨២២ថ្នាក់និងគ្រូបង្រៀនមានគុណវុឌ្ឍិ (កម្រិតបឋម) ជាក់ស្តែងមានចំនួន ៨៣៦បើគិតតាមនិយាមមានថ្នាក់រៀនមានចំនួន ៦០៣ ថ្នាក់ (២៧១២៥ ចែកនឹង ៤៥) គ្រូបង្រៀនតាមនិយាមក៏ ៦០៣នាក់ដែរព្រោះគ្រូម្នាក់បង្រៀន ១ថ្នាក់គ្រូលើសនិយាមមានចំនួន២៣៣ (៨៣៦ដក៦០៣) ដូច្នេះមានន័យថា៧២សាលាបឋមសិក្សាក្នុងខេត្តព្រះសីហនុ ប្រើប្រាស់គ្រូច្រើនជាងតម្រូវការជាក់ស្តែងចំនួន ២៣៣ នាក់។




*ក្រាហ្វទី 6៖ គ្រូកម្រិតបឋមសិក្សាគិតតាមនិយាម ថ្នាក់ជាក់ស្តែង សាលាបឋមសិក្ស ៧២ (ខេត្តព្រះសីហនុ)*

តាមការយល់ឃើញផ្ទាល់ខ្លួន ដើម្បីដោះស្រាយបញ្ហាគ្រូលើសនេះសាលាបឋមសិក្សាមួយចំនួន ក្នុងខេត្តព្រះសីហនុ ប្រើវិធីដូចជា បន្ថយនិយាម សិស្សថ្នាក់តិចជាង ៤០នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា។

*តារាងទី 1៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង អនុវិទ្យាល័យទាំង២៦ ក្នុងខេត្តព្រះសីហនុ*

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 8230 | |
| ថ្នាក់ | 183 | 196 |
| ម៉ោង | 6272 | 5856 |
| គ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) | 325 | 503 |

បើពិនិត្យជាក់ស្តែងឱ្យកាន់តែស៊ីជម្រៅ ទោះបីមានការលើសគ្រូបង្រៀនកម្រិតមូលដ្ឋានយ៉ាងច្រើនដូចនេះក៏មិនបានបញ្ជាក់ថាខ្វះគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ ។ ជាក់ស្តែងដូចមានបង្ហាញក្នុងក្រាបទី១ នៅក្នុងខេត្តព្រះសីហនុ មាន ២៦អនុវិទ្យាល័យ ភាគច្រើនគឺខ្វះ គីមី ផែនដីវិទ្យា ភូមិវិទ្យា

សីលធម៌ពលរដ្ឋ បច្ចេកវិទ្យាព័ត៌មាន គេហកិច្ចគឺតម្រូវការគ្រូមាន 26, 26, 27,31,31, 26 រីឯគ្រូកម្រិតមូលដ្ឋានវិញមាន 20, 16, 24, 23, 1, 11 ។

តាមមតិផ្ទាល់ខ្លួន ខេត្តព្រះសីហនុមានការខ្វះគ្រូបង្រៀនព័ត៌មានវិទ្យាយ៉ាងច្រើនដែលធ្វើ ឱ្យការបង្រៀនមុខវិជ្ជានេះទទួលបានលទ្ធផលមិនល្អ ព្រោះយកគ្រូឯកទេសផ្សេងទៅបង្រៀនជំនួស។




*ក្រាហ្វទី 7៖ ថ្នាក់ ម៉ោង គ្រូកម្រិតមូលដ្ឋានតាមនិយាម និងមានជាក់ស្តែង*

ការស្រាវជ្រាវនេះ ក៏បានពិនិត្យយ៉ាងស៊ីជម្រៅផងដែរទៅលើអនុវិទ្យាល័យ ២៦ ដែលនៅតាមស្រុកនីមួយៗលទ្ធផលបង្ហាញដូចខាងក្រោម៖

## ៤.១ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានក្នុងស្រុកទី១

ក្នុងស្រុកទី១ សំណាកដែលត្រូវបានជ្រើសរើសមានចំនួន ៣ អនុវិទ្យាល័យមានស្ថិតិសិស្ស សរុបមាន ៥៤០ នាក់។ តាមនិយាមត្រូវមានថ្នាក់ចំនួន១២ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍៣៨៤ម៉ោង ដែលប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ២១ នាក់ ។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែងអនុវិទ្យាល័យក្នុងស្រុកទី១នេះមានថ្នាក់ ៥ ម៉ោង ៤៨០ គឺមិនត្រូវទៅតាមនិយាមទេ ព្រោះគ្រូកម្រិតមូលដ្ឋាន

មានរហូតដល់ទៅ ៤៦នាក់ គឺលើសគ្រូចំនួន ២៥នាក់។

*តារាងទី 2៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង អនុវិទ្យាល័យទាំង៣ ក្នុងស្រុកទី១*

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 540 | |
| ថ្នាក់ | 12 | 15 |
| ម៉ោង | 384 | 480 |
| គ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) | 21 | 46 |

ក្រាហ្វទី២ ខាងក្រោមនេះបង្ហាញថាអនុវិទ្យាល័យក្នុងស្រុកទី១ មានមុខវិជ្ជាខ្លះខ្វះគ្រូ មុខវិជ្ជាខ្លះគ្រប់ចំនួន រីឯមុខវិជ្ជាដ៏ទៃទៀតលើសទៅវិញ។ ដូច្នេះក្រាបទី២ ខាងក្រោមបង្ហាញពីតម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវិឌ្ឍិ (កម្រិតមូលដ្ឋាន) លើមុខវិជ្ជាចំនួន ១៣ រួមមាន គណិតវិទ្យា អក្សរសាស្ត្រខ្មែរ ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋ ICT គេហវិទ្យា ភាសាបរទេស អប់រំកាយ។

តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជា គីមីវិទ្យា ផែនដីវិទ្យា ICT គេហវិទ្យា មានចំនួនគ្រូ ដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) តិចជាងតម្រូវការ។ ចំណែកឯមុខវិជ្ជា អក្សរសាស្ត្រខ្មែរ គណិតវិទ្យា ជីវវិទ្យា រូបវិទ្យា ប្រវត្តិវិទ្យា ភាសាបរទេស អប់រំកាយ គឺសុទ្ធតែលើសពីតម្រូវការ។នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកទី១ នេះនៅមានកម្រិត។

សន្និដ្ឋាន ចំពោះការបែងចែកគ្រូបង្រៀននៅស្រុកទី១នេះមិនទាន់សមស្របទៅតាមនិយាម និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅស្រុកទី១នេះគឺ យកគ្រូដែលលើសតាមមុខវិជ្ជា ទៅបង្រៀនខុសឯកទេស ចំពោះមុខវិជ្ជាណាដែលខ្វះគ្រូ។




*ក្រាហ្វទី ៥៖ គុណវុឌ្ឍិគ្រូបង្រៀន(កម្រិតមូលដ្ឋាន)នៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតម្រូវការជាក់ស្តែងក្នុងស្រុកទី១*

ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាសំខាន់ៗលើ ១៣ មុខវិជ្ជា ដើម្បីធ្វើការប្រៀបធៀប ចំនួនគ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) ធៀបទៅនិងចំនួនតម្រូវការគ្រូគិតតាមនិយាម។ ជាលទ្ធផលបង្ហាញឱ្យឃើញថាមានសាលារៀនខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋានលើមុខវិជ្ជាខ្លះ រីឯសាលាខ្លះទៀតខ្វះគ្រូបង្រៀនលើមុខវិជ្ជានោះ និងសាលាខ្លះទៀតមានគ្រូបង្រៀនគ្រប់ចំនួន ។ តួយ៉ាងដូចជាមុខវិជ្ជា គណិតវិទ្យានៅសាលាទី២ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាមចំនួន ១នាក់ គ្រូជាក់ស្តែងមាន ២នាក់ លើសពីតម្រូវការ១នាក់ ចំណែកសាលាទី៣ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាម ២នាក់ គ្រូជាក់ស្តែងមាន ៣នាក់ លើសពីតម្រូវការ១នាក់ ចំណែកឯសាលាទី១វិញ តម្រូវការគ្រូតាមនិយាម ១នាក់ ប៉ុន្តែគ្រូកម្រិតមូលដ្ឋានតាមជាក់ស្តែងគ្មាន ។ លទ្ធផលនេះបង្ហាញឱ្យឃើញថាការបែងចែកគ្រូទៅតាមអនុវិទ្យាល័យក្នុងស្រុកនេះមិនទាន់គិតគូបានត្រឹមត្រូវនោះទេ ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពនៃការអប់រំ។




*ក្រាហ្វទី ១៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ(គ្រូកម្រិតមូលដ្ឋាន)តាមនិយាមនៃមុខវិជ្ជានីមួយៗ និងគ្រូបង្រៀនដែលមានជាក់ស្តែងនៃមុខវិជ្ជានីមួយៗ តាមអនុវិទ្យាល័យក្នុងស្រុកទី១*

## ៤.២ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានក្រុងស្រុកទី២

ក្នុងស្រុកទី២ សំណាកដែលត្រូវបានជ្រើសរើសមានចំនួន ៤អនុវិទ្យាល័យ មានស្ថិតិសិស្ស ៧៩៦នាក់។ តាមនិយាមត្រូវមានថ្នាក់ចំនួន ១៨ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៥៤០ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានសម្រាប់គ្រប់មុខវិជ្ជាចំនួន ៣០នាក់។ប៉ុន្តែតាមស្ថានភាពជាក់ស្តែងអនុវិទ្យាល័យក្នុងស្រុកទី២ នេះមាន១៩ថ្នាក់ ម៉ោង ៦០៨គឺមិនត្រូវទៅតាមនិយាមទេព្រោះគ្រូកម្រិតមូលដ្ឋានមានរហូតដល់ទៅ ៣៩នាក់ គឺលើសគ្រូចំនួន ៩នាក់។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅស្រុកទី២មិនទាន់សមស្របទៅតាមនិយាម និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ ។ ដំណោះស្រាយចំពោះមុខគឺ ប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន មិនគ្រប់ម៉ោងទៅតាមនិយាមដែលក្រសួងបានកំណត់។

*តារាងទី ៣៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅតាមអនុវិទ្យាល័យក្នុងស្រុកទី២*

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 796 | |
| ថ្នាក់ | 18 | 19 |
| ម៉ោង | 576 | 608 |
| គ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) | 32 | 39 |

បើតាមរបាយគ្រូមុខវិជ្ជានីមួយៗក្នុងអនុវិទ្យាល័យទាំង ៤ ក្នុងស្រុកទី២ វិញបានបង្ហាញថាមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ចំនួន រីឯមុខវិជ្ជាដ៏ទៃទៀតលើសទៅវិញ។ ដូច្នេះក្រាបទី២ ខាងក្រោមបង្ហាញពីតម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)លើមុខវិជ្ជាចំនួន ១៣ រួមមាន៖ គណិតវិទ្យា អក្សរសាស្ត្រខ្មែរ ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋ ICT គេហវិទ្យា ភាសាបរទេស អប់រំកាយ សម្រាប់ស្រុកទី២ ។ តាមរយៈក្រាបទី២ នេះបង្ហាញឱ្យឃើញថាមុខវិជ្ជាប្រវត្តិវិទ្យាចំនួន គ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)លើសពីតម្រូវការតាមនិយាម។ រីឯមុខវិជ្ជា គណិតវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋ អប់រំកាយ មានចំនួនគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) តិចជាងតម្រូវការ។ ចំពោះមុខវិជ្ជា ICT គ្មានគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន)តាមនិយាមទេ ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី២ នេះនៅមានកម្រិត។

សន្និដ្ឋាន ចំពោះការបែងចែកគ្រូបង្រៀននៅស្រុកទី២នេះមិនទាន់សមស្របទៅតាមនិយាម និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅស្រុកទី២នេះគឺ យកគ្រូដែលលើសតាមមុខវិជ្ជា ទៅបង្រៀនខុសឯកទេស ចំពោះមុខវិជ្ជាណាដែលខ្វះគ្រូ និងយកគ្រូកម្រិតមូលដ្ឋានទៅបង្រៀននៅវិទ្យាល័យចំពោះមុខវិជ្ជាមួយចំនួន (សាលាដែលអនុវិទ្យាល័យនៅជាមួយវិទ្យាល័យ)។




*ក្រាហ្វទី 10៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី២*

ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរនូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាសំខាន់ៗលើ ១៣មុខវិជ្ជាដើម្បីធ្វើការប្រៀបធៀប ចំនួនគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) ធៀបទៅនិងចំនួនតម្រូវការគ្រូគិតតាមនិយាម។ ជាលទ្ធផលបង្ហាញឱ្យឃើញថាមានសាលារៀនខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន លើមុខវិជ្ជាខ្លះរីឯសាលាខ្លះទៀតខ្វះគ្រូបង្រៀនលើមុខវិជ្ជានោះ និងសាលាខ្លះទៀតមានគ្រូបង្រៀនគ្រប់ចំនួន។តួយ៉ាងដូចជាមុខវិជ្ជារូបវិទ្យានៅសាលាទី៣ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាមចំនួន ១នាក់ គ្រូជាក់ស្តែងមាន២នាក់លើសពីតម្រូវការ១នាក់ ចំណែកសាលាទី២ និងទី៤ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាម ១នាក់ប៉ុន្តែគ្រូកម្រិតមូលដ្ឋានតាមជាក់ស្តែងគ្មាន។លទ្ធផលនេះបង្ហាញឱ្យឃើញថាការ បែងចែកគ្រូទៅតាមអនុវិទ្យាល័យក្នុងស្រុកនេះមិនទាន់គិតគូបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យកាតគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពនៃការអប់រំ។




*ក្រាហ្វទី 11៖*
*តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)តាមនិយាមនៃមុខវិជ្ជានីមួយៗនិងគ្រូបង្រៀនដែលមានជាក់ស្តែងនៃមុខវិជ្ជានីមួយៗ តាមអនុវិទ្យាល័យក្នុងស្រុកទី២*

## ៤.៣ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិស្រុកទី៣

ក្នុងស្រុកទី៣ សំណាកដែលត្រូវបានជ្រើសរើសមានចំនួន ១៤អនុវិទ្យាល័យមានស្ថិតិសិស្ស ៣៨៥៥ នាក់។តាមនិយាមត្រូវមានថ្នាក់ចំនួន ៨៦ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ២៧៥២ ម៉ោងដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានសម្រាប់គ្រប់មុខវិជ្ជាចំនួន១៥៣នាក់ ។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែងអនុវិទ្យាល័យក្នុងស្រុកទី៣ នេះមាន ៨១ថ្នាក់ ម៉ោង ២៥៩២គឺមិនត្រូវទៅតាមនិយាមទេព្រោះគ្រូកម្រិតមូលដ្ឋានមានរហូតដល់ទៅ ២៣៤នាក់គឺលើសគ្រូចំនួន ៨១នាក់(២៣៤ដកនឹង១៥៣)។ នេះបញ្ជាក់ឱ្យឃើញថាការបែងចែកគ្រូបង្រៀននៅស្រុកទី៣មិនទាន់សមស្របទៅតាមនិយាមនិងមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

ដំណោះស្រាយចំពោះមុខគឺប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានដែលនង្រៀន មិនគ្រប់ម៉ោងទៅតាម

និយាមដែលក្រសួងបានកំណត់ជួយបង្រៀនមុខវិជ្ជាណាដែលខ្វះគ្រូ។

*តារាងទី 4៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅតាមអនុវិទ្យាល័យក្នុងស្រុកទី៣*

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 3855 | |
| ថ្នាក់ | 86 | 81 |
| ម៉ោង | 2752 | 2592 |
| គ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) | 153 | ១៩៧ |

បើតាមរបាយគ្រូមុខវិជ្ជានីមួយៗក្នុងអនុវិទ្យាល័យទាំង ១៤ ក្នុងស្រុកទី៣វិញបានបង្ហាញថាមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ចំនួន រីឯមុខវិជ្ជាដ៏ទៃទៀតលើសទៅវិញ។ដូច្នេះក្រាហ្វទី២ ខាងក្រោមបង្ហាញពីតម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិ( កម្រិតមូលដ្ឋាន )លើមុខវិជ្ជាចំនួន ១៣ រួមមាន៖ គណិតវិទ្យា អក្សរសាស្ត្រ ខ្មែរ ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋ ICT គេហវិទ្យា ភាសាបរទេស អប់រំកាយ សម្រាប់ស្រុកទី៣ ។ តាមរយៈក្រាបទី២ នេះបង្ហាញឱ្យឃើញថាមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ ជីវវិទ្យា រូបវិទ្យា ប្រវត្តវិទ្យា សីលធម៌ពលរដ្ឋ ភាសាបរទេស អប់រំកាយ ចំនួនគ្រូដែលមាន គុណវុឌ្ឍិ ( កម្រិតមូលដ្ឋាន )លើសពីតម្រូវការតាមនិយាម។ រីឯមុខវិជ្ជា គីមីវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា គេហ មានចំនួនគ្រូដែលមានគុណវុឌ្ឍិ ( កម្រិតមូលដ្ឋាន ) តិចជាងតម្រូវការ។ ចំពោះមុខវិជ្ជា ICT គ្មានគ្រូដែលមាន គុណវុឌ្ឍិ ( កម្រិតមូលដ្ឋាន )តាមនិយាមទេ ។នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់ គ្រូនៅក្នុងស្រុកទី៣នេះនៅមានកម្រិត។




*ក្រាហ្វទី 12៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៣*

ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាសំខាន់ៗលើ១៣ មុខវិជ្ជាដើម្បីធ្វើការប្រៀបធៀប ចំនួនគ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) ធៀបទៅនិងចំនួនតម្រូវការគ្រូគិតតាមនិយាម។ ជាលទ្ធផលបង្ហាញឱ្យឃើញថាមានសាលារៀនខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន លើមុខវិជ្ជាខ្លះ រីឯសាលាខ្លះទៀតខ្វះគ្រូបង្រៀនលើមុខវិជ្ជានោះ និងសាលាខ្លះទៀតមានគ្រូបង្រៀនគ្រប់ចំនួន។ តួយ៉ាងដូចជាមុខវិជ្ជា រូបវិទ្យានៅសាលាទី១ ទី២ ទី៣ ទី៧ ទី១០ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាម ចំនួន ១, ១, ២, ១, ១ នាក់ គ្រូជាក់ស្តែងមាន ២, ២, ៤, ២,២ នាក់ លើសពីតម្រូវការ១នាក់ៗចំពោះសាលាទី១ ទី២ ទី៧ ទី១០ ចំណែកសាលាទី៣ លើសពីតម្រូវការ ២នាក់ ចំណែកសាលាទី៨ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាម១នាក់ប៉ុន្តែគ្រូកម្រិតមូលដ្ឋានតាមជាក់ស្តែងគ្មាន។ សាលាទី៤,ទី៥,ទី៦, ទី៩, ទី១១, ទី១២, ទី១៣, ទី១៤នៃស្រុកនេះគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) ជាក់ស្តែងគ្រប់ចំនួនទៅតាម

និយាមដែលច្បាប់បានកំណត់ ។ លទ្ធផលនេះបង្ហាញឱ្យឃើញថាការបែងចែកគ្រូទៅតាមអនុវិទ្យាល័យក្នុងស្រុកនេះមិនទាន់គិតគូបានត្រឹមត្រូវនោះទេ ។ កត្តានេះបណ្តាលឱ្យកាតគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពនៃការអប់រំ។




*ក្រាហ្វទី 13៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ(គ្រូកម្រិតមូលដ្ឋាន)តាមនិយាមនៃមុខវិជ្ជានីមួយ និងគ្រូបង្រៀនដែលមានជាក់ស្តែងនៃមុខវិជ្ជានីមួយៗ តាមអនុវិទ្យា*

សន្និដ្ឋាន ចំពោះការបែងចែកគ្រូបង្រៀននៅស្រុកទី៣នេះមិនទាន់សមស្របទៅតាមនិយាម និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅស្រុកទី៣នេះគឺ យកគ្រូដែលលើ

សតាមមុខវិជ្ជា ទៅបង្រៀនខុសឯកទេស ចំពោះមុខវិជ្ជាណាដែលខ្វះគ្រូ និងយកគ្រូកម្រិតមូលដ្ឋានទៅបង្រៀននៅវិទ្យាល័យចំពោះមុខវិជ្ជាមួយចំនួន (សាលាដែលអនុវិទ្យាល័យនៅជាមួយវិទ្យាល័យ)។

### ៤.៤ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិស្រុកទី៤

ក្នុងស្រុកទី៤ សំណាកដែលត្រូវបានជ្រើសរើសមានចំនួន ៥អនុវិទ្យាល័យ មានស្ថិតិសិស្ស ៣០៣៩ នាក់។ តាមនិយាមត្រូវមានថ្នាក់ចំនួន ៦៨ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ២១៧៦ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានសម្រាប់គ្រប់មុខវិជ្ជាចំនួន ១២១នាក់ ។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែងអនុវិទ្យាល័យក្នុងស្រុកទី៤ នេះមាន ៨១ថ្នាក់ ម៉ោង ២៥៩២ គឺមិនត្រូវទៅតាមនិយាមទេព្រោះគ្រូកម្រិតមូលដ្ឋានមានរហូតដល់ទៅ ២០៣នាក់ គឺលើសគ្រូចំនួន ៨២នាក់(២០៣ដក១២១) ។ នេះបញ្ជាក់ឱ្យឃើញថាការបែងចែកគ្រូបង្រៀននៅស្រុកទី៤មិនទាន់សមស្របទៅតាមនិយាម និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

ដំណោះស្រាយចំពោះមុខគឺប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានដែលនង្រៀន មិនគ្រប់ម៉ោងទៅតាមនិយាមដែលក្រសួងបានកំណត់ជួយបង្រៀនមុខវិជ្ជាណាដែលខ្វះគ្រូ។

*តារាងទី ៥៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅតាមអនុវិទ្យាល័យក្នុងស្រុកទី៤*

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 3039 | |
| ថ្នាក់ | 68 | 81 |
| ម៉ោង | 2176 | 2592 |
| គ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) | 121 | 203 |

បើតាមរបាយគ្រូមុខវិជ្ជានីមួយៗក្នុងអនុវិទ្យាល័យទាំង ៥ ក្នុងស្រុកទី៤ វិញបានបង្ហាញថាមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ចំនួន រីឯមុខវិជ្ជាដ៏ទៃទៀតលើសទៅវិញ ។ដូច្នេះក្រាហ្វទី២ ខាងក្រោមបង្ហាញពីតម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)លើមុខវិជ្ជាចំនួន ១៣ រួមមាន៖ គណិតវិទ្យា អក្សរសាស្ត្រ ខ្មែរ ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋ ICTគេហវិទ្យា ភាសា

បរទេស អប់រំកាយ សម្រាប់ស្រុកទី៤ ។ តាមរយៈក្រាបទី២ នេះបង្ហាញឱ្យឃើញថាមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ គីមីវិទ្យា រូបវិទ្យា ប្រវត្តិវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា ភាសាបរទេសចំនួនគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន)លើសពីតម្រូវការតាមនិយាម។ រីឯមុខវិជ្ជា ជីវវិទ្យា សីលធម៌ពលរដ្ឋ ICT គេហវិទ្យា អប់រំកាយ។ មានចំនួនគ្រូដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)តិចជាងតម្រូវការ ។ ចំពោះមុខវិជ្ជា ICT គ្មានគ្រូ ដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)តាមនិយាមទេ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែកនិងប្រើប្រាស់គ្រូនៅក្នុងស្រុកទី៤ នេះនៅមានកម្រិត។




*ក្រាហ្វទី 14៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៤*

ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាសំខាន់ៗលើ ១៣មុខវិជ្ជាដើម្បីធ្វើការប្រៀបធៀប ចំនួនគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) ធៀបទៅនិងចំនួនតម្រូវការ គ្រូគិតតាមនិយាម ។ ជាលទ្ធផលបង្ហាញឱ្យឃើញថាមានសាលារៀនខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន លើ មុខវិជ្ជាខ្លះ រីឯសាលាខ្លះទៀតខ្វះគ្រូបង្រៀនលើមុខវិជ្ជានោះ និងសាលាខ្លះទៀតមានគ្រូបង្រៀនគ្រប់ចំនួន ។ តួយ៉ាងដូចជាមុខវិជ្ជា អក្សរសាស្ត្រខ្មែរនៅសាលាទី១ ទី២ ទី៤ ទី៥ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាម ចំនួន ៦, ៥, ៥, ៣ នាក់ គ្រូជាក់ស្តែងមាន ៧, ៧, ១៩,៤ នាក់ លើសពីតម្រូវការ១នាក់ៗចំពោះសាលាទី១ និងសាលាទី៥ ចំណែកសាលាទី៤ លើសពីតម្រូវការ ១៤នាក់ ។ ចំណែកឯមុខវិជ្ជា គីមីវិទ្យា នៅសាលាទី៣ និង

ទី៤ តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាម ១ នាក់ៗប៉ុន្តែគ្រូកម្រិតមូលដ្ឋានតាមជាក់សាលាទី៣មាន ២នាក់ សាលាទី៤ មាន៤នាក់ ។ ចំណែកសាលាទី១ គ្រូជាក់ស្តែងគ្មាន។ គ្រូភាសាបរទេស សាលាទី១,ទី២,ទី៤, ទី៥,តម្រូវការគ្រូកម្រិតមូលដ្ឋានតាមនិយាមចំនួន ៤, ៤, ៤, ២ នាក់ គ្រូជាក់ស្តែងមាន១០, ៥, ៨,៤ នាក់ ដោយសាលាទី១ លើសពីតម្រូវការ៦នាក់ សាលាទី២ លើសពីតម្រូវការ១នាក់សាលាទី៤លើសពីតម្រូវការ ៤នាក់សាលាទី៥ លើសពីតម្រូវការ២នាក់។លទ្ធផលនេះបង្ហាញឱ្យឃើញថាការបែងចែកគ្រូទៅតាមអនុវិទ្យាល័យ ក្នុងស្រុកទី៤នេះមិនទាន់គិតគូបានត្រឹមត្រូវនោះទេ ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពអប់រំ។

សន្និដ្ឋាន ចំពោះការបែងចែកគ្រូបង្រៀននៅស្រុកទី៤នេះមិនទាន់សមស្របទៅតាមនិយាម និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ ។ ការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅស្រុកទី៤នេះគឺ យកគ្រូដែលលើសតាមមុខវិជ្ជា ទៅបង្រៀនខុសឯកទេស ចំពោះមុខវិជ្ជាណាដែលខ្វះគ្រូ និងយកគ្រូកម្រិតមូលដ្ឋានទៅបង្រៀននៅវិទ្យាល័យចំពោះមុខវិជ្ជាមួយចំនួន (សាលាដែលអនុវិទ្យាល័យនៅជាមួយវិទ្យាល័យ)។




*ក្រាហ្វទី 15៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិ (គ្រូកម្រិតមូលដ្ឋាន)តាមនិយាមនៃមុខវិជ្ជានីមួយ និងគ្រូបង្រៀនដែលមានជាក់ស្តែងនៃមុខវិជ្ជានីមួយៗ តាមអនុវិទ្យាល័យក្នុងស្រុកទី៤*

## ៤.៥ តម្រូវការគ្រូ និងបំណែងចែកភារកិច្ចគ្រូ

តាមរយៈលទ្ធផលស្រាវជ្រាវខាងលើបានបង្ហាញថាកង្វះគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) មុខវិជ្ជាមួយចំនួនពិសេសគ្រូព័ត៌មានវិទ្យានៅតាមអនុវិទ្យាល័យនានា ក្នុងខេត្តព្រះសីហនុគឺក្លាយជាបញ្ហាប្រឈមសំខាន់បំផុតសម្រាប់នាយកទាំងអស់ចំពោះបំណែងចែកភារកិច្ចបុគ្គលិកតាមអង្គភាពនីមួយៗ។

រយៈពេលកន្លងមក ដំណោះស្រាយនៅតាមសាលានីមួយៗតែងតែធ្វើផែនការត ម្រូវការគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) របស់ខ្លួនព្រោះជាការងារ បច្ចេកទេសរបស់គណៈគ្រប់គ្រង ដើម្បីបំពេញសេចក្តីខ្វះខាតនៅតាមអនុវិទ្យាល័យរបស់ខ្លួន។គណៈគ្រប់គ្រងបានធ្វើផែនការតម្រូវការគ្រូដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) ជារៀងរាល់ឆ្នាំ មកថ្នាក់ស្រុក ថ្នាក់មន្ទីរ ថ្នាក់ក្រសួង ដើម្បីឱ្យរៀបចំចាត់ចែងបុគ្គលិក និងបញ្ជូន មកទាន់ពេលវេលា តាមសេចក្តីត្រូវការក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់សាធារណៈរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំយុវជន និងកីឡា បានត្រួតពិនិត្យឡើងវិញនូវការ គ្រប់គ្រងមន្ត្រីរាជការប្រកបដោយការទទួលខុសត្រូវក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការឱ្យស្របតាមនិយាមកំណត់មួយនិងការពង្រាលយគ្រូឱ្យដល់ទីកន្លែងដែលមានតម្រូវការ (សេចក្តីណែនាំស្តីពីការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ ,២០១៨)

រាល់ការធ្វើសំណើទាំងអស់សុទ្ធតែបានបញ្ជូនទៅដល់ មន្ទីរ ក្រសួង ប៉ុន្តែអង្គភាពទាំងនោះពុំសូវបានបញ្ជូនគ្រូដែលមានគុណវុឌ្ឍ (កម្រិតមូលដ្ឋាន) ឱ្យគ្រប់ចំនួនតាមសេចក្តីត្រូវការនោះទេ (សេចក្តីណែនាំស្តីពីនិយាមមប្រើប្រាស់បុគ្គលិកអប់រំ ខែឧសភា ឆ្នាំ២០១៨)។ ដូច្នេះដើម្បីដោះស្រាយចំពោះមុខជាក់ស្តែងដើម្បីដំណើរការសាលារៀន គណៈគ្រប់កគ្រងសាលាបានជ្រើសរើសយកគ្រូកម្រិតមូលដ្ឋានដែលលើសតាមមុខវិជ្ជាឱ្យជួយបង្រៀនមុខវិជ្ជាណាដែលខ្វះគ្រូ ឬគ្មានគ្រូតាមមុខវិជ្ជានីមួយៗ ឬឱ្យជួយបង្រៀននៅវិទ្យាល័យដែលសាលាអនុវិទ្យាល័យនៅជាមួយ។

## ៤.៦ បញ្ហាប្រឈមក្នុងការគ្រប់គ្រងអនុវិទ្យាល័យ

ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវបានរកឃើញថានៅតាមគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិបាន នឹងកំពុងប្រឈមនិងបញ្ហាមួយចំនួនក្នុងការគ្រប់គ្រងបុគ្គលិក ដោយនៅតាមសាលាមួយចំនួនមានគ្រូផ្ទេរចេញ ផ្ទេរចូលច្រើន កង្វះគ្រូតាមមុខវិជ្ជាឯកទេស ឬលើសគ្រូតាមមុខវិជ្ជាឯកទេស។ ដូច្នេះអនុវិទ្យាល័យតាមស្រុកមួយចំនួនខ្វះគ្រូបង្រៀន ដោយសារមានគ្រូផ្ទេរចេញច្រើន ជាពិសេសសាលាទើបបង្កើតអនុវិទ្យាល័យថ្មី ឬតំបន់ឆ្ងាយពីទីប្រជុំជន តំបន់ជួបការលំបាក និងទីជនបទដាច់ស្រយាលដោយប្រជាពលរដ្ឋ(មាតា បិតាសិស្ស) មានជីវភាពក្រីក្រ លំបាក ហេដ្ឋារចនាសម្ព័ន្ធពិបាកធ្វើដំណើរ ដែលជម្រុញឱ្យគ្រូមួយចំនួនផ្ទេរចេញនៅពេលពួកគាត់បង្រៀនគ្រប់ឆ្នាំកំណត់តាមនិយាមដោយសារបញ្ហាជីវភាព ព្រោះពិបាកធ្វើដំណើរ ឆ្ងាយពី សាច់ញាតិ ស្រុកកំណើត កន្លែងស្នាក់នៅមិនសមរម្យ និងបញ្ហាចំណាយច្រើនជាប្រចាំ និងប្រាក់បៀវត្សនៅមានកម្រិត។

ផ្ទុយទៅវិញអនុវិទ្យាល័យតាមស្រុកមួយចំនួនទៀតមានគ្រូបង្រៀន ដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) ផ្ទេរចូលច្រើន ដែលធ្វើឱ្យចំនួនគ្រូលើសពីតម្រូវការតាមនិយាមទៅវិញ ជាពិសេសអនុវិទ្យាល័យនានាក្នុងទីរួមខេត្ត ទីរួមស្រុក ទីប្រជុំជន ដែលបានផ្តល់ភាពងាយស្រួលក្នុងការរស់នៅ ទាំងការធ្វើដំណើរ ទាំងការរកប្រាក់ចំណូលបន្ថែមដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃតាមរយៈ ការបង្រៀនគួរក្រៅម៉ោងបន្ថែម កត្តាទាំងនេះជម្រុញឱ្យលោកគ្រូ អ្នកគ្រូ ផ្ទេរចូលកាន់តែច្រើន(សិទ្ធិនិងអត្ថប្រយោជន៍ ព្រមទាំងការតព្វកិច្ចរបស់មន្ត្រីរាជការ, ២០១៨)។

សរុបសេចក្តីមកការផ្ទេរចេញ ឬផ្ទេរចូលច្រើនធ្វើឱ្យមានអតុល្យភាពគ្រូបង្រៀន និងធ្វើឱ្យមានរបាយគ្រូបង្រៀនមិនស្មើគ្នា។ លើសពីនេះទៅទៀត ក្រសួង និងមន្ទីរ មិនមានគ្រូបង្រៀនគ្រប់តម្រូវការ ហើយក៏មិនបានបញ្ជូនគ្រូមកតាមតម្រូវការ តាមការស្នើសុំរបស់អនុវិទ្យាល័យនីមួយៗផងដែរ។ ការបញ្ជូនគ្រូទៀតសោតក្រសួងបានបញ្ជូនគ្រូខុសតម្រូវការ ដោយបញ្ជូនគ្រូដែលមានឯកទេសដូចៗគ្នា ធ្វើឱ្យចំនួនលើសកាន់តែច្រើនទៀតនៅក្នុងអនុវិទ្យាល័យមួយចំនួន ដោយឡែកនៅក្នុងអនុវិទ្យាល័យមួយចំនួនទៀត ស្ទើតែគ្មានគ្រូបង្រៀនទៅវិញដែលកត្តានេះហើយនាំឱ្យគណៈគ្រប់គ្រងអង្គភាពយកគ្រូដែលមានឯកទេសផ្សេងបង្រៀនជំនួស។

## ៤.៧លទ្ធផលនៃការសិក្សាស្រាវជ្រាវផ្នែកសាលាបឋមសិក្សា

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាង បានបង្ហាញថាស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពីខេត្តព្រះសីហនុមានដែលមានសាលារៀនចំនួន ៧២ មានសិស្សចំនួន ២៧១២៥ នាក់តាមនិយាមសិស្សមួយថ្នាក់មានចំនួន ៤៥នាក់ (និយាមលេខ២០) ដែលកំណត់ដោយច្បាប់នោះ ចំនួនថ្នាក់នៅក្នុងព្រះសីហនុមាន៦០៣ថ្នាក់ (២៧១២៥ចែកនឹង៤៥)។ តាមនិយាមម៉ោងសិស្សក្នុងមួយថ្នាក់ត្រូវរៀន២៥ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ ១៥០៧៥ម៉ោង (៦០៣ថ្នាក់គុណនឹង២៥ម៉ោង) ដែលត្រូវប្រើប្រាស់គ្រូកម្រិតបឋមចំនួន ៦០៣ នាក់ (និយាមលេខ២០ គ្រូ១/ថ្នាក់)។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីការចុះប្រមូលក្នុងខេត្តខាងលើថ្នាក់សរុបមានដល់ទៅ ៨២២ ថ្នាក់ ច្រើនជាងចំនួនថ្នាក់គិតតាមនិយាម ២១៩ថ្នាក់( ៨២២ថ្នាក់ ដក ៦០៣ថ្នាក់) ឯគ្រូបង្រៀនសរុបវិញមាន ៨៣៦នាក់ ច្រើនជាងនិយាមចំនួន ២33នាក់ ( ៨៣៦នាក់ ដក ៦០៣ នាក់ )។

សន្និដ្ឋានថាការប្រើប្រាស់និយាមសិស្សថ្នាក់របស់ខេត្តសំណាកខាងលើ នេះមិនទាន់គោរពបាននូវនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡានៅឡើយទេ ព្រោះសាលានៅតាមតំបន់ដាច់ស្រយ៉ាលថ្នាក់នីមួយៗមានចំនួនសិស្សមិនគ្រប់តាមនិយាមកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

*តារាងទី ៦៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូ សរុបតាមនិយាម និងតាមជាក់ស្តែង ទូទាំងខេត្តព្រះសីហនុ*

| ចំនួន | ជាក់ស្តែង | តាមនិយាម | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | 27125 | | | |
| ថ្នាក់ | 822 | 603 | 219 | 0 |
| ម៉ោង | 20550 | 15075 | 5475 | 0 |
| គ្រូមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) | 821 | 603 | 218 | 0 |




*ក្រាហ្វទី 16៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ*

## ៤.៨ ស្រុកទី១៖ ស្ថិតិសិស្ស-ថ្នាក់-គ្រូ និងម៉ោង

លទ្ធផលនៃការស្រាវជ្រាវក្នុងខេត្តព្រះសីហនុ ក្នុងស្រុកទី១ចំនួនសិស្សជាក់ស្តែងដែលបានស្រង់តាមភាពជាក់ស្តែងរួមទាំងថ្នាក់ទី១ដល់ទី៦ មានសិស្សសរុបចំនួន២៤៧១នាក់។ តាមនិយាមសិស្សក្នុងមួយថ្នាក់៤៥នាក់ដែលបានកំណត់ដោយច្បាប់នោះ ចំនួនថ្នាក់៥៥ (២៤៧១ ចែកនឹង៤៥)។ តាមនិយាមសិស្សមួយថ្នាក់រៀន ២៥ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ១៣៧៥ម៉ោង (៥៥ គុណ២៥ម៉ោង) ដែលត្រូវ

ប្រើគ្រូ ចំនួន៥៥នាក់។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីស្រុកខាងលើ ចំនួនថ្នាក់សរុបមាន ៨៨ ថ្នាក់ ចំនួនគ្រូដែលមានគុណវុឌ្ឍិបង្រៀនជាក់ស្តែងមានចំនួន៨៨នាក់ដែលកំពុងបម្រើការនៅ បឋមសិក្សាក្នុងស្រុកខាងលើ។ ដូចនេះតាមការប្រមូលទិន្នន័យបង្ហាញថាចំនួនគ្រូបឋមសិក្សានៅក្នុងស្រុកនេះគឺ លើសចំនួន ៣៣នាក់។ ក្នុងករណីគ្រូលើសគ្រូដូចនេះ នាយកសាលាបានឱ្យគ្រូទៅជួយការងារ ក្នុងបណ្ណាល័យ រោងជាង ឬធ្វើជាជំនួយការនាយក ។

*តារាងទី 7៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១*

| ចំនួន | ជាក់ស្តែង | តាមនិយាម | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | 2471 | | | |
| ថ្នាក់ | 88 | 55 | 33 | 0 |
| ម៉ោង | 2200 | 1375 | 825 | 0 |
| គ្រូមានគុណវុឌ្ឍិបង្រៀន( កម្រិតបឋម ) | 88 | 55 | 33 | 0 |




*ក្រាហ្វទី 17៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ*

សន្និដ្ឋាន ក្នុងស្រុកទី១ គ្រូមានគុណវុឌ្ឍិ( កម្រិតបឋមសិក្សា )លើសចំនួន ៣៣នាក់ បើគិតទៅតាមនិ

យាម ចំនួនគ្រូបង្រៀនលើសគ្រប់សាលាទាំងអស់ នេះបញ្ជាក់ថាការបែងចែកសិស្ស ថ្នាក់តាមសាលានីមួយៗ មិនស្របទៅតាមនិយាមដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយការបែងចែកគ្រូពុំទាន់មានតម្លាភាពហើយមិនទាន់បានអនុវត្តពេញលេញទៅតាមលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបែងចែកបុគ្គលិកអប់រំ។

### ៤.៩ ស្រុកទី២ ៖ ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង

លទ្ធផលនៃការស្រាវជ្រាវក្នុងស្រុកទី២ ចំនួនសិស្សជាក់ស្តែងដែលបានស្រង់តាមភាពជាក់ស្តែង រួមទាំងថ្នាក់ទី១-៦ មានសិស្សសរុបចំនួន១៩៣៥នាក់។ តាមនិយាមសិស្សក្នុងមួយថ្នាក់ ៤៥នាក់ដែលបានកំណត់ដោយច្បាប់នោះ ចំនួនថ្នាក់នៅបឋមសិក្សាក្នុងស្រុកទី១ មាន៤៣ថ្នាក់( ១៩៣៥ចែកនឹង៤៥ )។ តាមនិយាមសិស្សមួយថ្នាក់រៀន២៥ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ១០៧៥ម៉ោង( ៤៣គុណ២៥ម៉ោង) ដែលត្រូវប្រើប្រាស់គ្រូ៤៣នាក់ ។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីសាលាបឋមសិក្សាក្នុងស្រុកខាងលើ មានចំនួនថ្នាក់សរុបមាន៦៥ថ្នាក់ចំនួនគ្រូដែលមានគុណវុឌ្ឍិមាន៥៧នាក់ដែលកំពុងបម្រើការងារនៅសាលាបឋមសិក្សាក្នុងស្រុកលើ។ ដូច្នេះគ្រូលើសពីតម្រូវការតាមនិយាមចំនួន១៤នាក់( ៥៧ ដកនឹង៤៣ ) មានន័យថាលើសគ្រូរហូតទៅដល់ ចំនួន១៤នាក់។ ដោយសារលើសគ្រូបង្រៀនដែលមានគុណវុឌ្ឍិបឋមសិក្សាដូច្នេះទើបនាយកចាត់តាំងឱ្យគ្រូខ្លះកាន់ បណ្ណាល័យ គ្រូខ្លះកាន់ផ្នែករោងជាង និងនាយកបង្កើនចំនួនថ្នាក់ដោយមិនអនុវត្តទៅតាមនិយាមដែលបានកំណត់ដោយច្បាប់ឡើយ។

*តារាងទី ៩៖ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាមនិងតាមជាក់ស្តែងក្នុងស្រុកទី២*

| ចំនួន | ជាក់ស្តែង | តាមនិយាម | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | 1935 | | | |
| ថ្នាក់ | 65 | 43 | 22 | 0 |
| ម៉ោង | 1625 | 1075 | 550 | 0 |
| គ្រូមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) | 57 | 43 | 14 | 0 |




*ក្រាហ្វទី 18៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ*

ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរនូវចំនួនគ្រូបង្រៀនជាក់ស្តែង និងតម្រូវការគ្រូទៅតាមនិយាមដែលច្បាប់បានកំណត់ជាក់ស្តែងសាលាទី១,ទី២,ទី៣,ទី៤,ទី៦,ទី៧ ចំនួនគ្រូបង្រៀនជាក់ស្តែងសុទ្ធតែលើសពីតម្រូវការ ចំណែកឯសាលាទី៥ ខ្វះគ្រូបង្រៀន ១នាក់ទៅវិញ ។ លទ្ធផលនេះបង្ហាញឱ្យឃើញថាការបែងចែកគ្រូបង្រៀនទៅតាមសាលាបឋមសិក្សាក្នុងស្រុកនេះមិនទាន់គិតគូបានត្រឹមត្រូវនោះទេ ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពនៃការអប់រំ។

សន្និដ្ឋាន ក្នុងស្រុកទី២ គ្រូមានគុណវុឌ្ឍិ(កម្រិតបឋមសិក្សា)លើសចំនួន ១៤នាក់ បើគិតទៅតាមនិយាម ចំនួនគ្រូបង្រៀនសាលាខ្លះលើស សាលាខ្លះគ្រូបង្រៀនទៅវិញ នេះបញ្ជាក់ថាការបែងចែកគ្រូ សិស្សថ្នាក់តាមសាលានីមួយៗមិនស្របទៅតាមនិយាមដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយការហើយមិនទាន់បានអនុវត្តពេញលេញទៅតាមលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពី ការបែងចែកបុគ្គលិកអប់រំ។

## ៤.១០ ស្រុកទី៣៖ ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង

លទ្ធផលនៃការស្រាវជ្រាវក្នុងស្រុកទី៣ ចំនួនសិស្សជាក់ស្តែង ដែលបានស្រង់តាមភាពជាក់ស្តែងរួមទាំងថ្នាក់ទី១-៦ មានសិស្សសរុបចំនួន១២៣៤៩នាក់។ តាមនិយាមសិស្សក្នុងមួយថ្នាក់ ៤៥នាក់ដែលបានកំណត់ដោយច្បាប់នោះ ចំនួនថ្នាក់នៅបឋមសិក្សាក្នុងស្រុកទី៣នេះ មាន២៧៤ថ្នាក់ (១២៣៤៩ចែកនឹង៤៥) ។ តាមនិយាមសិស្សមួយថ្នាក់រៀន២៥ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ៦៨៥០ម៉ោង(២៧៤គុណ២៥ម៉ោង)ដែលត្រូវប្រើប្រាស់គ្រូ២៧៤នាក់។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីសាលាបឋមសិក្សាក្នុងស្រុកខាងលើ មានចំនួនថ្នាក់សរុបមាន៣៦១ថ្នាក់ចំនួនគ្រូដែលមានគុណវុឌ្ឍិមាន៣៦០នាក់ដែលកំពុងបម្រើការងារនៅសាលាបឋមសិក្សាក្នុងស្រុកលើ។ បើគិតទីតាមនិយាមស្រុកទី៣នេះលើសគ្រូចំនួន ៨៦នាក់ (៣៦០ ដក ២៧៤)។

*តារាងទី ៩៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង ក្នុងស្រុកទី៣*

| ចំនួន | ជាក់ស្តែង | តាមនិយាម | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | 12349 | | | |
| ថ្នាក់ | 361 | 274 | 87 | 0 |
| ម៉ោង | 9025 | 6850 | 2175 | 0 |
| គ្រូមានគុណវុឌ្ឍិ | 360 | 274 | 86 | 0 |

ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរនូវចំនួនគ្រូបង្រៀនជាក់ស្តែង និងតម្រូវការគ្រូទៅតាមនិយាមដែលច្បាប់បានកំណត់ដូចក្នុងក្រាបទី៤ខាងក្រោម៖

ជាក់ស្តែងសាលាទី២,ទី៣,ទី៤,ទី៥,ទី៦,ទី៧,ទី៨,ទី៩,ទី១០,ទី១១,ទី១២,ទី១៣,ទី១៤,ទី១៥,ទី១៦,ទី១៧,ទី១៨,ទី១៩,ទី២០,ទី២១,ទី២២,ទី២៣,ទី២៥,ទី២៦,ទី២៧,ទី២៨,ទី៣០,ទី៣១,ទី៣២,ទី៣៣,ទី៣៤,ទី៣៥,ទី៣៦ចំនួនគ្រូបង្រៀនជាក់ស្តែងសុទ្ធតែលើសពី តម្រូវការចំណែកឯសាលាទី១ខ្វះគ្រូបង្រៀន

២នាក់ សាលាទី២៤,ទី២៥ ខ្វះគ្រូបង្រៀន ១នាក់ៗទៅវិញ។លទ្ធផលនេះបង្ហាញឱ្យឃើញថាការបែងចែកគ្រូបង្រៀនទៅតាមសាលាបឋមសិក្សាក្នុងស្រុកនេះមិនទាន់គិតគូបានត្រឹមត្រូវនោះទេ។

កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពនៃការអប់រំ។

សន្និដ្ឋាន ក្នុងស្រុកទី៣ គ្រូមានគុណវុឌ្ឍិ(កម្រិតបឋមសិក្សា)លើសចំនួន ៨៦នាក់ បើគិតទៅតាមនិយាម ចំនួនគ្រូបង្រៀនសាលាខ្លះលើស សាលាខ្លះគ្រូបង្រៀនទៅវិញ នេះបញ្ជាក់ថាការបែងចែកគ្រូ សិស្សថ្នាក់តាមសាលានីមួយៗ មិនស្របទៅតាមនិយាមដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយការហើយមិនទាន់បានអនុវត្តពេញលេញទៅតាមលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំយុវជន និងកីឡាស្តីពី ការបែងចែកបុគ្គលិកអប់រំ។



*ក្រាហ្វទី 19៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនជាក់ស្តែង គ្រូលើស គ្រូខ្វះ*

## *៤.១១ ស្រុកទី៤៖ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង*

លទ្ធផលនៃការស្រាវជ្រាវក្នុងខេត្តព្រះសីហនុសាលាបឋមសិក្សាក្នុងស្រុកទី៤ បានបង្ហាញថាចំនួន សិស្សជាក់ស្តែងដែលបានស្រង់តាមភាពជាក់ស្តែងរួមទាំងថ្នាក់ទី១-៦ មានសិស្សសរុបចំនួន១០៣៧០នាក់។ តាមនិយាមសិស្សក្នុងមួយថ្នាក់ ៤៥នាក់ដែលបានកំណត់ដោយច្បាប់នោះ ចំនួនថ្នាក់នៅបឋមសិក្សាក្នុងស្រុកទី៤ មាន២៣០ថ្នាក់(១០៣៧០ចែកនឹង៤៥)។ តាមនិយាមសិស្សមួយថ្នាក់រៀន២៥ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ៥៧៥០ម៉ោង(២៣០គុណនឹង២៥ម៉ោង)ដែលត្រូវប្រើប្រាស់គ្រូចំនួន២៣០នាក់ ។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីបឋមសិក្សា ក្នុងស្រុកខាងលើចំនួនថ្នាក់សរុបមាន៣០៤ថ្នាក់ចំនួនគ្រូដែលមានគុណវុឌ្ឍិជាក់ស្តែងមាន៣៣០នាក់ដែលកំពុងបម្រើការងារនៅបឋមសិក្សាក្នុងស្រុកខាងលើ។ បើគិតទៅតាមនិយាមស្រុកទី៤នេះលើសគ្រូដែលមានគុណវុឌ្ឍិ(កម្រិតបឋម )ចំនួន ១០០ នាក់ (៣៣០ ដក២៣០) ដោយសារលើសគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(បឋមសិក្សា) ដូច្នេះទើបនាយកសាលា ចាត់តាំងឱ្យគ្រូខ្លះកាន់បណ្ណាល័យ គ្រូខ្លះកាន់ផ្នែករោងជាង និងគ្រូខ្លះជាជំនួយការនាយក។ ហើយកា របែងចែក សិស្សថ្នាក់ដោយមិនអនុវត្តទៅតាមនិយាមដែលបានកំណត់ដោយច្បាប់ឡើយ។

*តារាងទី 10៖ ស្ថិតិ-សិស្ស-ថ្នាក់-គ្រូតាមនិយាមជាក់ស្តែង ស្រុកទី៤ ខេត្តព្រះសីហនុ*

| ចំនួន | ជាក់ស្តែង | តាមនិយាម | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | 10370 | | | |
| ថ្នាក់ | 304 | 230 | 74 | 0 |
| ម៉ោង | 7600 | 5750 | 1850 | 0 |
| គ្រូមានគុណវុឌ្ឍិបង្រៀន | 330 | 230 | 100 | 0 |

ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរនូវចំនួនគ្រូបង្រៀនជាក់ស្តែង និងតម្រូវការគ្រូទៅ

តាមនិយាមដែលច្បាប់បានកំណត់ដូចក្នុងក្រាបទី៥ខាងក្រោម៖

ដាក់ស្តែងសាលាទី១,ទី២,ទី៣,ទី៤,ទី៥,ទី៦,ទី៧,ទី៨,ទី៩, ទី១១,ទី១២,ទី១៣,ទី១៤,ទី១៥,ទី១៦, ទី១៧, ចំនួនគ្រូបង្រៀនដាក់ស្តែង សុទ្ធតែលើសពីតម្រូវការ ចំណែកឯសាលាទី១០ខ្វះគ្រូបង្រៀន២នាក់ទៅវិញ ។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការបែងចែកគ្រូបង្រៀនទៅតាមសាលាបឋមសិក្សាក្នុងស្រុកនេះមិនទាន់គិតគូបានត្រឹមត្រូវនោះទេ ។កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ ។ ករណីសាលាដែលខ្វះគ្រូនោះនាយកសាលាចាត់ឱ្យគ្រូបង្រៀនដែលមានគុណវុឌ្ឍិបង្រៀនពីពេល ឬថ្នាក់គួប។




*ក្រាហ្វទី 20៖ គ្រូសរុបតាមនិយាម និងតម្រូវការគ្រូបង្រៀនដាក់ស្តែង គ្រូលើស គ្រូខ្វះក្នុងស្រុទី៤ ខេត្តព្រះសីហនុ*

សន្និដ្ឋាន ក្នុងស្រុកទី៤ គ្រូមានគុណវុឌ្ឍិ( កម្រិតបឋមសិក្សា )លើសចំនួន ១០០នាក់ បើគិតទៅតាម

និយាម ចំនួនគ្រូបង្រៀនសាលាខ្លះលើស សាលាខ្លះគ្រូបង្រៀនទៅវិញ នេះបញ្ជាក់ថាការបែងចែកគ្រូ សិស្សថ្នាក់តាមសាលានីមួយៗ មិនស្របទៅតាមនិយាមដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយមិនទាន់បានអនុវត្តពេញលេញទៅតាមលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំយុវជន និងកីឡាស្តីពីការបែងចែកបុគ្គលិកអប់រំ។

## ៤.១២ ដំណោះស្រាយរបស់នាយកសាលាចំពោះសាលា ដែលលើស ឬខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)

មុខវិជ្ជាព័ត៌មានវិទ្យា អប់រំសិល្បៈ អប់រំសុខភាព បំណិនជីវិតមូលដ្ឋាន អនុវិទ្យាល័យដែលមិនបានអនុវត្តមាន ៨០% (២០សាលា)ដោយសារគ្មានសម្ភារឧបទេស និងគ្រូឯកទេស ១០%(៣ សាលា) បានអនុវត្តគ្រប់មុខវិជ្ជា ១០%(៣ សាលា) បានបញ្ចូលមុខវិជ្ជាអប់រំសិល្បៈ អប់រំសុខភាព បំណិនជីវិតមូលដ្ឋាន ទៅក្នុងមុខវិជ្ជាគេហវិទ្យា។ ចំពោះអនុវិទ្យាល័យដែលលើសគ្រូ នាកយសាលាមានដំណោះស្រាយដូចជា៖ ៤៥%(១១ សាលា)ចាត់គ្រូបង្រៀនឱ្យជួយការងារបណ្ណាល័យ ការងារយុវជន និងកុមារ ជួយទីចាត់ការ និង ៣០%(៨ សាលា)បង្កើនម៉ោងបង្រៀនចំពោះមុខវិជ្ជាដែលលើសគ្រូ ២៥%(៧ សាលា)យកគ្រូដែល លើសតាមមុខវិជ្ជាជួយបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ចំពោះវិទ្យាល័យដែលមានអនុវិទ្យាល័យនៅជាមួយ។

ចំពោះអនុវិទ្យាល័យដែលខ្វះគ្រូ នាកយសាលាមានដំណោះស្រាយដូចជា៖ ៧០% (១៨ សាលា) យកគ្រូមកបង្រៀនខុសឯកទេស ២០% (៥ សាលា) បន្ថយម៉ោងបង្រៀន ចំពោះមុខវិជ្ជាដែលខ្វះគ្រូ ១០% (៣ សាលា)យកគ្រូទុតិយភូមិមកជួយបង្រៀន ចំពោះអនុវិទ្យាល័យនៅជាមួយ វិទ្យាល័យ។

សន្និដ្ឋាន ចំពោះខេត្តព្រះសីហនុ អនុវិទ្យាល័យស្ទើរតែទាំងអស់ខ្វះគ្រូបង្រៀន ឯកទេសព័ត៌មានវិទ្យា អប់រំសិល្បៈ អប់រំសុខភាព បំណិនជីវិតមូលដ្ឋាន ហើយសាលាមួយចំនួនចាត់តាំង ឱ្យគ្រូបង្រៀនខុសឯកទេស និងឱ្យគ្រូបង្រៀនកម្រិតមូលដ្ឋានទៅបង្រៀននៅទុតិយភូមិ ចំពោះអនុវិទ្យាល័យដែលនៅជាមួយវិទ្យាល័យ។

**ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូបង្រៀន(កម្រិតមូលដ្ឋាន)**

រយៈពេល ៥ឆ្នាំចុងក្រោយនាយកសាលាទទួលបានគ្រូបង្រៀនតាមការស្នើសុំ៖ ៦០%(១៥ សាលា)

ទទួលបានខ្លះ ៣០%( ៨ សាលា )មិនទទួលបានគ្រូសោះ ១០%( ៣ សាលា )មានគ្រូបង្រៀនគ្រប់ចំនួន។ បញ្ហាប្រឈមក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យគឺ ខ្វះគ្រូឯកទេសមួយចំនួនជាពិសេសគឺឯកទេសព័ត៌មានវិទ្យា( ICT )។

នាយកសាលាបានផ្តល់អនុសាសន៍ចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីខ្វះគ្រូបង្រៀនដូចជា៖៤២% ( ១១សាលា ) បង្កើននិយាមបង្រៀនពី ១៨ម៉ោង ទៅ២០ម៉ោង ៤០%( ១០សាលា ) ផ្តល់គ្រូថ្មីបន្ថែម១០%( ៣សាលា ) កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋានឬសហគមន៍៨% ( ២សាលា ) បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សាទៅជាគ្រូបង្រៀនអនុវិទ្យាល័យ។

នាយកសាលាបានផ្តល់អនុសាសន៍ចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើសគ្រូបង្រៀនដូចជា៖ ៤៨%( ១២សាលា )ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែចំពោះអ្នកស្ម័គ្រចិត្តពង្រាយ ៤០%( ១១សាលា )លើកទឹកចិត្តបង្កើនកាំប្រាក់ ១ឆ្នាំម្តងចំពោះអ្នកស្ម័គ្រចិត្តពង្រាយ ១២%( ៣សាលា ) ប្រើគោលការណ៍ប្តូរវេនសាលាក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង។

សន្និដ្ឋាន នាយកអនុវិទ្យាល័យស្ទើរតែទាំងអស់ក្នុងខេត្តព្រះសីហនុស្នើសុំឱ្យក្រសួងផ្តល់គ្រូបង្រៀនឱ្យបានទាន់ពេលវេលាមុខវិជ្ជាព័ត៌មានវិទ្យា និងកុំព្យូទ័រ ហើយសុំឱ្យក្រសួងបង្កើននិយាមគ្រូបង្រៀនពី ១៨ ម៉ោងទៅ ២០ម៉ោង និងផ្តល់ការលើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ ក៏ដូចជាលើកទឹកចិត្តបង្កើនកាំប្រាក់១ឆ្នាំម្តងចំពោះអ្នកស្ម័គ្រចិត្តពង្រាយពីសាលាលើសគ្រូបង្រៀនទៅសាលាខ្វះគ្រូបង្រៀននៅក្នុងស្រុក។

## ៤.១៣ ដំណោះស្រាយរបស់នាយកសាលា ចំពោះសាលា ដែលលើស ឬ ខ្វះ គ្រូបង្រៀនដែលមានគុណវុឌ្ឍិ( កម្រិតបឋម )

ដំណោះស្រាយរបស់នាយកសាលាចំពោះសាលាបឋមសិក្សាដែលលើសគ្រូបង្រៀនគឺ៖ ៦៥% ( ៤៧ សាលា ) យកគ្រូបង្រៀនដែលលើសឱ្យកាន់បណ្ណាល័យ ពេងជាង និងជួយការងារទីចាត់ការ ៣៥%( ២៥ សាលា ) បង្កើនចំនួនថ្នាក់រៀន។ ដំណោះស្រាយរបស់នាយកសាលាចំពោះសាលាបឋមសិក្សាដែលខ្វះគ្រូបង្រៀន

គឺៈ ៨០%(៥៦សាលា)ស្នើសុំគោលការណ៍ទៅមន្ទីរអប់រំ ដើម្បីរៀបចំឱ្យមានការបង្រៀនថ្នាក់គួប ឬពីរពេល។

សន្និដ្ឋាន ចំពោះនាយកសាលាបឋមសិក្សាភាគច្រើននៅខេត្តព្រះសីហនុ ចាត់ឱ្យគ្រូបង្រៀនដែលលើសទៅកាន់បណ្ណាល័យ រោងជាង ជួយការងារទីចាត់ការ និងបង្កើនចំនួនថ្នាក់រៀន បើសាលាខ្វះគ្រូវិញគឺរៀបចំឱ្យមានការបង្រៀនថ្នាក់គួប ឬបង្រៀនពីរពេល។

**ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូបង្រៀន (កម្រិតបឋម)**

រយៈពេល ៥ឆ្នាំចុងក្រោយនាយកសាលាទទួលបានគ្រូបង្រៀនតាមការស្នើសុំៈ ៦០%(៤៣ សាលា) ទទួលបានខ្លះ ៤០%(២៩សាលា)មិនទទួលបានគ្រូសោះ ។

នាយកសាលាបានផ្តល់អនុសាសន៍ចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីខ្វះគ្រូបង្រៀនដូចជាៈ ៥៥%(៤០សាលា)ផ្តល់គ្រូថ្មីបន្ថែម ៤៥%(៣២សាលា) កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍។

នាយកសាលាបានផ្តល់អនុសាសន៍ចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើសគ្រូបង្រៀនដូចជាៈ ៥០%(៣៦សាលា) ផ្តល់ការលើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សរ៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ ៣០%(២២សាលា) លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តងចំពោះអ្នកស្ម័គ្រចិត្តពង្រាយ ២០%(១៤សាលា)ប្រើគោលការណ៍ប្តូរវេនសាលាក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង។

សន្និដ្ឋាន នាយកសាលាបឋមសិក្សាក្នុង ខេត្តព្រះសីហនុ ស្នើសុំឱ្យក្រសួងអប់រំ យុវជន និងកីឡា ផ្តល់គ្រូថ្មីបន្ថែមឱ្យបានទាន់ពេលវេលាចំពោះសាលាដែលខ្វះគ្រូ ក៏ដូចជាការជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍ ហើយសុំឱ្យក្រសួងផ្តល់ការលើកទឹកចិត្តបន្ថែមលើប្រាក់បៀវត្សន៍រៀងរាល់ខែចំពោះអ្នកស្ម័គ្រចិត្តពង្រាយ ក៏ដូចជាលើកទឹកចិត្តបង្កើនកាំប្រាក់ ១ឆ្នាំម្តងចំពោះអ្នកស្ម័គ្រចិត្តពង្រាយ ពីសាលាលើសគ្រូបង្រៀនទៅសាលាខ្វះគ្រូបង្រៀន នៅក្នុងស្រុក និងស្នើឱ្យក្រសួងប្រើគោលការណ៍ប្តូរវេន សាលាក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការសិក្សា ស្រាវជ្រាវ និងអង្កេតនៅតាមអនុវិទ្យាល័យទាំង២៦ និងសាលាបឋមសិក្សា ៧២ ផ្អែកលើប្រធានបទ « **ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀន នៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ ក្នុងខេត្តព្រះសីហនុ**»មិនទាន់សមស្របនៅឡើយដូចជា (១) ការប្រើប្រាស់និយាមថ្នាក់មិនត្រូវតាមគោលការណ៍ (មានសាលាខ្លះលើសគ្រូ សាលាខ្លះខ្វះគ្រូ)(២) ការពង្រាយគ្រូរបស់ក្រសួងទៅតាមខេត្ត និងពីខេត្តទៅតាមស្រុកមិនទាន់បានសមស្រប (មុខវិជ្ជាខ្លះខ្វះមុខវិជ្ជាខ្លះលើស)។ ហើយករណីនេះអាចកើតមានពីតាមស្រុកទៅតាមសាលារៀននីមួយៗផងដែរ ។ បញ្ហាប្រឈម ធំៗដែលកើត ឡើងចំពោះការប្រើប្រាស់គ្រូមធ្យមសិក្សាបឋមភូមិ និងគ្រូបឋមសិក្សាក្នុងខេត្តព្រះសូហនុមានចំនួនបីគឺ **ទី១** កង្វះគ្រូបង្រៀនឯកទេសច្រើនជាពិសេសមុខវិជ្ជាសង្គម និង ICT**ទី២**ការផ្គត់ផ្គង់គ្រូមិនឆ្លើយតបទៅនិងការស្នើសុំ**ទី៣** គ្រូបង្រៀនផ្ទេរចេញមិនទាន់គ្រប់ឆ្នាំកំណត់។ទស្សនយល់ឃើញរបស់គណៈគ្រប់សាលារៀនលើការដោះស្រាយបញ្ហាប្រឈមចំពោះករណីខ្វះគ្រូសុំផ្តល់គ្រូថ្មីបន្ថែមជ្រើសរើសគ្រូចេញពីមូលដ្ឋានផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដើម្បីលើកទឹកចិត្តគ្រូបង្រៀនដែលស្ម័គ្រចិត្តទៅបង្រៀននៅសាលាដាច់ស្រយាល ឬ តំបន់ជួបការលំបាកប្តូរវេនក្នុងស្រុករៀងរាល់ បីឆ្នាំម្តង ពង្រឹងការអនុវត្តច្បាប់ក្នុងការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន ។

ដូច្នេះការគណនាតម្រូវការ ការបែងចែកកូតានិងការប្រើប្រាស់គ្រូបង្រៀនតាមសាលានីមួយៗ ឬតាមស្រុកនីមួយៗគឺជាកូនសោគន្លឹះក្នុងការកំណត់ពីគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ មានទស្សនផ្សេងៗគ្នាជាច្រើនដែលនិយាយអំពីកត្តាធ្វើឱ្យការអប់រំមានគុណភាព។ ទោះជាមានទស្សនខុសៗគ្នាបែបនេះក៏ដោយក៏ មានចំណុចរួមគ្នាមួយគុណភាពនៃការអប់រំ គឺផ្អែកទៅលើគុណភាពរបស់គ្រូបង្រៀន ។ វិធីសាស្ត្រដែលនាយកសាលា ធ្លាប់យកមកអនុវត្តបែបប្រពៃណី ឬតាមទម្លាប់ ដូចជាវិធីគណនាតាមមេគុណសន្ទស្សន៍ ផលធៀបសិស្សគ្រូ ផលធៀបសិស្សថ្នាក់ ឬការស្មានតាមតម្រូវការជាក់ស្តែងដោយគ្មានគោលការណ៍ ឬរូបមន្តជាក់លាក់ជាដើម ។ ការអនុវត្ត

បែបនេះអាចមិនច្បាស់លាស់ ខាតបង់ធនធានកម្លាំងពលកម្ម ខាតថវិកាជាតិ មិនអាចផ្តល់សេវាអប់រំ ប្រកបដោយសមភាព និងសមធម៌និងមិនអាចធ្វើការអភិវឌ្ឍប្រកបដោយនិរន្តភាពបានទេ។ ក្នុងស្ថានការណ៍នេះ ការប្រើប្រាស់វិធីសាស្ត្រគណនាត្រឹមត្រូវ នឹងផ្តល់យុត្តិធម៌ និងតម្លាភាពក្នុងការកំណត់កូតាបែងចែកគ្រូបង្រៀន និងការប្រើប្រាស់គ្រូបង្រៀនទៅតាមតម្រូវការជាក់ស្តែង ។ តាមរយៈមូលដ្ឋានដ៏រឹងមាំនេះ បានជួយដល់ ការអភិវឌ្ឍ លើផ្នែក ផ្សេងៗទៀតដូចជា ការសាង សង់សាលារៀន ការជុសជុលថ្នាក់ ការពង្រីកថ្នាក់ សម្ភារសិក្សា និងការចំណាយផ្សេងៗ។ សមធម៌ក្នុងការផ្តល់សេវាអប់រំ និងជួយពង្រឹងដល់គុណភាពអប់រំតាមរយៈការបែងចែក និងប្រើប្រាស់ គ្រូបង្រៀនដែលមានទេពកោសល្យខ្ពស់ដល់សាលាតូចៗនៅតាមជនបទហើយជួបការលំបាក ។ ក្នុងករណីសាលានៅទីក្រុង ឬទីប្រជុំជនលើសគ្រូបង្រៀនដែលមានគុណវុឌ្ឍិ ឬឯសាលានៅតាមជនបទខ្វះគ្រូ ដែលធ្វើឱ្យលទ្ធផល សិក្សារបស់សិស្សពិបាកនិងប្រកួតប្រជែងរវាងសាលាទាំងពីរប្រភេទខាងលើនេះណាស់។

## ៥.២ សំណូមពរ

ចំពោះសាលារៀន៖ ធ្វើចំណោលឱ្យបានច្បាស់លាស់ពីតម្រូវការគ្រូ តាមមុខវិជ្ជប្រើប្រាស់គ្រូដែលលើសឱ្យបំពេញការងារឱ្យអស់លទ្ធភាព។

ចំពោះការិយាល័យអប់រំ យុវជន និងកីឡាស្រុក៖ ត្រូវបែងចែកគ្រូបង្រៀនទៅតាមសាលារៀនដោយធ្វើការស្រាវជ្រាវពីតម្រូវការសាលានីមួយៗឱ្យបានច្បាស់លាស់។

ចំពោះមន្ទីរអប់រំយុវជន និងកីឡាខេត្ត៖ ត្រូវបែងចែកគ្រូទៅតាមស្រុក ដោយធ្វើការស្រាវជ្រាវឱ្យបានច្បាស់លាស់ពីតម្រូវការនិងការផ្គត់ផ្គង់ ត្រូវត្រួតពិនិត្យតាមដានការបែងចែកគ្រូបន្តពីស្រុកទៅសាលារៀនជាប្រចាំជាពិសេសត្រូវពិនិត្យមើល ពីការអនុវត្តនិយាមនៃការប្រើប្រាស់គ្រូ និងការផ្លាស់ប្តូរគ្រូបង្រៀន។

ចំពោះក្រសួងអប់រំយុវជននិងកីឡា៖ឧបត្ថម្ភថវិកា ឬសម្ភារផ្សេងៗជាការលើកទឹកចិត្តដល់គ្រូបង្រៀនដែលស្ម័គ្រចិត្តទៅបម្រើការងារនៅតំបន់ដាច់ស្រយាល និងជួបការលំបាកផ្គត់ផ្គង់គ្រូទៅតាមតម្រូវការជាក់ស្តែងទាំងចំនួន និងមុខវិជ្ជាឯកទេស ។

សរុបរួមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ និងបែងចែកគ្រូបង្រៀន គឺត្រូវតែមានការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងធនធានអប់រំឱ្យមានលក្ខណៈជាប្រព័ន្ធ តាមការប្រើវិធីគណនាតម្រូវការគ្រូបង្រៀនដូចជាការធ្វើចំណោល និងការប្រើប្រាស់រូបមន្តជាក់លាក់ ។ ការបែងចែក និងប្រើប្រាស់គ្រូបង្រៀនបានត្រឹមត្រូវនិងផ្តល់តម្លៃដល់ស្ថាប័ន និងចំណោញថវិកាជាតិ ។ ការបណ្តុះបណ្តាលនាយកសាលាលើការគ្រប់គ្រង និងការបែងចែកធនធានអប់រំរឹតតែចាំបាច់ព្រោះនាយកសាលាជាអ្នកអនុវត្តផ្ទាល់។

## ៥.៣ ការងារស្រាវជ្រាវបន្ត

វិសាលភាពនៃការសិក្សាស្រាវជ្រាវនេះធ្វើឡើងចំពោះអនុវិទ្យាល័យ ១៨ វិទ្យាល័យ ដែលមានអនុវិទ្យាល័យនៅជាមួយ៨ និងសាលាបឋមសិក្សាចំនួន ៧២ ដោយផ្តោតលើតែនាយក ឬនាយករង នាយិកា ឬនាយិការរង នៅក្នុងខេត្តព្រះសីហនុ ។ ដូច្នេះពុំបានស៊ីជម្រៅគ្រប់ជ្រុងជ្រោយទេ សង្ឃឹមថាអ្នកសិក្សាស្រាវជ្រាក្រោយៗ និងជ្រើសរើសយកអ្នកចូលរួមច្រើនជាងនេះ ដោយមានប្រធានក្រុមបច្ចេកទេសលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីធ្វើឱ្យការស្រាវជ្រាវនេះកាន់តែប្រសើរ និងភាពចាំបាច់ក្នុងការពង្រីកវិសាលភាពជាងនេះ និងកាន់តែច្បាស់ទាក់ទងលើប្រធានបទ «**ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ**» ។

# ឯកសារយោង ( REFERENCES )


(២០១៧).*( អនុក្រឹតលេខ ១០ អនក្រ.បក ចុះថ្ងៃទី៣០ មករា ២០១៧ ស្តីពីការកម្រិតម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ*.ភ្នំពេញៈ អនុក្រឹត.

ក្រសួងអប់រំ. (២០១៦).*បំណិនវិជ្ជាជីវៈសម្រាប់បំប៉ននាយកសាលាបឋមសិក្សា និងមធ្យមសិក្សា*.ភ្នំពេញ.

(២០១៤-២០១៨).*ក្រសួងអប់រំយុវជន និងកីឡា ផែនការយុទ្ធសាស្ត្រឆ្នាំ*.ភ្នំពេញៈ ក្រសួងអប់រំ.

(២០១៧).*គោលនយោបាយគ្រូបង្រៀន*.ភ្នំពេញៈ វិទ្យាស្ថានជាតិអប់រំ.

(២០១៥).*គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យអប់រំ*.ភ្នំពេញៈ រាជរដ្ឋាភិបាលកម្ពុជា.

(២០១៧).*បណ្ឌិត នូវ វ៉ាំឧត្តមភាពបុគ្គល ការសាងទំនុកចិត្តលើខ្លួនឯង*.ភ្នំពេញ.

(២០២០).*បណ្ឌិត សៀង សុវណ្ណាការគេណនាតម្រូវការគ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យ*.ភ្នំពេញ.

(២០១៦).*បណ្ឌិត ហង់ ជួនណារ៉ុនផែនការសកម្មភាពស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ*.ភ្នំពេញ.

(២០១០).*ផែនការគោលសម្រាប់អភិវឌ្ឍគ្រូបង្រៀន*.ភ្នំពេញៈ ក្រសួងអប់រំ យុវជន និងកីឡា.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥).*គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំ*.ភ្នំពេញ.

(២០១៨).*សិទ្ធិ និងអត្ថប្រយោជន៍ ព្រមទាំងកាតព្វកិច្ចរបស់មន្ត្រីរាជការ*.ភ្នំពេញ.

(២០១៨).*សេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី ៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើបុគ្គលិកអប់រំ*.ភ្នំពេញៈ សេចក្តីណែនាំ.

(២០០២).*សេចក្តីណែនាំលេខ ២៥៦ អយក.សណន ចុះថ្ងៃទី២៩ មករា ២០០២ ស្តីពី ការកំណត់និយាមនិងប្រើប្រាស់មន្ត្រីរាជការសម្រាប់មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅនិងសាលាគរុកោសល្យ*.ភ្នំពេញៈ សេចក្តីណែនាំ.

(២០១៥).*សេចក្តីណែនាំលេខ ៤៩៨ មស.សណន ចុះថ្ងៃទី១៩ កុម្ភៈ២០១៥ ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យានៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ*.ភ្នំពេញ: សេចក្តីណែនាំ.

(២០១៥).*សេចក្តីណែនាំលេខ ៤៩៨មស.សណន ចុះថ្ងៃទី១៩កុម្ភៈ២០១៥ ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យានៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ*.ភ្នំពេញ.

(២០១៤).*អនុក្រឹតលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី៣០ ធ្នូ ២០១៤ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀននៅគ្រឹះស្ថានសាធារណៈបឋមសិក្សា*.ភ្នំពេញ: អនុក្រឹត.

# ឧបសម្ព័ន្ធ

## បញ្ជីឈ្មោះសាលាអនុវិទ្យាល័យទាំង១៨វិទ្យាល័យ៨ដែលមានអនុវិទ្យាល័យនៅជាមួយ

| | |
|---|---|
| I. **ស្រុកទី១**(**ស្ទឹងហាវ**) | |
| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះអនុវិទ្យាល័យនិងវិទ្យាល័យពិត |
| វិទ្យាល័យ១ | វិទ្យាល័យហ.ស កែវផុស |
| វិទ្យាល័យ២ | វិទ្យាល័យស្ទឹងហាវ |
| អនុវិទ្យាល័យ៣ | អនុវិទ្យាល័យទំនប់រលកថ្មី |
| II. **ស្រុកទី២**(**កំពង់សិលា**) | |
| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះអនុវិទ្យាល័យនិងវិទ្យាល័យពិត |
| វិទ្យាល័យ១ | វិទ្យាល័យហ.ស កំពង់សិលា |
| អនុវិទ្យាល័យ២ | អនុវិទ្យាល័យស្ទឹងឆាយ |
| អនុវិទ្យាល័យ៣ | អនុវិទ្យាល័យស្ទឹងសំរោង |
| អនុវិទ្យាល័យ៤ | អនុវិទ្យាល័យចម្ការហ្លួង |
| III. **ស្រុកទី៣**(**ព្រៃនប់**) | |
| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះអនុវិទ្យាល័យនិងវិទ្យាល័យពិត |
| វិទ្យាល័យ១ | វិទ្យាល័យហ.ស ព្រៃនប់ |
| វិទ្យាល័យ២ | វិទ្យាល័យស្មាច់ដែង |
| វិទ្យាល័យ៣ | វិទ្យាល័យហ.ស វាលរិញ |
| អនុវិទ្យាល័យ៤ | អនុវិទ្យាល័យទួលទទឹង |
| អនុវិទ្យាល័យ៥ | អនុវិទ្យាល័យតានៃ |
| អនុវិទ្យាល័យ៦ | អនុវិទ្យាល័យអូរចំណារ |
| អនុវិទ្យាល័យ៧ | អនុវិទ្យាល័យសំរុង |
| អនុវិទ្យាល័យ៨ | អនុវិទ្យាល័យសាមគ្គី |
| អនុវិទ្យាល័យ៩ | អនុវិទ្យាល័យអណ្តូងថ្ម |

| | |
|---|---|
| អនុវិទ្យាល័យ១០ | អនុវិទ្យាល័យទួលកែវ |
| អនុវិទ្យាល័យ១១ | អនុវិទ្យាល័យបិតត្រាំងមិត្តភាព |
| អនុវិទ្យាល័យ១២ | អនុវិទ្យាល័យព្រែកសង្កែ |
| អនុវិទ្យាល័យ១៣ | អនុវិទ្យាល័យបឹងតាព្រហ្ម |
| អនុវិទ្យាល័យ១៤ | អនុវិទ្យាល័យអូរជ្រៅ |
| IV. **ស្រុកទី៤**(**ក្រុងព្រះសីហនុ**) | |
| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះអនុវិទ្យាល័យនិងវិទ្យាល័យពិត |
| វិទ្យាល័យ១ | វិទ្យាល័យហ.ស មិត្តភាព |
| វិទ្យាល័យ២ | វិទ្យាល័យហ.ស ឃ្លាំងលើ |
| អនុវិទ្យាល័យ | អនុវិទ្យាល័យកម្មករ |
| អនុវិទ្យាល័យ | អនុវិទ្យាល័យសម្តេចឪ |
| អនុវិទ្យាល័យ | អនុវិទ្យាល័យសាគូរ៉ា |

# សាលាបឋមសិក្សាទាំង៧២(ខេត្តព្រះសីហនុ)

| I. **ស្រុកទី១(កំពង់សិលា)** | |
|---|---|
| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាបឋមសិក្សាពិត |
| សាលាបឋមសិក្សា១ | សាលាបឋមសិក្សាព្រៃប្រសិទ្ធ |
| សាលាបឋមសិក្សា២ | សាលាបឋមសិក្សាជីស៊ីកំពង់សិលា |
| សាលាបឋមសិក្សា៣ | សាលាបឋមសិក្សាថ្នល់បំបែក |
| សាលាបឋមសិក្សា៤ | សាលាបឋមសិក្សាស្ទឹងសំរោង |
| សាលាបឋមសិក្សា៥ | សាលាបឋមសិក្សាហ.ស កំពង់សិលា |
| សាលាបឋមសិក្សា៦ | សាលាបឋមសិក្សាសម្តេចតា |
| សាលាបឋមសិក្សា៧ | សាលាបឋមសិក្សាដីក្រហម |
| សាលាបឋមសិក្សា៨ | សាលាបឋមសិក្សាគីរីវ័ន្ត |
| សាលាបឋមសិក្សា៩ | សាលាបឋមសិក្សាហ.ស ក្អោង |
| សាលាបឋមសិក្សា១០ | សាលាបឋមសិក្សាភូមិថ្មី |
| សាលាបឋមសិក្សា១១ | សាលាបឋមសិក្សាស្ទឹងប្រាល |
| សាលាបឋមសិក្សា១២ | សាលាបឋមសិក្សាស្ទឹងឆាយ |
| II. **ស្រុកទី២(ស្ទឹងហាវ)** | |
| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាបឋមសិក្សាពិត |
| សាលាបឋមសិក្សា១ | សាលាបឋមសិក្សាចំការខ្ញី |
| សាលាបឋមសិក្សា២ | សាលាបឋមសិក្សាចំរាំង |
| សាលាបឋមសិក្សា៣ | សាលាបឋមសិក្សាទំនប់រលកថ្មី |
| សាលាបឋមសិក្សា៤ | សាលាបឋមសិក្សាកំពេញថ្មី |
| សាលាបឋមសិក្សា៥ | សាលាបឋមសិក្សាអូរត្រេះថ្មី |
| សាលាបឋមសិក្សា៦ | សាលាបឋមសិក្សាថ្មរៀង |
| សាលាបឋមសិក្សា៧ | សាលាបឋមសិក្សាកែវផុស |
| III. **ស្រុកទី៣(ព្រៃនប់)** | |

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាបឋមសិក្សាពិត |
|---|---|
| សាលាបឋមសិក្សា១ | សាលាបឋមសិក្សាអូរចំណារ |
| សាលាបឋមសិក្សា២ | សាលាបឋមសិក្សាអូរតាសេក |
| សាលាបឋមសិក្សា៣ | សាលាបឋមសិក្សាវាលរេញ |
| សាលាបឋមសិក្សា៤ | សាលាបឋមសិក្សាអូរត្រជាក់ចិត្ត |
| សាលាបឋមសិក្សា៥ | សាលាបឋមសិក្សាត្រពាំងគា |
| សាលាបឋមសិក្សា៦ | សាលាបឋមសិក្សាអូថ្មខ៣ |
| សាលាបឋមសិក្សា៧ | សាលាបឋមសិក្សាជើងគោ |
| សាលាបឋមសិក្សា៨ | សាលាបឋមសិក្សាសំរុង |
| សាលាបឋមសិក្សា៩ | សាលាបឋមសិក្សាអូរជ្រៅ |
| សាលាបឋមសិក្សា១០ | សាលាបឋមសិក្សាបឹងតាព្រហ្ម |
| សាលាបឋមសិក្សា១១ | សាលាបឋមសិក្សាបិតត្រាំង |
| សាលាបឋមសិក្សា១២ | សាលាបឋមសិក្សាស្នាច់ដែង |
| សាលាបឋមសិក្សា១៣ | សាលាបឋមសិក្សារាម |
| សាលាបឋមសិក្សា១៤ | សាលាបឋមសិក្សាព្រៃកប្រស់ |
| សាលាបឋមសិក្សា១៥ | សាលាបឋមសិក្សាព្រៃកទាល់ |
| សាលាបឋមសិក្សា១៦ | សាលាបឋមសិក្សាកំពង់ចិន |
| សាលាបឋមសិក្សា១៧ | សាលាបឋមសិក្សាទួលកែវ |
| សាលាបឋមសិក្សា១៨ | សាលាបឋមសិក្សាណារុគីបឹងរាំង |
| សាលាបឋមសិក្សា១៩ | សាលាបឋមសិក្សាព្រៃកក្រាញ់ |
| សាលាបឋមសិក្សា២០ | សាលាបឋមសិក្សាសាមគ្គី |
| សាលាបឋមសិក្សា២១ | សាលាបឋមសិក្សាកំពង់ស្នាច់តូច |
| សាលាបឋមសិក្សា២២ | សាលាបឋមសិក្សាហ.ស តានៃ |
| សាលាបឋមសិក្សា២៣ | សាលាបឋមសិក្សាអន្លង់ក្រពើ |
| សាលាបឋមសិក្សា២៤ | សាលាបឋមសិក្សាដំឡូងមី |
| សាលាបឋមសិក្សា២៥ | សាលាបឋមសិក្សាព្រៃកស្វាយ |

| | |
|---|---|
| សាលាបឋមសិក្សា២៦ | សាលាបឋមសិក្សាមនោរម្យ |
| សាលាបឋមសិក្សា២៧ | សាលាបឋមសិក្សាហ.ស ដូងប្រេង |
| សាលាបឋមសិក្សា២៨ | សាលាបឋមសិក្សាព្រៃកសង្កែ |
| សាលាបឋមសិក្សា២៩ | សាលាបឋមសិក្សាកោះខ្យង |
| សាលាបឋមសិក្សា៣០ | សាលាបឋមសិក្សាផ្កាឈូករ័ត្ន |
| សាលាបឋមសិក្សា៣១ | សាលាបឋមសិក្សាបត់សិរមាន់ |
| សាលាបឋមសិក្សា៣២ | សាលាបឋមសិក្សាអណ្តូងថ្ម |
| សាលាបឋមសិក្សា៣៣ | សាលាបឋមសិក្សា៧៥ |
| សាលាបឋមសិក្សា៣៤ | សាលាបឋមសិក្សាទួលទទឹង |
| សាលាបឋមសិក្សា៣៥ | សាលាបឋមសិក្សាជម្ពូខ្មៅ |
| សាលាបឋមសិក្សា៣៦ | សាលាបឋមសិក្សាព្រៃនប់ |
| IV. **ស្រុកទី៤**(**ក្រុងព្រះសីហនុ**) | |
| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាបឋមសិក្សាពិត |
| សាលាបឋមសិក្សា១ | សាលាបឋមសិក្សាកោះតូច |
| សាលាបឋមសិក្សា២ | សាលាបឋមសិក្សាសុខសាន្ត |
| សាលាបឋមសិក្សា៣ | សាលាបឋមសិក្សាផ្សារលើ |
| សាលាបឋមសិក្សា៤ | សាលាបឋមសិក្សាតេដោសែនកម្មករ |
| សាលាបឋមសិក្សា៥ | សាលាបឋមសិក្សាអូរគ្រែះ |
| សាលាបឋមសិក្សា៦ | សាលាបឋមសិក្សាហ.ស មិត្តភាព |
| សាលាបឋមសិក្សា៧ | សាលាបឋមសិក្សាសាគូរ៉ា |
| សាលាបឋមសិក្សា៨ | សាលាបឋមសិក្សាចំការកៅស៊ូ |
| សាលាបឋមសិក្សា៩ | សាលាបឋមសិក្សាបូរីកម្មករ |
| សាលាបឋមសិក្សា១០ | សាលាបឋមសិក្សាហ.ស ឃ្លាំងលើ |
| សាលាបឋមសិក្សា១១ | សាលាបឋមសិក្សាហ.ស ក្រុង |
| សាលាបឋមសិក្សា១២ | សាលាបឋមសិក្សាកំពេញ |
| សាលាបឋមសិក្សា១៣ | សាលាបឋមសិក្សាអនុវត្ត |

| | |
|---|---|
| សាលាបឋមសិក្សា១៤ | សាលាបឋមសិក្សាជាស៊ីម |
| សាលាបឋមសិក្សា១៥ | សាលាបឋមសិក្សាព្រែកស្វាយ |
| សាលាបឋមសិក្សា១៦ | សាលាបឋមសិក្សាដើមថ្កូវ |
| សាលាបឋមសិក្សា១៧ | សាលាបឋមសិក្សារ៉ុងសន្លឹម |

**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងអប់រំយុវជន និងកីឡា ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

**<u>កម្រងសំណួរ កម្រិត បឋមសិក្សា</u>**

**ប្រធានបទ៖ ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រះសីហនុ**

**កម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា**

**វត្ថុបំណងនៃការស្រាវជ្រាវ៖**

1. រកឱ្យឃើញពីស្ថានភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅតាមបឋមសិក្សា ក្នុងប្រទេសកម្ពុជា។
2. រកឱ្យឃើញនូវយុទ្ធសាស្ត្រសមស្របដើម្បីគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជាឱ្យមានប្រសិទ្ធភាព។

*ការរក្សាការសម្ងាត់*

*ព័ត៌មានដែលទទួលបានពីលោក លោកស្រីសម្រាប់ការវិភាគពីការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជា នឹងត្រូវរក្សាការសម្ងាត់។ អត្តសញ្ញាណរបស់លោក លោកស្រីមិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។*

- **ការកំណត់ពីតម្រូវការ**

1. តើសាលាបឋមសិក្សារបស់លោក~លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា?
   - ក្នុងស្រុក.......................................ឈ្មោះសាលា....................................
2. តើសាលាបឋមសិក្សារបស់លោក~លោកស្រីមានចំនួនសិស្សប៉ុន្មាននាក់និងចំនួនថ្នាក់ប៉ុន្មាន?
   - ថ្នាក់ទី១៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
   - ថ្នាក់ទី២៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
   - ថ្នាក់ទី៣៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
   - ថ្នាក់ទី៤៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
   - ថ្នាក់ទី៥៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
   - ថ្នាក់ទី៦៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
3. តើចំនួនគ្រូ ក្របខ័ណ្ឌដែលមានគុណវុឌ្ឍិ បានបណ្តុះបណ្តាលចេញពីសាលាគរុកោសល្យសរុបប៉ុន្មាននាក់?
   - ចំនួនសរុប......................នាក់ ស្រី.....................នាក់
4. តើគ្រូដែលកំពុងបង្រៀនជាក់ស្តែងមានចំនួនប៉ុន្មាននាក់?
   - ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី................នាក់

5. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់ ?
   - ចំនួនបន្ទប់រៀនជាក់ស្តែង.....................បន្ទប់

6. តើលោក~លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច ?
   - ករណីលើស ..........................................................................................
   ..........................................................................................................
   - ករណីខ្វះ ..............................................................................................
   ..........................................................................................................

- **ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូបង្រៀន**

1. តើសាលាបឋមសិក្សារបស់លោក~លោកស្រីបានទទួលចំនួនគ្រូបង្រៀនតាមការស្នើសុំដែរឬទេ រយៈពេល៥ឆ្នាំចុងក្រោយនេះ ?

**ចំនួនគ្រូបង្រៀនទទួលបានតាមការស្នើសុំគឺ៖**

☐គ្រប់ចំនួន ☐ទទួលបានខ្លះ ☐មិនទទួលបាន ☐ផ្សេងៗ.................

2. តើលោក លោកស្រីផ្តល់អនុសាសន៍ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ?

<u>**ករណីខ្វះ**</u>

☐ ផ្តល់គ្រូថ្មីបន្ថែម
☐ ផ្តល់ប្រាក់ម៉ោងបន្ថែម
☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍
☐ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកិច្ចសន្យាទៅជាគ្រូកម្រិតបឋមសិក្សា ពេញសិទ្ធ
☐ ផ្សេងៗ..........................................................................................

<u>**ករណីលើស**</u>

☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង
☐ ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ
☐ ផ្សេងៗ..........................................................................................

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។

សូមអរគុណ!

***សម្គាល់៖***កម្រិកការពារតាមសាលានីមួយៗ សរុបចូលគ្នា វិភាគលើថ្នាក់ស្រុកនីមួយៗនិងសរុបស្រុកបានថ្នាក់ខេត្ត។

**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងអប់រំយុវជន និងកីឡាជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

**<u>កម្រងសំណួរ កម្រិត អនុវិទ្យាល័យ</u>**

**ប្រធានបទ៖ ស្ថានភាព ក្នុងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តព្រះសីហនុ**

## កម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា

**វត្ថុបំណងនៃការស្រាវជ្រាវ៖**

1. រកឱ្យឃើញពីស្ថានភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យ ក្នុងប្រទេសកម្ពុជា។
2. រកឱ្យឃើញនូវយុទ្ធសាស្ត្រសមស្របដើម្បីគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជាឱ្យមានប្រសិទ្ធភាព។

*ការរក្សាការសម្ងាត់*

*ព័ត៌មានដែលទទួលបានពីលោក លោកស្រីសម្រាប់ការវិភាគពីការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជា នឹងត្រូវរក្សាការសម្ងាត់។ អត្តសញ្ញាណរបស់លោក លោកស្រីមិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។*

- **ការកំណត់ពីតម្រូវការ**

1. តើសាលាអនុវិទ្យាល័យរបស់លោក~លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា?
   - ក្នុងស្រុក..........................................ឈ្មោះសាលា..............................
2. តើសាលាអនុវិទ្យាល័យ របស់លោក~លោកស្រី មានសិស្សចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?
   - ថ្នាក់ទី៧៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៨៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៩៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
3. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់?
   - ចំនួនបន្ទប់រៀនសរុប..................បន្ទប់ ប្រើប្រាស់ជាក់ស្តែង..................បន្ទប់
4. តើគ្រូ ក្របខ័ណ្ឌដែលមានគុណវុឌ្ឍិ បានបណ្តុះបណ្តាលចេញពី សាលាគរុកោសល្យ សរុបចំនួនប៉ុន្មាននាក់?
   - ចំនួនសរុប.......................នាក់ ស្រី......................នាក់
5. តើគ្រូកំពុងបង្រៀនជាក់ស្តែង(មិនគិតមន្ត្រីការិយាល័យចំពោះរបបម៉ោងបន្ថែម)ចំនួនប៉ុន្មាននាក់និងតាមមុខវិជ្ជានីមួយៗចំនួនប៉ុន្មាននាក់?(សូមជួយបំពេញតាមតារាងខាងក្រោមដែលផ្តល់ជូន)
   - ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់

| ល.រ | មុខវិជ្ជាបង្រៀន | ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង | ស្រី |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |
| ៣ | គណិត | | |
| ៤ | រូប | | |
| ៥ | គីមី | | |
| ៦ | ជីវៈ | | |
| ៧ | ផែនដី | | |
| ៨ | ប្រវត្តិ | | |
| ៩ | ភូមិ | | |
| ១០ | សីលធម៌ ពលរដ្ឋ | | |
| ១១ | ICT | | |
| ១២ | អប់រំកាយនិងកីឡា | | |
| ១៣ | អប់រំសិល្បៈ | | |
| ១៤ | អប់រំសុខភាព | | |
| ១៥ | បំណិនជីវិតតាមមូលដ្ឋាន | | |
| សរុបចំនួន | | | |

6. តើក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើតើមុខវិជ្ជាណាខ្លះដែលមិនបានអនុវត្ត ?បញ្ជាក់ពីមូលហេតុ ។

..........................................................................................................................

..........................................................................................................................

..................................................................................................................................

..................................................................................................................

7. បើមុខវិជ្ជាមិនបានអនុវត្តតើម៉ោងមុខវិជ្ជាទាំងនោះយកទៅបញ្ចូលជាមួយមុខវិជ្ជាណា ?

..................................................................................................................................

..................................................................................................................................

.......................................................................................................................

8. តើលោក លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច ?
   - ករណីលើស .......................................................................................................

     ...................................................................................................................

   - ករណីខ្វះ ..........................................................................................................

     ..................................................................................................................

- **ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូបង្រៀន**

1. តើអនុវិទ្យាល័យ របស់លោក~លោកស្រីបានទទួលចំនួនគ្រូបង្រៀន តាមការស្នើសុំដែរ ឬទេរយៈ ពេល ៥ឆ្នាំចុងក្រោយនេះ ?

**ចំនួនគ្រូបង្រៀនទទួលបានតាមការស្នើសុំគឺ៖**

☐គ្រប់ចំនួន ☐ទទួលបានខ្លះ ☐មិនទទួលបាន ☐ផ្សេងៗ.................

2. តើលោក~លោកស្រីជួបប្រទះបញ្ហាប្រឈមអ្វីខ្លះក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យ ?

..................................................................................................................................

..................................................................................................................................

.......................................................................................................................

3. តើលោក លោកស្រីផ្តល់អនុសាសន៍ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ?

**<u>ករណីខ្វះ</u>**

☐ ផ្តល់គ្រូថ្មីបន្ថែម

☐ ផ្តល់ប្រាក់ម៉ោងបន្ថែម

☐ បង្កើននិយាមម៉ោងបង្រៀន ពី១៨ ម៉ោង ទៅ ២០ម៉ោង

☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍

☐ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សា ទៅជាគ្រូអនុវិទ្យាល័យ

☐ ផ្សេងៗ.........................................................

<u>**ករណីលើស**</u>

☐ ប្រើគោលការណ៍ប្ដូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្ដង

☐ ផ្ដល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្ដងចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តដោយផ្ដល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

☐ ផ្សេងៗ...................................................................

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកលោកស្រីដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។*

*សូមអរគុណ!*

***សម្គាល់៖***កម្រិតការពារតាមសាលានីមួយៗ សរុបចូលគ្នា វិភាគលើថ្នាក់ស្រុកនីមួយៗនិងសរុបស្រុកបានថ្នាក់ខេត្ត ធៀបនឹងនិយាម និងកម្មវិធីសិក្សាចាស់។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៤ វជអ.វក

ថ្ងៃ ពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបជូន**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ២៧៧ ខជអ.វក

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ "**ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ**" នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្នន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្នន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សូគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សូគាន | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុធី | ប | តាកែវ |

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នួ ចន្ទី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នួ ចន្ទី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី រដ្ឋា | ឆាន ឆាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី រដ្ឋា | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នួវ វីរ៉ា | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន ឌីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ោញ រដ្ឋា | ស | មណ្ឌលគីរី |
| 25 | លោកបណ្ឌិត នួវ វីរ៉ា | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វួច វី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវជអ "ដើម្បីជ្រាបជាព័ត៌មាន"
-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជអ "ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ ១៣៤ ខជអ. ទក

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុធី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ថាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន ឌីណា | ស | ភ្នំពេញ |
| 24 | ម៉ៅញ រដ្ឋា | ស | មណ្ឌលគិរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | វួច វី | ប | សៀមរាប |
| 27 | ខូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | វ៉ែន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ ៧រោច ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណារ៉ា

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ